ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



◆ មេដឹកនាំខ្មែរក្រហមសមនឹងទទួលបាននូវការកាត់ទោស

◆ នួន ជា មិនត្រូវដើរចេញពីបន្ទប់សវនាការទេ

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខពិសេស១៣៩ ខែកក្កដា ឆ្នាំ២០១១

# ឧស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា

### ផ្នែកសំបុត្រ


◆មេដឹកនាំខ្មែរក្រហមសមនឹងទទួលបាននូវការកាត់ទោស ............................១


### ផ្នែកធំព័រពិសេសនៃករណី០០២


◆ពេលវេលាមួយនៃគម្លាភាព..............................................................៣

◆តើព្រះរាជទានទោស និងការលើកលែងទោស ....................................១៤

◆ថ្ងៃដែលនិយាយពីអាជ្ញាយុកាល និងសំណងជំងឺចិត្ត ............................២៦

◆"គួរតែស្តាប់សាក្សីរបស់ខ្ញុំ"............................................................៤០

◆អៀង សារី ត្រូវតែមានវត្តមានដើម្បីទទួលនូវការកាត់ទោស ...............៥២

◆ខៀវ សំផន មិនដែលទុកចិត្តប្រជាជនរបស់ខ្លួនទេ ..............................៥៤

◆អៀងធីរិទ្ធ : ស្ត្រីដំបូងរបស់កម្ពុជា...............................................៥៦

◆នួន ជា មិនត្រូវដើរចេញពីបន្ទប់សវនាការទេ ................................៥៨

◆ប្រតិកម្មរបស់យុវជនចំពោះសំណុំរឿង០០២ ...................................៥៩



# ស្វែងរកការពិត

លេខពិសេស១៣៩ ខែកក្កដា ឆ្នាំ២០១១



## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា



អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ០២៩១ពម/៩៩

ចុះថ្ងៃទី២ខែសីហាឆ្នាំ១៩៩៩

រូបថតឯកសារ : មជ្ឈមណ្ឌលឯកសារកម្ពុជា

និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង




ចៅក្រមជនជាតិញូវហ្ស៊ីឡែន ស៊ីលវៀ ខាតវ៉្រាយត៍ និងប្រធានចៅក្រម និល ណុន


**ស្នេរលេខនេះ :** គ្រីស៊ីន អ៊ីវេន, អេង កុកថាយ, សើ សាយ្យាណា, ឆាយ ឈុនលី, ឌី ខាំបូលី **អ្នកនិពន្ធនិងស្រាវជ្រាវ :** គាត លក្ខិណា, សោម ប៊ុនថន, ស៊ិន សុធីតា **អ្នកបកប្រែ :** ទែន សុខស្រីនិត **និពន្ធនាយកទូទៅ :** ឆាំង យុ **ជំនួយការនិពន្ធនាយក :** ញាណ សុជាតិ **ក្រាហ្វិកកុំព្យូទ័រ :** ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយ :** ម៉ម សុជាត Email: dccam@online.com.kh, Homepage: www.dccam.org

# មេដឹកនាំខ្មែរក្រហមសមនឹងទទួលបាននូវការកាត់ទោស

ខ្ញុំបានបកប្រែនិក្ខេបបទថ្នាក់បណ្ឌិតរបស់ ខៀវ សំផន ស្តីអំពីការអភិវឌ្ឍឧស្សាហកម្មនិងសេដ្ឋកិច្ចរបស់កម្ពុជានៅពេលដែលខ្ញុំកំពុងសិក្សានៅសហរដ្ឋអាមេរិក ។ សាស្ត្រាចារ្យ ឡូវ៉ា សាំមើស៍ ដែលបានបកប្រែនិក្ខេបបទនេះដំបូងគេពីភាសាបារាំងមកជាភាសាអង់គ្លេសមានចិត្តសប្បុរសនិងបានផ្តល់ការអនុញ្ញាតឲ្យខ្ញុំក្នុងការបកប្រែនិក្ខេបបទនេះជាភាសាខ្មែរដើម្បីទទួលបានពិន្ទុសម្រាប់ការសិក្សារបស់ខ្ញុំ ។ ដូចគ្នាទៅនឹងនិស្សិតកម្ពុជាផ្សេងទៀតដែរ ខ្ញុំចាត់ទុកថា ខៀវ សំផន គឺជាអ្នកចេះដឹងមួយរូប ហើយពិបាកនឹងជឿថាគាត់ជាមនុស្សម្នាក់នៃរបបមួយដែលទទួលខុសត្រូវក្នុងការធ្វើឲ្យប្រជាជនកម្ពុជាស្លាប់ជាងពីរលាននាក់ក្នុងអំឡុងពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ។

ប៉ុន្តែ តាមការវិភាគទៅលើនិក្ខេបបទរបស់ ខៀវ សំផន និងតាមការស្រាវជ្រាវទាក់ទងនឹងរបបខ្មែរក្រហមអស់រយៈពេលពីរទសវត្សរ៍កន្លងមកនេះ ខ្ញុំរកឃើញថា ខៀវ សំផន និងមេដឹកនាំខ្មែរក្រហមឯទៀតបានភូតភរចំពោះការទទួលខុសត្រូវរបស់ខ្លួនពីបទឧក្រិដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យដែលខ្លួនបានដឹកនាំ ។

ក្នុងអំឡុងបុណ្យភ្ជុំបិណ្ឌក្នុងខែកញ្ញាឆ្នាំនេះ សវនាការអង្គជំនុំជម្រះទោសមេដឹកនាំទាំងបួនរួមមាន អៀង សារី, អៀង ធីរិទ្ធ, នួន ជា និង ខៀវ សំផន នឹងចាប់ផ្តើម ។ ប្រសិនបើអំឡុងពេលបុណ្យភ្ជុំបិណ្ឌនេះ ជនជាប់ចោទទាំងនេះបួងសួងដល់ព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ តើជនជាប់ចោទទាំងនេះបានផ្លាស់ប្តូរនូវអ្វីដែលខ្លួនធ្លាប់ធ្វើកាលពីជាងពីរទសវត្សរ៍មុនបានដែរឬទេ? តើព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃអាចជួយសម្រាលជនជាប់ចោទទាំងនោះនូវការទទួលខុសត្រូវពីបទឧក្រិដ្ឋដ៏ព្រៃផ្សៃដែលគូកនរបស់ខ្លួនបានប្រព្រឹត្តទៅលើប្រជាជនកម្ពុជារាប់លាននាក់បានដែរឬទេ? តើព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃអាចលើកទោសដល់បាបកម្មរបស់ជនជាប់ចោទទាំងនោះបានទេ? ខ្ញុំឆ្ងល់ថាតើអ្នកទាំងនោះនឹងនិយាយពាក្យអ្វីទៅកាន់ព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃដែលខ្លួនធ្លាប់កំណត់គោលដៅក្នុងការសម្លាប់ផ្តាច់ពូជ ហើយខ្លួនបានភូតភរ ហើយភូតភរទៀតចំពោះជនរងគ្រោះអស់រយៈពេលជាងសាមសិបឆ្នាំមកហើយទេ ។

ថ្នាក់ដឹកនាំរបស់ខ្មែរក្រហមនៅតែមានជីវិតរហូតដល់សព្វថ្ងៃនេះដូចគ្នាទៅនឹងបទឧក្រិដ្ឋដែលអ្នកទាំងនោះបានប្រព្រឹត្តមកលើប្រជាជនកម្ពុជាដូច្នោះដែរ ។ បទឧក្រិដ្ឋទាំងអស់មិនមែនសម្រាប់អតីតកាលទេ តែសម្រាប់ពេលបច្ចុប្បន្ននេះ ។ ខៀវ សំផន បានអះអាងនៅក្នុងនិក្ខេបបទរបស់ខ្លួនថាខ្លួនចូលបដិវត្តន៍ដោយសារតែខ្លួនចង់ធ្វើឲ្យប្រទេសឯករាជ្យនិងអភិវឌ្ឍន៍ ។ មេដឹកនាំខ្មែរក្រហមផ្សេងទៀតក៏បានដោះសាដោយយកលេសស្រដៀងគ្នានេះដែរ ។ ដោយប្រៀបធៀបការដោះសាទាំងនេះទៅនឹងការស្រាវជ្រាវរបស់ខ្ញុំ និងបទពិសោធន៍ផ្ទាល់ខ្លួនរបស់ខ្ញុំដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហម ខ្ញុំនៅតែឆ្ងល់ថា តើមេដឹកនាំខ្មែរក្រហមទាំងនោះកំពុងនិយាយពីអ្វី?

ខ្ញុំបានឃើញដោយផ្ទាល់ភ្នែកនូវកម្មាភិបាលខ្មែរក្រហមសម្លាប់គូស្នេហ៍មួយគូនៅក្នុងអង្គប្រជុំជាសាធារណៈមួយក្នុងបរិវេណវត្តព្រះនេត្រព្រះ (បច្ចុប្បន្នខេត្តបន្ទាយមានជ័យ) ។ ខ្ញុំបានឃើញមនុស្សរាប់រយនាក់បានស្លាប់ដោយការអត់ឃ្លាន រួមទាំងបងស្រីរបស់ខ្ញុំម្នាក់ផង ហើយខ្ញុំបានចងក្រងជាឯកសារនូវអ្នកដែលបានស្លាប់រាប់លាននាក់ទៀតដោយសារការសម្លាប់ ការធ្វើទារុណកម្ម និងបង្ខំឲ្យធ្វើពលកម្ម ជំងឺ និងការអត់ឃ្លានក្រោមរបបខ្មែរក្រហម ។ អតីតមេដឹកនាំខ្មែរក្រហមបានអះអាងថាប្រជាជនកម្ពុជាមិនដល់មួយលាននាក់ទេបានស្លាប់ក្នុងរបបខ្មែរក្រហម ។ ខ្ញុំឆ្ងល់ណាស់ថាតើមេដឹកនាំទាំងនោះធ្លាប់បានទៅមើលគុកសម្ងាត់ស-២១របស់ខ្លួនទេ ដែលឥឡូវនេះគឺជាគុកទួលស្លែង ។ គុកនេះគឺជាគុកមួយក្នុងចំណោមគុករាប់រយផ្សេងទៀត ហើយគុកសម្ងាត់ស-២១នេះជាកន្លែងដែលអ្នកទោសប្រមាណ ១៨.០០០នាក់ ត្រូវបានធ្វើទារុណកម្មនិងសម្លាប់ ។ តើមេដឹកនាំទាំងអស់នោះមានដឹងទេថាមានរណ្តៅសាកសពប្រហែលជា ២០.០០០កន្លែងទូទាំងប្រទេស?

ពីមុន ខៀវ សំផន ធ្លាប់បានបញ្ជាក់ថា គាត់និងមេដឹកនាំខ្មែរក្រហមឯទៀតមិនជំពាក់នឹងបំណងក្នុងការបង្កើតគុលាការខ្មែរ

ក្រហមទេ ។ តើអ្នកទាំងនោះយល់ពីទស្សនៈនៃយុត្តិធម៌ដែរឬទេ? យុត្តិធម៌ក្នុងរបបខ្មែរក្រហមមានន័យថា អ្នកណាដែលហ៊ានបញ្ចេញពីគំនិតឬទស្សនៈឯករាជ្យត្រូវបានវិនិច្ឆ័យទោសថាជាសត្រូវរបស់ «អង្គការ» ហើយត្រូវតែកម្ចាត់ចោល ។

ម្តងហើយម្តងទៀត មេដឹកនាំខ្មែរក្រហមនៅតែបញ្ជាក់ថា ភាពល្អរបស់ជាតិមួយតម្រូវឲ្យមានការលះបង់ជីវិតដោយប្រជាជនកម្ពុជាខ្លួនឯងផ្ទាល់ ។ ហើយមេដឹកនាំទាំងនោះបានអនុវត្តជំនឿរបស់ខ្លួនដោយការសងសឹក ។ យុត្តិធម៌ក្នុងរបបខ្មែរក្រហមមានន័យថាជា «ខ្មែរត្រូវតែបរិសុទ្ធ» ។ អង្គការបានប្រឌិតរឿងអ្វីៗគ្រប់យ៉ាងដើម្បីវិនិច្ឆ័យគុណភាពទាំងអស់នេះ រួមមានអ្នកដែលមានចំណេះដឹង ឬសប្បុរស ឬអ្នកដែលរស់នៅក្នុងទីក្រុងថាជាសត្រូវ ។ បើសិនជានរណាម្នាក់ធ្លាក់ចូលទៅក្នុងជំពូកមនុស្សខាងលើនេះ ខ្មែរក្រហមនឹងសម្លាប់អ្នកនោះចោល ឬបង្អត់អាហារឲ្យស្លាប់ ។

អតីតមេដឹកនាំខ្មែរក្រហមក៏បាននិយាយដែរថា នឹងមានចលាចលកើតឡើងជាថ្មីទៀតបើសិនជាថ្នាក់ដឹកនាំខ្មែរក្រហមត្រូវយកមកកាត់ទោស ។ ខ្ញុំឆ្ងល់ណាស់ថាហេតុអ្វីបានជាអ្នកទាំងនោះនិយាយពាក្យបែបនេះចេញមករួច? ក្នុងរបបខ្មែរក្រហម មនុស្សម្នាក់ៗត្រូវបានបង្ខំឲ្យបំបិទសិទ្ធិក្នុងការនិយាយស្តី ដោយមិនត្រូវតវ៉ាអ្វីទាំងអស់ ។ បើសិនជានរណាម្នាក់តវ៉ា នោះនឹងនាំទៅរកសេចក្តីស្លាប់ ។ ជាមួយគ្នានោះដែរ មេដឹកនាំខ្មែរក្រហមបានបង្ខំប្រជាជនកម្ពុជាឲ្យនិយាយភូតភរអំពីអត្តសញ្ញាណរបស់ខ្លួន និងអំពីអ្នកផ្សេងទៀតដើម្បីឲ្យសមស្របទៅនិងរបបដ៏ឃោរឃៅរបស់ខ្លួន ។ តើមេដឹកនាំខ្មែរក្រហមយល់ពីអត្ថន័យនៃការផ្លាស់ប្តូរនិងការអភិវឌ្ឍនៅក្នុងសង្គមប្រជាធិបតេយ្យដែរឬទេ?

ឥឡូវនេះ មេដឹកនាំខ្មែរក្រហមនិយាយអំពីការបង្រួបបង្រួមជាតិ និយាយពីការចង់បានដ៏ខ្លាំងនូវសន្តិភាពនិងការអភិវឌ្ឍ និងនិយាយពីការដោះស្រាយភាពក្រីក្រជូនប្រជាជន និងនិយាយថាខ្លួនកំពុងស្វែងរកការពិត ។ ការនិយាយដោយឥតអៀនខ្មាសបែបនេះពីក្រុមមនុស្សដែលបង្កឲ្យមានការខូចខាំដល់ប្រទេសកម្ពុជាមិនមានការយល់ដឹងអ្វីទេ ។ តើយើងអាចបង្រួបបង្រួមជាមួយមនុស្សដែលសម្លាប់សមាជិកគ្រួសាររបស់យើងដោយគ្មានជំនុំជម្រះទោសបានដែរឬទេ? តើ «សន្តិភាព» ប្រភេទណាដែលអាច «បង្កើតឡើង» នៅក្នុងប្រទេសមួយដែលបញ្ហាទាំងអស់មិនទាន់បានដោះស្រាយនោះ? តើរបបខ្មែរក្រហមមានដែលចង់បង្រួបបង្រួមជាមួយនឹងអ្នកដែល «ធ្លាប់បម្រើ» ការនៅក្នុងរបបមុនៗឬសមាជិកគ្រួសាររបស់អ្នកទាំងនោះ ឬអ្នកដែលធ្លាប់រស់នៅក្នុងទីក្រុងជានិស្សិត ឬជាពាណិជ្ជករដែរឬទេ? តើឯណាទៅពាក្យដែលមេដឹកនាំទាំងនោះនិយាយថា «រឿងដែលកន្លងហួសឲ្យវាហួសទៅចុះ» នោះ? តើត្រង់ណាទៅដែលមេដឹកនាំខ្មែរក្រហមចង់បង្រួបបង្រួមជាតិនិងការអភិវឌ្ឍនោះ? មេដឹកនាំខ្មែរក្រហមនិយាយពីការអភិវឌ្ឍនិងក្រោយមកបានកាត់ផ្តាច់ប្រទេសរបស់ខ្លួនចេញពីប្រទេសផ្សេងទៀតនៅលើសកលលោក ធ្វើឲ្យប្រជាជនកម្ពុជាធ្វើការដ៏លំបាកលំបិននៅក្នុងវាលស្រែដោយគ្មានអាហារហូបចុកគ្រប់គ្រាន់ និងគ្មានថ្នាំព្យាបាល ។ តើអ្វីទៅដែលបានកើតឡើងអំឡុងពេលរបបខ្មែរក្រហមដែលមេដឹកនាំទាំងនោះមិនចង់ឲ្យពិភពខាងក្រៅឃើញហើយដែលខ្លួនបដិសេធថាមិនបានដឹងពូរឿងរ៉ាវទាំងអស់នោះមកដល់ពេលនេះ?

មេដឹកនាំខ្មែរក្រហមបាននិយាយអំពីការដោះស្រាយភាពក្រីក្រនិងគ្រោះអត់ឃ្លាន ។ តើហេតុអ្វីបានជាយើងមិនមានទីជម្រកត្រឹមត្រូវ និងសម្លៀកបំពាក់គ្រប់គ្រាន់ដើម្បីស្លៀកពាក់ អាហារគ្រាប់គ្រាន់ដើម្បីហូបចុកកាលពីសម័យខ្មែរក្រហមខណៈពេលដែលមេដឹកនាំខ្មែរក្រហមបានកំពុងនាំចេញនូវធនធានរបស់ជាតិយ៉ាងច្រើនសន្ធឹកសន្ធាប់ដូចជាមាសនិងស្រូវទៅបរទេស ។ មេដឹកនាំទាំងនោះប្រហែលជារវល់នឹងសម្លាប់អ្នកទោសប្រហែលជា ៥២០០នាក់ក្នុងមួយសប្តាហ៍ៗនៃការកាន់អំណាចរយៈពេលជិតបួនឆ្នាំរបស់ខ្លួន ហើយមិនបានខ្វល់ពីប្រជាជនរាប់លាននាក់ទៀតដែលបានស្លាប់ដោយការអត់អាហារនិងថ្នាំពេទ្យ ។

មេដឹកនាំខ្មែរក្រហមនៅតែបដិសេធអំពីការដឹងពូនៃការសម្លាប់ក្រោមរបបរបស់ខ្លួន ។ ក្នុងកាលៈទេសៈបែបនេះ តើយើងគួរជឿ ខៀវ សំផន និងមេដឹកនាំដទៃទៀតឬទេ? តើមេដឹកនាំទាំងនោះសម្លឹងមើលព្រះនេត្រព្រះពុទ្ធដែរឬទេនៅពេលដែលអ្នកទាំងនោះកំពុងបួងសួងដល់ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ? តើមេដឹកនាំទាំងនោះសម្តែងការគោរពចំពោះព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃដែរឬទេនៅពេលដែលខ្លួនជួបព្រះសង្ឃ? តើមេដឹកនាំទាំងនោះបួងសួងសុំឲ្យមានការអភ័យទោសពីជនរងគ្រោះរបស់ខ្លួនដែរឬទេ?

**ឆាំង យុ**

# ពេលវេលាមួយនៃតម្លាភាព "មិនមែនជាស្រោមសំបុត្របិទជិតទេ"

សវនាការបឋមចំនួនបួនថ្ងៃនៃសំណុំរឿង០០២នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចាប់ផ្តើមនៅថ្ងៃនេះ ។ លោកឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ស៊ីហ៊ិន រ៉ាហ្ ទទួលបន្ទុកកិច្ចការឧក្រិដ្ឋកម្មសង្គ្រាមបានហៅសវនាការនេះថា «ជាសវនាការសំខាន់បំផុតនៅក្នុងពិភពលោក» ។

ជនត្រូវចោទទាំងបួននៅក្នុងសំណុំរឿង០០២គឺជាមេដឹកនាំជាន់ខ្ពស់បំផុតនៃរបបខ្មែរក្រហមដែលនៅរស់ ។ ជនត្រូវចោទទាំងនោះរួមមាន នួន ជា ដែលមានតួនាទីជាអនុលេខាបក្ស និងត្រូវបានស្គាល់ជា «បងធំទី២» ខៀវ សំផន ដែលជាគណៈប្រធានរដ្ឋកម្ពុជាប្រជាធិបតេយ្យ អៀង សារី ឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងការបរទេស និង អៀង ធីរិទ្ធ ដែលជារដ្ឋមន្ត្រីសង្គមកិច្ច ។ ជនត្រូវចោទទាំងបួនត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អំពើប្រល័យពូជសាសន៍ ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាក្រុងហ្សឺណែវឆ្នាំ១៩៤៩ និងបទល្មើសក្នុងស្រុកមួយចំនួនទៀតនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ។

ប្រជាជនកម្ពុជានិងជនបរទេសជាច្រើនយល់ឃើញដូចគ្នាថា សវនាការនៅថ្ងៃដំបូងដែលមានលក្ខណៈរស់រវើកនិងគួរឲ្យចង់មើលបានជជែកដេញដោលពីបញ្ហាមួយចំនួនដែលរួមមានចំណុចមួយចំនួនដែលមិនមានរួមបញ្ចូលនៅក្នុងរបៀបវារៈដូវការរបស់តុលាការ ។ សាធារណជននៅក្នុងបន្ទប់សវនាការរួមមាន ប្រជាជនចាមមូស្លីម និស្សិតមហាវិទ្យាល័យ និងអ្នកសង្កេតការណ៍បរទេស ព្រមទាំងព្រះសង្ឃ និងដូនជីជាច្រើនដែលអង្គុយនៅពេញកៅអីពីរជួរនៅក្នុងសវនាការនៅពេលព្រឹក ។

នៅពេលវាំងននដែលបាំងបន្ទប់សវនាការត្រូវបានទាញចេញ សាធារណជនមើលឃើញមុនគេគឺជនត្រូវចោទទាំងបួនដែលអង្គុយនៅខាងឆ្វេងដៃនៃចៅក្រមនិងនៅពីក្រោយមេធាវីការពារក្តីរបស់ខ្លួន ។ នួន ជា ពាក់មួកចាក់ពណ៌ខ្មៅ វ៉ែនតាខ្មៅ និងអាវធំខ្មៅខាងក្រៅដ៏ចម្លែកនៅក្នុងបន្ទប់សវនាការដែលមានអាកាសធាតុក្តៅនិងមានបើកម៉ាស៊ីនត្រជាក់បន្ថយកំដៅ ហើយសាធារណជនជាច្រើនយកចិត្តប័ណ្ណផ្សព្វផ្សាយព័ត៌មានរបស់សាលាក្តីខ្មែរក្រហមមកបក់ ។

ជនត្រូវចោទទាំងបួនបានចាប់ផ្តើមចូលរួមក្នុងសវនាការដោយយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើប្រធានអង្គជំនុំជម្រះ និល ណុន ដែលបានប្រាប់ជនត្រូវចោទទាំងបួនពីបទល្មើសដែលអ្នកទាំងនោះត្រូវបានចោទប្រកាន់ ។ លោកប្រធាន និល ណុន បានរៀបចំរបៀបវារៈសវនាការសម្រាប់ថ្ងៃបន្តបន្ទាប់ គឺថ្ងៃទីមួយសម្រាប់បែងចែកបញ្ជីឈ្មោះបណ្តោះអាសន្នរបស់សាក្សី និងការបដិសេធជាបឋមទៅលើគោលការណ៍ស្តីពីការជំនុំជម្រះរឿងក្តីមួយតែមួយលើក និងបញ្ហាអភ័យឯកសិទ្ធិឬការលើកលែងទោស ។ ខណៈពេលដែលពេលវេលាដើរទៅមុខ វាមានលក្ខណៈច្បាស់លាស់ថាភាគីទាំងអស់មានបញ្ហាបែងចែកពេលវេលាឲ្យស្របនឹងរបៀបវារៈដែលបានព្រាងទុក ដូច្នេះតុលាការត្រូវរុញបញ្ហាអភ័យឯកសិទ្ធិឬការលើកលែងទោសទៅថ្ងៃបន្ទាប់វិញ ។

### ដំណើរសវនាការ

លោកប្រធាន និល ណុន បានប្រកាសពីដំណើរការសវនាការដែលបានព្រាងទុកមុនសម្រាប់ឲ្យភាគីទាំងអស់ ។ ដំណើរការដែលអង្គជំនុំជម្រះនឹងដំណើរការទៅនៅក្នុងបទបង្ហាញភស្តុតាងគឺ ៖

១) រចនាសម្ព័ន្ធនៃរបបកម្ពុជាប្រជាធិបតេយ្យ

២) តួនាទីរបស់ជនត្រូវចោទម្នាក់ៗ នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា

៣) តួនាទីរបស់ជនត្រូវចោទម្នាក់ៗ ពោលគឺការទទួលខុសត្រូវរបស់អ្នកទាំងនោះ និងមាគ៌ាទំនាក់ទំនងជាមួយកម្ពុជាប្រជាធិបតេយ្យ

៨) គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាស្តីពីបញ្ហាដែលបានលើកឡើងនៅក្នុងអង្គជំនុំជម្រះ ។

យោងទៅតាមគម្រោងនេះ ភាគីបានផ្តល់បញ្ជីស្នើឈ្មោះសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញទៅឲ្យអង្គជំនុំជម្រះតាំងពីមុនដែលធ្វើឲ្យអង្គជំនុំជម្រះអាចកំណត់បញ្ជីឈ្មោះសាក្សីបណ្តោះអាសន្ន ។ បញ្ជីនេះត្រូវបានចែកឲ្យគ្រប់ភាគី ប៉ុន្តែលោកប្រធាន និល ណុន បានប្រកាសថា ការជជែកដេញដោលផ្ទាល់មាត់នឹងត្រូវប្រព្រឹត្តទៅនៅចុងសវនាការបឋមគឺនៅថ្ងៃព្រហស្បតិ៍ទី៣០ ខែមិថុនា ។

**ការផ្លាស់ប្តូររបៀបវារៈ**

បន្ទាប់ពីមានការចែកបញ្ជីសាក្សីបណ្តោះអាសន្នរួច សុន អារុណ ដែលជាសហមេធាវីការពារក្តីកម្ពុជារបស់ នួន ជា បានក្រោកឡើងនិយាយទៅកាន់អង្គជំនុំជម្រះ ។ សំណើទីមួយរបស់លោកបានផ្លាស់ប្តូររបៀបវារៈដែលអង្គជំនុំជម្រះបានរៀបចំ ។ លោក សុន អារុណ បានលើកឡើងពីលិខិតដែលលោកបានផ្ញើជូនអង្គជំនុំជម្រះដោយស្នើថា គុរបស់សហមេធាវីរបស់ នួន ជា គួរតែដាក់ឲ្យស្របជាមួយសហមេធាវីទាំងបីដើម្បីឲ្យសហមេធាវីទាំងអស់មានភាពងាយស្រួលក្នុងការអង្គុយ ហើយ នួន ជា ក៏អាចទទួលបាន «សិទ្ធិស្មើគ្នាដូចភាគីដទៃទៀតដែរ» ។ ដោយលើកឡើងពីបញ្ហានៃការគោរព លោក សុន អារុណ បានប្រកាសថា «ប្រសិនបើស្ថានភាពដដែលនៅតែបន្ត នោះយើងនឹងមានបញ្ហាក្នុងការធ្វើការជាមួយកូនក្តីរបស់យើង» ។ លោកប្រធាន និល ណុន បានឆ្លើយតបយ៉ាងលឿនទៅកាន់លោក សុន អារុណ ថា រឿងគុមិនមែនជាបញ្ហាព្រួយបារម្ភធំទេ ហើយវានឹងត្រូវបានដោះស្រាយយ៉ាងលឿនបំផុត ។

មុនពេលដែលអង្គជំនុំជម្រះដំណើរការទៅមុខតាមរបៀបវារៈ លោក អារុណ បានបន្តសំណើរបស់លោកទៅដល់ប្រធានបទដែលប្រហែលជាមានលក្ខណៈសំខាន់ជាងគេ គឺបញ្ហាវ័យចំណាស់របស់ជនត្រូវចោទដែលនឹងបន្តរហូតដល់ពេលថ្ងៃ ។ ការពិភាក្សាពីវ័យរបស់ជនត្រូវចោទដែលមានអាយុពី៧៩ ដល់៨៥ឆ្នាំបានចាប់ផ្តើមភ្លាមៗបន្ទាប់ពីអង្គជំនុំជម្រះបានចេញបញ្ជា និងបន្តសវនាការដល់ពេលថ្ងៃ ។ នោះគឺជាការពិភាក្សាទៅលើលទ្ធភាពរបស់អង្គជំនុំជម្រះក្នុងការតម្រូវឲ្យជនត្រូវចោទចូលរួមក្នុងសវនាការនៅពេលដែលជននោះមានការពិបាកក្នុងការចូលរួម ។



ស៊ីហ៊ិន រ៉ាហ្



ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ខារ៉ូល ដលី



អាល់ រ៉ុកខហ្

លោកប្រធាន និល ណុន បានកំណត់ដំណាក់កាលសម្រាប់ការពិភាក្សាដោយប្រកាសថា «ដើម្បីសម្រួលដល់ដំណើរការនីតិវិធី និងជនត្រូវចោទមានវ័យចំណាស់» ត្រូវបិទវាំងននទៅជុំវិញបន្ទប់សវនាការនៅពេលដែលចៅក្រមចាកចេញពីកន្លែងអង្គុយ ។ បន្ទាប់មកអង្គជំនុំជម្រះបានប្រកាសថា ជនត្រូវចោទអាចចាកចេញពីបន្ទប់សវនាការ ដោយមានអ្នកបណ្តើរដើម្បីសម្រាកនៅគ្រប់ពេលដោយមិនចាំបាច់ស្នើសុំទៅអង្គជំនុំជម្រះឡើយ ។ នេះជាជម្រើសដែល អៀង សារី បានប្រើប្រាស់ គឺចាកចេញពីបន្ទប់សវនាការដោយមានការជួយគ្រាហ៍ពីសន្តិសុខនៅអំឡុងពេលសវនាការនៅពេលព្រឹក ។

ការទទួលស្គាល់វ័យចំណាស់របស់ជនត្រូវចោទធ្វើឲ្យ សុន អារុណ ដែលជាមេធាវីការពារក្តីរបស់ នួន ជា ស្នើឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យ នួន ជា ពាក់មួកចាក់ដើម្បីទប់នឹងខ្យល់ម៉ាស៊ីនត្រជាក់ និងពាក់វ៉ែនតាខ្មៅដើម្បីការពារពន្លឺ ដោយសារតែគាត់ «មានវ័យចំណាស់និងសុខភាពទ្រុឌទ្រោម» ។ អង្គជំនុំជម្រះបានយល់ស្របនឹងសំណើទាំងនេះ ។ បន្ទាប់មក លោក អារុណ បានស្នើទៅអង្គជំនុំជម្រះអនុញ្ញាតឲ្យ នួន ជា អាចនិយាយដោយអង្គុយពីព្រោះគាត់មានបញ្ហាពិបាកនឹងក្រោកឈរ ។

ភ្លាមៗបន្ទាប់ពីអង្គជំនុំជម្រះអនុញ្ញាតសំណើនេះ សាធារណជនបានអង្គុយផ្អែកខ្នងនឹងកៅអីដើម្បីស្តាប់ជនត្រូវចោទម្នាក់ឡើងនិយាយ ។ នួន ជា បានប្រកាសថា «ខ្ញុំមិនសប្បាយចិត្តនឹងសវនាការនេះទេ ខ្ញុំចង់ឲ្យសហមេធាវីរបស់ខ្ញុំបកស្រាយពីហេតុផលនេះ» ។ សេចក្តីថ្លែងការណ៍របស់ នួន ជា ធ្វើឲ្យអ្នកចូលរួមក្នុងសវនាការខ្លះអស់សង្ឃឹមដោយអង្គុយផ្អែកនឹងកៅអី ហើយអ្នកខ្លះអង្គុយផ្អែកដោយមានពាក់ប្រដាប់ស្តាប់សំឡេង ។ លោកប្រធាន និល ណុន ដែលហាក់ដូចជាអស់ភាពអត់ធ្មត់បានបដិសេធនឹងសំណើរបស់ នួន ជា ដែលឲ្យសហមេធាវីរបស់ខ្លួននិយាយពីការមិនពេញចិត្តរបស់គាត់ ពីព្រោះវាស្ថិតនៅក្រៅបរិបទរបស់សវនាការបឋម ។

## ការប្រានចោលដោយ នួន ជា

ដើម្បីជាការឆ្លើយតប ម៉ៃឃើល ផេស្តមេន ដែលជាសហមេធាវីអន្តរជាតិរបស់ នួន ជា បានក្រោកឈរឡើងយ៉ាងលឿនដើម្បីសុំអនុញ្ញាតលើកឡើងពីចំណុចមួយនៃលំដាប់លំដោយរបៀបវារៈ ។ បន្ទាប់ពីអង្គជំនុំជម្រះអនុញ្ញាតឲ្យ ម៉ៃឃើល ផេស្តមេន





សាស្ត្រាចារ្យ អាឡិច ហ៊ីនតុន



អតីតអ្នកទោស[illegible] ស-២១ ជុំ ម[illegible]

បន្ត វាហាក់ដូចជាមានលក្ខណៈច្បាស់ថា «លំដាប់លំដោយ» ដែលលោកបានលើកឡើងនោះគឺដើម្បីប្រឆាំងនឹងការបដិសេធរបស់អង្គជំនុំជម្រះទៅលើសំណើរបស់ នួន ជា ។ ម៉ៃឃើល ជេស្តមេន បានលើកឡើងថា ជនត្រូវចោទបានផ្តល់ឈ្មោះសាក្សី ៣០០នាក់ទៅឲ្យអង្គជំនុំជម្រះ ។ ប៉ុន្តែ ក្រោយមកលោកបានលើកឡើងថា «យើងឆ្ងល់ថាហេតុអ្វីយើងត្រូវរំខាន» បើអង្គជំនុំជម្រះបានផ្ញើរបៀបវារៈដែលនឹងមិនមានលើកឡើងពីការបដិសេធសាក្សីជាក់លាក់មួយចំនួន ។ លោកបានពន្យល់ថា កូនក្តីរបស់គាត់ជឿថា គាត់មានសិទ្ធិបដិសេធជាបឋមទៅលើការមិនរួមបញ្ចូលសាក្សី និងពន្យល់ថាហេតុអ្វីបានជាសាក្សីដែលគាត់បានផ្តល់ឲ្យអង្គជំនុំជម្រះមានសារសំខាន់សម្រាប់ការជំនុំជម្រះ ។

ជាជាងអនុញ្ញាតឲ្យអង្គជំនុំជម្រះឆ្លើយតប លោក ជេស្តមេន បានវាយប្រហារទៅលើការស៊ើបអង្កេតដោយយុត្តិធម៌សម្រាប់ដំណើរការនីតិវិធីដោយលើកឡើងថា ការស៊ើបអង្កេត និងការមិនទទួលស្គាល់របស់អង្គជំនុំជម្រះទៅលើសិទ្ធិបដិសេធរបស់ជនត្រូវចោទទៅលើការស៊ើបអង្កេតគឺ «មិនមានភាពយុត្តិធម៌ និងផ្តល់ផលអាក្រក់ដល់សិទ្ធិរបស់កូនក្តីខ្ញុំ ។ ហេតុនេះហើយ សវនាការគួរតែបញ្ចប់» ។ លោកបានបង្ហាញពីការយល់ស្របនឹងការមិនពេញចិត្តរបស់ព្រះរាជអាជ្ញាទៅលើការរារាំងមិនឲ្យមានការស៊ើបអង្កេតពាក់ព័ន្ធសំណុំរឿង០០៣ និង០០៤ និងលើកឡើងថា នួន ជា បានស្នើ២៦ដងឲ្យមានវិធានការស៊ើបអង្កេត ប៉ុន្តែចៅក្រមស៊ើបអង្កេតមិនអើពើនឹងសំណើនោះសោះ ។ លោក ជេស្តមេន បានសួរថា «ហេតុអ្វីបានជាមិនមានការស៊ើបអង្កេតទៅលើការទម្លាក់គ្រាប់បែកដ៏សាហាវរបស់សហរដ្ឋអាមេរិក?» «ហេតុអ្វីបានជាមិនមានការស៊ើបអង្កេតទៅលើតួនាទីរបស់វៀតណាមនៅកម្ពុជា?» «តើតុលាការនេះមានបំណងចង់កប់ប្រវត្តិសាស្ត្រឬ?»

លោក ជេស្តមេន បានធ្វើសេចក្តីសន្និដ្ឋានទៅលើពាក្យសម្តីខ្លួនដោយលើកឡើងថា «ការជំនុំជម្រះក្តីគឺប្រៀបដូចជាការសាងសង់ផ្ទះមួយ វាត្រូវការមូលដ្ឋានត្រឹមត្រូវ បើពុំដូច្នោះទេ វានឹងរលំជាមិនខាន ។ ប្រសិនបើតុលាការមិនមែនជាតុលាការដែលមានតែឈ្មោះទេ តុលាការគួរតែចាប់ផ្តើមបង្ហាញធ្មេញរបស់ខ្លួន» ។ លោក ជេស្តមេន បានស្នើឲ្យមានការពិភាក្សាពេញលេញទៅអ្វីដែលលោកហៅថា «ការស៊ើបអង្កេតដោយសម្ងាត់» ប្រឆាំងនឹងកូនក្តីរបស់លោក ដោយស្នើឲ្យពេលវេលាមួយមានតម្លាភាពគឺមិនមែនជាស្រោមសំបុត្រដែលបិទជិតទេ» ។ បន្ទាប់មក លោក ជេស្តមេន បានប្រកាសថា កូនក្តីរបស់ខ្លួនមិនអាចទទួលការបង្ខំឲ្យនៅក្នុងសវនាការទេ គាត់នឹងចាកចេញពីបន្ទប់សវនាការ ហើយគាត់នឹងត្រឡប់មកវិញនៅពេលដែលតុលាការទទួលស្គាល់ការបដិសេធរបស់គាត់ ។

លោកប្រធាន និល ណុន បានឆ្លើយតបដោយខឹងសម្បាទៅលើពាក្យសម្តីរបស់លោក ជេស្តមេន ថា «អង្គជំនុំជម្រះនឹងមិនអនុញ្ញាតឲ្យមានការរំខានបែបនេះទៀតឡើយ» ។ នៅពេលដែលលោកចង់បន្តតាមរបៀបវារៈរបស់ខ្លួន នួន ជា បានក្រោកចេញពីកន្លែងអង្គុយដោយមានសន្តិសុខពីរនាក់ជួយ ។ បន្ទាប់ពីទទួលការយល់ស្របពីតុលាការ ជនត្រូវចោទបានស្នើសុំចាកចេញពីបន្ទប់សវនាការ ហើយនឹងត្រឡប់មកវិញនៅពេលដែលតុលាការយល់ព្រមពិចារណាទៅលើការបដិសេធរបស់គាត់ ។ លោកប្រធាន និល ណុន បានអនុញ្ញាតសំណើនោះ និងណែនាំឲ្យសន្តិសុខនាំជនត្រូវចោទត្រឡប់ទៅមន្ទីរឃុំឃាំង ។ នួន ជា មិនបានត្រឡប់មកបន្ទប់សវនាការវិញឡើយ ។

## ការពិភាក្សាទៅលើបញ្ជីឈ្មោះបណ្តោះអាសន្នរបស់សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ

បន្ទាប់ពី នួន ជា ចាកចេញពីបន្ទប់សវនាការ លោកប្រធាន និល ណុន បានទាញការចាប់អារម្មណ៍របស់អង្គជំនុំជម្រះទៅតាមរបៀបវារៈវិញ ដោយចាប់ផ្តើមពិភាក្សាពីបញ្ជីដើមបណ្តឹងរដ្ឋប្បវេណី ។ អេលីហ្សាប៊ែត ស៊ីម៉ូណូ ហ្វុត ដែលជាសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីនាំមុខបានស្នើសុំឱកាសដើម្បីបកស្រាយពីហេតុផលដែលខ្លួនមិនបានផ្តល់បញ្ជីឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីនៅពេលចាប់ផ្តើមសវនាការ ។ លោកស្រី ស៊ីម៉ូណូ ហ្វុត បានលើកឡើងពីសេក្តីសម្រេចចុងក្រោយនៅថ្ងៃសុក្រទី២៤ ខែមិថុនា របស់អង្គបុរេជំនុំជម្រះដែលសម្រេចឲ្យមានលក្ខណៈវិនិច្ឆ័យទូលាយក្នុងការទទួលស្គាល់ជនរងគ្រោះ ។ អាស្រ័យហេតុនេះទើបធ្វើឲ្យមានចំនួនដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០២ កើនឡើងទ្វេជាពីរគឺមានសរុប៣៨៥០នាក់ ។

តុលាការបានបដិសេធសំណើសុំការបកស្រាយ ដោយអះអាងថាការពិភាក្សាមានលក្ខណៈសមរម្យជាងសម្រាប់បិទសវនាការ ។ ការលើកឡើងរបស់តុលាការធ្វើឲ្យមានការឆ្លើយតបជាច្រើនពីភាគីទាក់ទងនឹងបញ្ហាថាតើគួរតែពិភាក្សាបញ្ជីសាក្សីនៅក្នុងសវនាការសាធារណៈឬដោយសម្ងាត់? ម៉ៃឃើល ខារណាវ៉ាស ដែលជាសហមេធាវីការពារក្តីអន្តរជាតិរបស់ អៀង សារី បានអះអាងថា ការពិភាក្សាទូទៅអំពីថាតើអ្នកណាត្រូវបង្ហាញខ្លួននៅតុលាការគួរតែធ្វើឡើងជាសាធារណៈ បន្ទាប់មកសម្រេចថាតើអ្នកណាត្រូវផ្តល់សក្ខីកម្មនៅក្នុងសវនាការមិនសាធារណៈ ។ លោក ស សូវ៉ាន ដែលជាសហមេធាវីកម្ពុជារបស់ ខៀវ សំផន បានស្នើថាគួរតែពិភាក្សាពីបញ្ជីសាក្សីជាលក្ខណៈមិនសាធារណៈ ពីព្រោះមិនមែនសាក្សីទាំងអស់ដែលស្នើឲ្យដោយកូនក្តីរបស់លោកមានឈ្មោះក្រៅទេ ។

សហព្រះរាជអាជ្ញាអន្តរជាតិ អេនឌ្រូ ខេលី បានស្នើថាគ្រប់សាក្សីគួរតែមានលេខកូដ ដូច្នេះ បញ្ជីឈ្មោះអាចយកមកពិភាក្សាជាសាធារណៈ ។ លោក ខេលី ក៏បានយកឱកាសនេះដើម្បីទាញការចាប់អារម្មណ៍របស់តុលាការទៅលើឯកសារដែលបានដាក់ដោយព្រះរាជអាជ្ញាថ្មីៗនេះទៅលើសក្ខីកម្មរបស់ជនត្រូវចោទ ដោយស្នើថាបញ្ជីសាក្សីបណ្តោះអាសន្នត្រូវបានយកទៅពិចារណា ហើយជនត្រូវចោទទាំងបួនត្រូវតម្រូវឲ្យផ្តល់សក្ខីកម្មនៅមុខសាក្សី ។ នៅក្នុងសំណើនេះ លោក ខេលី ប្រហែលជាបានលើកឡើងម្តងទៀតពីវិយចំណាស់របស់ជនត្រូវចោទដើម្បីធានាថាតុលាការអាចទទួលបានសក្ខីកម្ម ខណៈពេលដែលជនត្រូវចោទនៅអាចចូលរួមក្នុងសវនាការ ។

លោកស្រី ហ្វូត បានបង្ហាញថា ដើមបណ្តឹងរដ្ឋប្បវេណីមិនមានការបដិសេធអ្វីទៅនឹងបញ្ជីសាក្សីដែលកំពុងតែពិភាក្សាជាសាធារណៈនេះឡើយ ពីព្រោះសាក្សីមួយចំនួនត្រូវបានឲ្យឈ្មោះក្រៅ បន្ទាប់មកលោកស្រីបានធ្វើសេចក្តីសន្និដ្ឋានដោយអះអាងថា ដើមបណ្តឹងរដ្ឋប្បវេណីនឹងដាក់បញ្ជីដើមបណ្តឹងរដ្ឋប្បវេណីដែលកែសម្រួលរួចមិនយូរជាងថ្ងៃព្រហស្បតិ៍ទី៣០ ខែមិថុនាទេ ។ លោកស្រីបានយកចិត្តទុកដាក់ទៅលើបញ្ជីសាក្សីដើម្បីធានាឲ្យមានភាពខុសគ្នារវាងតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីនិងតួនាទីរបស់សាក្សី ។

នៅពេលធ្វើសេចក្តីសន្និដ្ឋានលើការពិភាក្សាទៅលើបញ្ជីឈ្មោះបណ្តោះអាសន្ន លោកប្រធាន និល ណុន បានសង្កត់ធ្ងន់ថា យោងទៅតាមច្បាប់អង្គជំនុំជម្រះនឹងមិនអនុញ្ញាតឲ្យសាក្សីដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកជំនាញផ្តល់សក្ខីកម្មដដែលៗទេ ។ ជាសរុប គ្រប់ភាគីបានដាក់ឈ្មោះសាក្សី និងអ្នកជំនាញចំនួន ១០៥៨នាក់ ។ អង្គជំនុំជម្រះបានបង្ហាញថា អង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មយ៉ាងតិចបំផុត ដើម្បីរក្សាពេលវេលាដ៏មានតម្លៃ ។

**តារាងពេលវេលាសម្រាប់ការបដិសេធបឋម និងការឆ្លើយតបជាលាយលក្ខណ៍អក្សរ**

បន្ទាប់មក លោកប្រធាន និល ណុន បានបន្តរបៀបវារៈដោយពិភាក្សាពីដំណើរការនីតិវិធីដែលបានរៀបចំទុកមុនទាក់ទងនឹងការបដិសេធបឋម ។ លោកបានលើកឡើងថា ការបដិសេធជាបឋមជាក់លាក់មួយចំនួនដូចជាការបដិសេធដែលពាក់ព័ន្ធនឹងបញ្ហាច្បាប់នឹងត្រូវយកទៅពិចារណា ដោយផ្អែកទៅតាមសារណាជាលាយលក្ខណ៍អក្សរប៉ុណ្ណោះ ។ ការបដិសេធទាំងនេះរួមមានប្រធានបទមួយចំនួនដូចជា ១)យុត្តាធិការរបស់សាលាក្តីខ្មែរក្រហមទៅលើបទល្មើសអន្តរជាតិ ២)សហកម្មខក្រិដ្ឋកម្មរួមនិងការទទួលខុសត្រូវរបស់ថ្នាក់លើដែលជាទម្រង់នៃការទទួលខុសត្រូវផ្សេងទៀត ៣)ថាតើតុលាការគួរតែបង្កើតបញ្ហាការរំលោភសេពសន្ថវៈជាខក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាជាងគ្រាន់តែជាខក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងសកម្មភាពអមនុស្សធម៌ផ្សេងទៀតដែរឬទេ និង៤)ថាតើខក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតម្រូវឲ្យមានការភ្ជាប់ទៅរកជម្លោះប្រដាប់អាវុធនៅសាលាក្តីខ្មែរក្រហមដែរឬទេ ។

លោកប្រធាន និល ណុន ក៏បានប្រកាសពីការពន្យារពេលដល់ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១១ សម្រាប់ឲ្យជនត្រូវចោទឆ្លើយតបនឹងសារណាជាក់លាក់មួយចំនួនដែលធ្វើឡើងដោយសហព្រះរាជអាជ្ញា ។ អ្វីដែលសំខាន់ជាងគេនៅក្នុងសារណាទាំងនេះគឺសំណើរបស់សហព្រះរាជអាជ្ញាស្នើឲ្យអង្គជំនុំជម្រះពិចារណាទៅលើសហកម្មខក្រិដ្ឋកម្មរួមបី (ឬសហកម្មខក្រិដ្ឋកម្មរួមដែលត្រូវបានពន្យាត) ថាជាទម្រង់នៃការទទួលខុសត្រូវផ្សេង ។

អង្គជំនុំជម្រះក៏បានត្រឡប់ទៅពិភាក្សាពីប្រធានបទទាក់ទងនឹងវ័យចំណាស់របស់ជនត្រូវចោទដោយភ្ជាប់គារាងពេលវេលាសម្រាប់ការធ្វើរបាយការណ៍ពីអ្នកជំនាញឲ្យស្របទៅនឹងជនត្រូវចោទ ។ ប្រធាន និល ណុន ក៏បានយកពេលវេលាបកស្រាយថា បន្ទប់ឃុំខ្លួននៅសាលាក្តីខ្មែរក្រហមមានប្រព័ន្ធវីដេអូ និងទូរស័ព្ទភ្ជាប់មកបន្ទប់សវនាការ ។ ឧបករណ៍ទាំងនេះកំពុងតែត្រូវបានប្រើប្រាស់បច្ចុប្បន្ន ដូច្នេះ ជនត្រូវចោទអាចជ្រើសឧបករណ៍នេះដើម្បីតាមដាននិងចូលរួមក្នុងសវនាការ ។ លោកប្រធាន និល ណុន ក៏បានលើកឡើងថា ប្រសិនបើជនត្រូវចោទជ្រើសរើសចង់នៅសវនាការ ជនត្រូវចោទនោះអាចចេញពីបន្ទប់សវនាការដោយមានអ្នកកំដរដើម្បីទៅសម្រាកគ្រប់ពេលវេលាដោយមិនចាំបាច់សុំអនុញ្ញាត ។

ការប្រកាសពីការពន្យារពេលឆ្លើយតបនឹងសំណើរបស់សហព្រះរាជអាជ្ញាទៅលើសហកម្មឧក្រិដ្ឋកម្មរួមបីបានធ្វើឲ្យមានការឆ្លើយតបដ៏ក្តៅគគុកពី ម៉ៃឃើល ខាណាវ៉ាស ដែលជាសហមេធាវីរបស់ អៀង សារី ។ ខាណាវ៉ាស បានលើកឡើងថា ខណៈពេលដែលគាត់ស្វាគមន៍រាល់ការពន្យារពេល ដើម្បីឆ្លើយតបនឹងសារណារបស់សហព្រះរាជអាជ្ញា លោកមិនជឿថាវាគ្រប់គ្រាន់សម្រាប់ពន្យារពេលទេ លោកបានស្នើឲ្យអង្គជំនុំជម្រះកំណត់ថ្ងៃដ៏តឹងរ៉ឹងសម្រាប់ឲ្យគ្រប់ភាគីដាក់សារណា ។ លោកបានចោទប្រកាន់សហព្រះរាជអាជ្ញាថា សហព្រះរាជអាជ្ញាចង់នៅរង់ចាំមើលបញ្ហាមួយចំនួនដែលត្រូវបានលើកឡើងនៅតុលាការ និងព្យាយាមចាំឆ្មក់ទៅលើបញ្ហាសហកម្មឧក្រិដ្ឋកម្មរួមបី» ។ បន្ទាប់មក ខាណាវ៉ាស បានលើកឡើងដោយព្រះរាជអាជ្ញាថា «បានព្យាយាមរំខានដល់តុលាការ» ។ ដោយលើកឡើងថាការជំនុំជម្រះនឹងមិនអាចដំណើរការទៅមុខបានរហូតដល់ទម្រង់នៃការទទួលខុសត្រូវត្រូវបានកំណត់ លោក ខាណាវ៉ាស បានធ្វើការសន្និដ្ឋានថា «ប្រជាជនកំពុងតែរង់ចាំមើល ហើយមេធាវីការពារក្តីមិនបានរារាំងអ្វីឡើយ ។ យើងជឿថា ព្រះរាជអាជ្ញាគឺជាអ្នកពន្យារការជំនុំជម្រះ» ។

សហព្រះរាជអាជ្ញា ខេលី បានក្រោកឈរយ៉ាងលឿនដើម្បីឆ្លើយតបនឹងការចោទប្រកាន់ ដោយអះអាងថាសហព្រះរាជអាជ្ញាបានដាក់សំណើឲ្យទាន់ពេលវេលាដែលកំណត់ ។ ដោយធ្វើការវាយប្រហារតបនឹងលោក ខាណាវ៉ាស លោក ខេលី បានឆ្លើយតបថា «ខ្ញុំមានករណីលើកលែងពិសេស ដោយមិនត្រូវទទួលបានការចោទប្រកាន់ពីការពន្យារពេលទេ ។ ពាក្យនេះគឺមិនសមរម្យទេ ហើយក៏នឹងមិនទទួលពាក្យនេះដែរ» ។ បន្ទាប់មក លោក ខេលី ស្នើឲ្យតុលាការណែនាំ លោក ខាណាវ៉ាស កុំឲ្យប្រើប្រាស់ពាក្យបែបនេះម្តងទៀតលើកក្រោយ ។

### លោកប្រធាន និល ណុន ប្រកាសឲ្យសម្រាក

ពេលត្រឡប់មកពីសម្រាកវិញ លោកប្រធាន និល ណុន បានស្នើដល់លោកសហព្រះរាជអាជ្ញា អេនឌ្រូ ខេលី ដើម្បីឲ្យគាត់បន្តសេចក្តីថ្លែងការណ៍របស់គាត់ទៀត ។ មើលទៅហាក់បីដូចជាមានអារម្មណ៍ស្ងប់ជាងកាលពីព្រឹកមិញ លោក ខេលី ទទួលស្គាល់នូវរបៀបវារៈរបស់តុលាការសម្រាប់ថ្ងៃនេះដោយធ្វើការស្នើសម្រាប់ឱកាសក្រោយទៀតដើម្បីឆ្លើយតបទៅនឹងសេចក្តីថ្លែងរបស់ ម៉ៃឃើល ផេស្តមេន កាលពីព្រឹកមិញស្តីអំពីការស៊ើបអង្កេតទៅលើករណី នួន ជា ដើម្បីឲ្យសាធារណជនអាចដឹងពុ «រឿងរ៉ាវទាំងស្រុង» ។ តុលាការបានកត់ត្រាទុកសំណើនេះ ហើយបន្តអង្គសវនាការទៅមុខទៀត ។

ពេលនេះ សហមេធាវីជាតិរបស់ អៀង ធីរិទ្ធ ឈ្មោះ ផាត់ ពៅស៊ាង ស្នើទៅតុលាការដើម្បីឲ្យកូនក្តីរបស់ខ្លួនចាកចេញពីបន្ទប់សវនាការដើម្បីទៅកាន់បន្ទប់ឃុំឃាំងដោយសារសុខភាពរបស់គាត់កាន់តែយ៉ាប់ទៅ ។ ដោយយល់ពីសិទ្ធិរបស់ជនត្រូវចោទថាតើត្រូវចូលរួមក្នុងដំណើរសវនាការប៉ុយ៉ាងណា លោកប្រធាន និល ណុន បានយល់ព្រមទៅនឹងសំណើរបស់មេធាវី ហើយលោកប្រធានបានបង្គាប់ឲ្យសន្តិសុខនាំជនត្រូវចោទ អៀង ធីរិទ្ធ ទៅកាន់បន្ទប់ឃុំឃាំងវិញ ។

មេធាវី ស សូវ៉ាន ក៏បានឡើងថ្លែងទៅកាន់តុលាការទាក់ទងទៅនឹងបំណងរបស់ ខៀវ សំផន ក្នុងការចូលរួមក្នុងដំណើរការសវនាការ ដោយបញ្ជាក់ថា កូនក្តីរបស់ខ្លួន «មានសុខភាពប្រសើរជាង» ជនត្រូវចោទដទៃទៀត ហើយមានបំណងនឹងចូលរួមក្នុងដំណើរការស្វែងរកការពិតនេះ ។ ស សូវ៉ាន បានស្នើដល់តុលាការដើម្បីឲ្យកូនក្តីរបស់ខ្លួនសម្រាកមួយសន្ទុះ ហើយត្រឡប់មកកាន់សវនាការវិញនៅពេលក្រោយ ។ លោកប្រធាន និល ណុន

បានបញ្ជាក់ជាថ្មីម្តងទៀតទៅនឹងអ្វីដែលគាត់បានថ្លែងកាលពីមុន ទាក់ទងទៅនឹងលទ្ធភាពរបស់ជនត្រូវចោទក្នុងការសុំឈប់សម្រាប់នាពេលណាមួយ ។

**ការជំទាស់ជាបឋមទៅលើការមិនឲ្យមានករណីដូចគ្នាកើតឡើងពីរដង**

លោកប្រធាន និល ណុន បានបិទការពិភាក្សាទាក់ទងទៅនឹងបញ្ជីឈ្មោះបណ្តោះអាសន្នរបស់សាក្សី ភាគីបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ហើយបន្តទៅរបៀបវារៈទីពីរបន្តទៀតគឺការជំទាស់ជាបឋមទាក់ទងទៅនឹងដែនដែលកំណត់ដោយច្បាប់នៃការដែលអាចបង្កហានិភ័យដោយជនត្រូវចោទ អៀង សារី ។ ដោយសារពេលវេលាមានកំណត់សម្រាប់ថ្ងៃនេះ តុលាការបានទទូចឲ្យគ្រប់ភាគីទាំងអស់កុំធ្វើសេចក្តីថ្លែងការណ៍ច្រំដែលៗ ពេលដែលភាគីនីមួយៗឡើងនិយាយ ។ ចំណុចនេះមានតែភាគីមួយចំនួនប៉ុណ្ណោះគោរពតាម ហើយភាគីខ្លះបានបញ្ជាក់ហើយបញ្ជាក់ទៀតទាក់ទងទៅនឹងប្រធានបទដដែលៗ ដែលបានបកស្រាយនៅក្នុងសេចក្តីថ្លែងការណ៍រួចហើយ ដោយយកមកនិយាយតែរឿងរ៉ាវដដែលៗសម្រាប់ថ្ងៃនេះ ។

អាង ឧត្តម សហមេធាវីរបស់ អៀង សារី បានចាប់ផ្តើមធ្វើសេចក្តីថ្លែងការណ៍ផ្ទាល់មាត់ ដោយធ្វើការថ្លែងអំណរគុណដល់តុលាការដែលបានផ្តល់ឱកាសដល់ខ្លួនក្នុងការធ្វើសេចក្តីថ្លែងនេះ ។ ជាមួយគ្នានោះដែរ មេធាវីរូបនេះហាក់បីដូចជាខឹងនឹងតុលាការដែរ ហើយបានស្នើដល់តុលាការថា សំណួរមួយចំនួនគួរតែរៀបចំឲ្យមាន «ប្រសិទ្ធភាព» ។ អាង ឧត្តម បានបន្តសេចក្តីថ្លែងការណ៍របស់គាត់ ដោយលើកជាមូលដ្ឋានក្នុងការជំទាស់ទៅនឹងអ្វីដែល អៀង សារី ត្រូវបានយកមកកាត់ទោសម្តងទៀត ។ អាង ឧត្តម បានធ្វើការពន្យល់ថា អៀង សារី ត្រូវបានកាត់ទោសកំបាំងមុខម្តងរួចទៅហើយកាលពីខែសីហា ឆ្នាំ១៩៧៩ ដោយតុលាការបដិវត្តន៍ប្រជាជនក្នុងប្រទេសកម្ពុជាដោយចោទពីបទអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មផ្សេងៗទៀត ។ អៀង សារី ត្រូវបានរកឃើញថាមានទោសហើយត្រូវកាត់ទោសប្រហារជីវិត ហើយទ្រព្យសម្បត្តិរបស់គាត់ត្រូវបានរឹបអូស ។

អាង ឧត្តម បានអះអាងថា តុលាការសព្វថ្ងៃរំលោភបំពានទៅលើទស្សនៈនៃការមិនឲ្យមានករណីដូចគ្នាកើតឡើងពីរដងនៅក្នុង ១) ច្បាប់នៅក្នុងស្រុក ២) កតិកាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ៣) វិធានបែបបទច្បាប់អន្តរជាតិ ។ ទាក់ទងនឹងច្បាប់នៅក្នុងស្រុក អាង ឧត្តម សម្អាងលើមាត្រា៧ នៃក្រមព្រហ្មទណ្ឌកម្ពុជាដែលតម្រូវឲ្យសកម្មភាពឧក្រិដ្ឋបានកើតឡើងហើយកាត់ទោសរួចហើយ ឬត្រូវបានសម្រេចតាមផ្លូវច្បាប់រួចទៅហើយ ។ អាង ឧត្តម បានបញ្ជាក់ផងដែរថា ករណីរបស់ អៀង សារី គឺ «ពិតជា» កាត់ទោសរួចហើយដោយសារករណីនេះទាក់ទងទៅនឹងហេតុការណ៍ពិតដែលត្រូវបានដោះស្រាយក្នុងឆ្នាំ១៩៧៩ ។ អាង ឧត្តម បានច្រានចោលនូវការសម្អាងរបស់សហព្រះរាជអាជ្ញាទៅលើមាត្រា១២ នៃក្រមព្រហ្មទណ្ឌកម្ពុជាដែលមើលទៅហាក់បីដូចជាដាក់ដែនកំណត់ទៅនឹងរឿងរ៉ាវដែលបានកាត់ទោសរួចហើយ ។ អាង ឧត្តម បានបញ្ជាក់ថា ការកំណត់ទៅលើរឿងរ៉ាវដែលបានកាត់ទោសរួចហើយអាចនាំទៅរក «លទ្ធផលមិនសមហេតុផល» ខណៈពេលគោលបំណងនៃរឿងរ៉ាវដែលបានកាត់ទោសរួចហើយធ្វើឡើងដើម្បីការពារនូវការវិនិច្ឆ័យចុងក្រោយ និងដើម្បីជួយបុគ្គលដែលត្រូវចោទប្រកាន់ចៀសផុតពីអារម្មណ៍មួហ្មង ការឈឺចាប់ខាងរាងកាយ និងបញ្ហាថវិកាគ្រួសារដោយសារតែការឡើងតុលាការម្តងទៀត ។ គោលបំណងទាំងនេះមិនបានកំណត់ចំពោះអ្នកដែលស្នើសុំចេញក្រៅពីបន្ទប់សវនាការនោះទេ ។

បន្ទាប់មក អាង ឧត្តម បានងាកមកថ្លែងអំពីការមិនឲ្យមានករណីដូចគ្នាកើតឡើងពីរដងក្រោមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ។ មាត្រា១៤.៧ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយបានថ្លែងថា «គ្មាននរណាម្នាក់អាចយកមកកាត់ទោស ឬទទួលទណ្ឌកម្មម្តងទៀត ដោយបទល្មើសតែមួយដែលត្រូវបានកាត់ទោសហើយនៅក្រោមច្បាប់នៃប្រទេសនីមួយៗនោះទេ» ។ អាង ឧត្តម បានអះអាងថា ទោះបីជាអង្គបុរេជំនុំជម្រះរកឃើញកំហុសខុសពីមុនក៏ដោយ ក៏មាត្រានេះអាចយកមកប្រើប្រាស់បាននៅក្នុងសាលាក្តីខ្មែរក្រហម និងសវនាការថ្មីៗនេះដែរ ព្រោះសាលាក្តីខ្មែរក្រហមគឺជាតុលាការកម្ពុជា ហើយនេះគឺជាកាតព្វកិច្ចរបស់រដ្ឋដែលជាសមាជិករបស់កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដើម្បីគោរពតាម ។

ទីបញ្ចប់ អាង ឧត្តម បានថ្លែងទាក់ទងទៅនឹងវិធានបែបបទអន្តរជាតិ និងករណីសវនាការសព្វថ្ងៃ ។ អាង ឧត្តម បានបញ្ជាក់ថា វិធានទាំងនេះគួរតែពិភាក្សាទៅលើករណីស្រពេចស្រពិលនៃច្បាប់ក្នុងស្រុក ។ នៅពេលដែលក្រមព្រហ្មទណ្ឌកម្ពុជា និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយយកមកប្រើប្រាស់ក្នុងករណីរបស់ អៀង សារី យ៉ាងច្បាស់ក្រឡែត ដូច្នេះគ្មានភាពប្រាកដប្រជាទេថាវិធានបែបបទអន្តរជាតិមិនត្រូវយកមកពិគ្រោះទេ ។ អាង ឧត្តម បានធ្វើសេចក្តីសន្និដ្ឋានចុងក្រោយថា មូលដ្ឋានទាំងបីនេះតម្រូវឲ្យសាលាក្តីខ្មែរក្រហមលុបចោលនូវការចោទប្រកាន់មកលើ អៀង សារី ដែលកំពុងតែចោទប្រកាន់ថ្មីៗនេះ ។

សហមេធាវីម្នាក់ទៀតរបស់ អៀង សារី គឺ ម៉ៃឃើល ខារណាវ៉ាស បានស្រាយបញ្ជាក់ពីអ្វីដែល អាង ឧត្តម ទើបតែនិយាយចប់ ហើយបានបញ្ជាក់ថា សំណើរបស់អង្គបុរេជំនុំជម្រះដែលគ្រប់ភាគីបានសួរថាតើតុលាការឆ្នាំ១៩៧៩ លើករណី អៀង សារី ត្រូវបានធ្វើឡើងក្រោមបទដ្ឋានអន្តរជាតិ ហើយនោះគឺជាតុលាការដ៏សមរម្យដែរឬអត់? ឆ្លើយទៅនឹងសំណួរនេះ ម៉ៃឃើល ខារណាវ៉ាស បានសម្អាងទៅនឹងសេចក្តីសម្រេចនៃការដាក់ទោស អៀង សារី ហើយ ម៉ៃឃើល ខារណាវ៉ាស បានបញ្ជាក់ថា «ភស្តុតាងគឺកំពុងស្ថិតនៅក្នុងចានបន្ថែម» នៃការកាត់ទោសប្រហារជីវិតដែលបានដាក់ចុះ ។ ម៉ៃឃើល ខារណាវ៉ាស បានអះអាងថា បើសិនជា អៀង សារី កំពុងស្ថិតនៅក្នុងតុលាការសព្វថ្ងៃ ឬប្រសិនបើ អៀង សារី នឹងត្រូវកាត់ទោសនាពេលឆាប់ៗនេះ នោះគាត់នឹងត្រូវបានសម្រេចទោស ហើយនៅតែមិនដឹងថានេះគឺជាសេចក្តីសម្រេចចុងក្រោយឬយ៉ាងណា ។

ម៉ៃឃើល ខារណាវ៉ាស បានងាកទៅថ្លែងអំពីការជំទាស់របស់អង្គបុរេជំនុំជម្រះទាក់ទងនឹងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ និងការយករឿងរ៉ាវដែលកាត់ទោសរួចហើយមកនិយាយម្តងទៀតក្នុងសាលាក្តីខ្មែរក្រហម ។ អង្គបុរេជំនុំជម្រះបានសម្រេចចិត្តថា កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយគឺមិនអាចយកមកប្រើប្រាស់បានទេនៅក្នុងករណីនេះពីព្រោះច្បាប់នេះមិនអាច «អនុវត្តឆ្លងប្រទេស» ហើយមានតែឥទ្ធិពលតែទៅលើរដ្ឋដែលជាសមាជិកប៉ុណ្ណោះ ។ ម៉ៃឃើល ខារណាវ៉ាស បានអះអាងថា អង្គបុរេជំនុំជម្រះកំពុងតែធ្វើការដោយខុសឆ្គងដោយមិនបានលើកយក «ការអនុវត្តឆ្លងប្រទេស» មកនិយាយក្នុងបញ្ហានេះ ។ ផ្ទុយទៅវិញ តុលាការឆ្នាំ១៩៧៩ កើតឡើងនៅក្នុងតុលាការកម្ពុជា ហើយករណីដែលកំពុងតែកើតឡើងថ្មីនេះក៏ជាតុលាការកម្ពុជាដែរ ។ តាមការអះអាងបែបនេះ ម៉ៃឃើល ខារណាវ៉ាស បានងាកមកមើលបំណងរបស់ជនត្រូវចោទត្រង់ថា តុលាការខ្មែរក្រហមគឺជាតុលាការជាតិមួយមិនមែនជាតុលាការអន្តរជាតិទេ ។ គាត់បានអះអាងថា តុលាការមិនគួរត្រូវបានអនុញ្ញាតឲ្យធ្វើជាឧបសគ្គចំពោះការកាត់ទោសដោយហៅថា តុលាការខ្មែរក្រហមជាតុលាការអន្តរជាតិទេ ។

ម៉ៃឃើល ខារណាវ៉ាស បានធ្វើការសន្និដ្ឋានថា ការអះអាងមិនឲ្យមានករណីដូចគ្នាកើតឡើងពីរដងរបស់ជនត្រូវចោទដោយបញ្ជាក់អំពីបំណងរបស់សហព្រះរាជអាជ្ញាដែលតុលាការឆ្នាំ១៩៧៩ មិនបានធ្វើសេចក្តីសម្រេចចុងក្រោយដោយសារតែសេចក្តីសម្រេចនោះមិនត្រូវបានត្រួតពិនិត្យដោយតុលាការផ្សេងទៀត ។ ម៉ៃឃើល ខារណាវ៉ាស បាននិយាយថា «ខ្ញុំនឹងមិនរៀបរាប់ប្រាប់តុលាការទេ» ។ នៅពេលដែលតុលាការមួយផ្សេងទៀតមិនមាននៅក្នុងទឹកដីកម្ពុជា «តើសេចក្តីសម្រេចដែលនឹងធ្វើសវនាការមួយត្រូវកាត់ទោសក្នុងរវាងឆ្នាំ១៩៧៩ និងការបង្កើតភ្លាមៗផ្សេងទៀតគឺមិនមានលក្ខណៈចុងក្រោយឬ? នោះជនត្រូវចោទមិនបានប្រើប្រាស់សិទ្ធិពេញលេញទេ? នោះគឺជាផលប៉ះពាល់មួយ» ។ ម៉ៃឃើល ខារណាវ៉ាស បានអះអាងបន្តទៀតថា ការដែលមិនមានតុលាការផ្សេងទៀតកើតមាននៅប្រទេសកម្ពុជាកាលពីឆ្នាំ១៩៧៩ បានជំរុញឲ្យមានការវិវាទថា ការកាត់ក្តី អៀង សារី ដោយតុលាការបដិវត្តន៍ប្រជាជនគឺជាសេចក្តីសម្រេចចុងក្រោយ ។

ក្រោយពេលដែល ម៉ៃឃើល ខារណាវ៉ាស បញ្ចប់ការបកស្រាយផ្ទាល់មាត់របស់ខ្លួន តុលាការក៏ដល់ពេលសម្រាកអាហារថ្ងៃត្រង់ល្មម ។

### ការតម្រូវឲ្យជនត្រូវចោទមានវត្តមានក្នុងអង្គសវនាការ

ក្រោយត្រឡប់មកកាន់អង្គសវនាការវិញបន្ទាប់ពីអាហារថ្ងៃត្រង់ តុលាការបានចាប់ផ្តើមកិច្ចការរបស់ខ្លួនបន្តទៀតនាពេលរសៀលដោយតុលាការបកស្រាយអំពីវត្តមានរបស់ជនត្រូវចោទ

នៅក្នុងបន្ទប់សវនាការក្នុងអំឡុងពេលនៃសវនាការ ដែលចំណុចនេះបង្កឲ្យមានការពិភាក្សាយ៉ាងក្តៅគគុកក្នុងបណ្តាភាគីទាំងអស់ ។

ប្រហែលជាប្រតិកម្មនឹងការច្រានចោលភ្លាមៗទៅនឹងសំណើរបស់ នួន ជា និង អៀង ធីរិទ្ធ កាលពីអំឡុងសវនាការនាពេលព្រឹកមិញ ដែលមើលទៅប្រហែលជាកើតឡើងដោយគ្មានការពិគ្រោះគ្នារវាងប្រធាន និល ណុន និងចៅក្រមផ្សេងទៀត តុលាការបានស្រាយបញ្ជាក់ឡើងវិញអំពីវិធានផ្ទៃក្នុងរបស់សាលាក្តីខ្មែរក្រហមទាក់ទងនឹងបញ្ហានេះ ។ វិធានផ្ទៃក្នុងលេខ ៨១(៣)(៤)(៥) តម្រូវឲ្យមានវត្តមានរបស់ជនត្រូវចោទនៅក្នុងបន្ទប់សវនាការជានិច្ចរាល់ពេលដែលមានសវនាការ ។ វិធាននេះលើកលែងតែជនត្រូវចោទមានបញ្ហាខាងសុខភាពប៉ុណ្ណោះ ប៉ុន្តែតុលាការតម្រូវថា ជនត្រូវចោទត្រូវមានវត្តមានរាល់ព្រឹករាល់ល្ងាច ឬរាល់ថ្ងៃ តែការចូលរួមមិនពេញលេញគ្រាន់តែជាការបណ្តោះអាសន្នប៉ុណ្ណោះមុននឹងត្រូវបាននាំខ្លួនទៅកាន់កន្លែងផ្សេងទៀត ។ តុលាការទទូចឲ្យគ្រប់ភាគីទាំងអស់មានវត្តមានដោយអនុញ្ញាតឲ្យតុលាកាធ្វើការសម្រេចចិត្តថាតើជនត្រូវចោទត្រូវបានលើកលែងដែរឬអត់ ។

ឆ្លើយតបទៅនឹងចំណុចខាងលើ ស សូវ៉ាន បានបកស្រាយថា ក្រុមការពារក្តីរបស់ ខៀវ សំផន «នឹងធ្វើតាមយ៉ាងយកចិត្តទុកដាក់» ។ ស សូវ៉ាន បានបន្តទៀតដោយស្នើទៅតុលាការថា ខៀវ សំផន គួរតែចេញពីបន្ទប់សវនាការសម្រាប់ពេលរសៀលនេះដោយសារតែគាត់អស់កម្លាំងខ្លាំង ហើយដោយសារតែមិនមានអ្វីមកបកស្រាយបន្តទៀតសម្រាប់ថ្ងៃនេះផង ។

ក្រោយពីពិភាក្សាជាមួយចៅក្រមផ្សេងទៀតរួចមក ប្រធាន និល ណុន បានច្រានចោលសំណើរបស់ ស សូវ៉ាន ដោយគូសបញ្ជាក់ថា លក្ខខណ្ឌសុខភាពរបស់ ខៀវ សំផន មិនទាន់មានលក្ខណៈធ្ងន់ធ្ងរទេ ។

ភ្លាមៗនោះដែរ ម៉ៃឃើល ខាណាវ៉ាស ឆ្លើយតបទៅនឹងការបដិសេធនៃសំណើរបស់ ស សូវ៉ាន ដោយបានលើកឡើងអំពីបទពិសោធន៍ការងាររបស់គាត់ជាមួយតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីជាមូលដ្ឋាននៃការអះអាងរបស់ខ្លួនព្រោះថា «ព្រះរាជអាជ្ញាចូលចិត្តលើកយកករណីតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីមកធ្វើជាឧទាហរណ៍» ហើយគាត់បានទទូចឲ្យអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាធ្វើតាមវិធាននោះដែរ ។ នៅឯតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី គ្មាននរណាម្នាក់ត្រូវបានបង្ខំឲ្យមានវត្តមាននៅក្នុងតុលាការនោះទេ ជនត្រូវចោទម្នាក់ៗមានសិទ្ធិសម្រេចអំពីវត្តមានរបស់ខ្លួននៅក្នុងតុលាការ ។ ម៉ៃឃើល ខាណាវ៉ាស បានទទូចឲ្យតុលាការពិចារណាឡើងវិញអំពីគោលនយោបាយថ្មីនេះ ហើយអនុញ្ញាតឲ្យជនត្រូវចោទចុះហត្ថលេខានៅលើក្រដាសដោយបង្ហាញអំពីចិត្តចង់បង្ហាញមុខនៅក្នុងអង្គសវនាការ ។ គាត់បានបញ្ជាក់ទៀតថា ការដែលបង្ខំជនត្រូវចោទឲ្យមានវត្តមាននៅក្នុងអង្គសវនាការ ទោះបីបង្ខំដោយរាងកាយក្តី ផ្លូវចិត្តក្តី នៅពេលដែលជនត្រូវចោទមិនចង់ចូលរួមគឺ «ជាការរំលោភសិទ្ធិនៃការចូលរួមការកាត់ក្តីដោយយុត្តិធម៌ និងជាការរំលោភសិទ្ធិរបស់ជនត្រូវចោទ» ។ ម៉ៃឃើល ខាណាវ៉ាស បានបញ្ចប់ការសន្និដ្ឋានដោយស្នើថា កូនក្តីរបស់ខ្លួនឈ្មោះ អៀង សារី ដែលមានបញ្ហាមិនអាចអង្គុយយូរបានឲ្យចេញពីបន្ទប់សវនាការសម្រាប់ថ្ងៃនេះ ។

សហព្រះរាជអាជ្ញា ខេលី បានឆ្លើយតបទៅនឹងការអះអាងរបស់ ម៉ៃឃើល ខាណាវ៉ាស ដោយបញ្ជាក់ថា រាល់បណ្តាតុលាការអន្តរជាតិទាំងអស់ត្រូវមានតម្រូវការមូលដ្ឋានមួយដែលជនត្រូវចោទត្រូវតែចូលរួមក្នុងដំណើរការកាត់ក្តី ។ ពេលនោះ ខេលី ត្រូវបានកាត់អំឡុងពេលដែលគាត់កំពុងនិយាយ ដោយសហមេធាវីរបស់ អៀង សារី ឈ្មោះ អាង ឧត្តម បានស្នើឲ្យតុលាការធ្វើការសម្រេចចិត្តទាក់ទងទៅនឹងសំណើរបស់សហការីរបស់ខ្លួនគឺ ម៉ៃឃើល ខាណាវ៉ាស ។ ប្រធាន និល ណុល បានទុកចោលការនិយាយបកស្រាយរបស់ អាង ឧត្តម មួយអន្លើ ហើយទទូចឲ្យ ខេលី បកស្រាយបន្តទៀត ។ ខេលី បានទទូចថា ភាពប្រាកដប្រជារបស់តុលាការគឺច្បាស់ណាស់នៅពេលដែលជនត្រូវចោទមិនបានចូលរួម ឬមិនមានវត្តមាននៅក្នុងអង្គសវនាការ ។ ហេតុផលនៃការច្រានចោលត្រូវតែបញ្ជាក់ជាលាយលក្ខណ៍អក្សរ ហើយជនត្រូវចោទត្រូវតែបញ្ជាក់ពីការផ្តល់សិទ្ធិរបស់ខ្លួន ដូច្នេះគាត់អាចមិនមានឱកាសនឹងប្រើប្រាស់ការតវ៉ារបស់គាត់នាពេល

អនាគតទេ ។

ម៉ៃ យើល ខាណាវ៉ាស បានព្យាយាមឆ្លើយតបទៅនឹង ខេលី ដោយលើកដៃ និងចុចប៊ូតុងដើម្បីបើកម៉ៃក្រូហ្វូន ។ ប៉ុន្តែម៉ៃក្រូហ្វូនមិនបានបើកទេ ដែលផ្តល់ឱកាសដល់ប្រធាន និល ណុន អាចកាត់ផ្តាច់ការពិភាក្សានោះបាន ។ ប្រធាន និល ណុន បានបញ្ជាក់ថា តុលាការមិនមែនស្ថិតក្នុងជំហរក្នុងការសម្រេចពីបញ្ហានេះ ហើយថាបញ្ហានេះនឹងលើកយកទៅពិភាក្សានាពេលក្រោយទៀត ។

ម៉ៃ យើល ខាណាវ៉ាស បានធ្វើការស្នើជាចុងក្រោយដោយសុំឲ្យមានការអនុញ្ញាតដល់ អៀង សារី ឲ្យចេញពីបន្ទប់សវនាការ ។ នៅពេលដែលចៅក្រមកំពុងតែពិភាក្សាគ្នា ចៅក្រម ស៊ីលវៀ ខាត់វ្រ៉ាយត៍ បានប្រាប់ ម៉ៃ យើល ខាណាវ៉ាស ដែលកំពុងតែឈរនៅឡើយឲ្យអង្គុយចុះនៅពេលដែលចៅក្រមកំពុងតែពិភាក្សា ។ ចៅក្រម ខាត់វ្រ៉ាយត៍ បាននិយាយថា «សូមផ្តល់សិទ្ធិដល់យើងខ្ញុំផង» ។ ការដែលចៅក្រមប្រាប់ ម៉ៃ យើល ខាណាវ៉ាស ពីកំហុសបែបនេះធ្វើឲ្យមានសំណើចបន្តិចនៅក្នុងបន្ទប់របស់អ្នកចូលរួមអង្គុយដែលជួយសម្រួលភាពតានតឹងនៅក្នុងបន្ទប់សវនាការខ្លះ ។

ងាកមករកបន្ទប់សវនាការវិញ ចៅក្រម ឡាវ៉ែញ បានធ្វើការបកស្រាយបញ្ជាក់ថា តុលាការត្រូវប្រឈមមុខនឹងស្ថានភាពផ្សេងៗចំនួនពីរក្រោមវិធាន៨១ ។ ទីមួយ ពេលដែលជនត្រូវចោទបដិសេធមិនចូលរួម ជនត្រូវចោទអាចប្រើប្រាស់សិទ្ធិតែត្រូវប្រើប្រាស់សិទ្ធិនេះដោយត្រឹមត្រូវនិងតម្លាភាព ។ ក្នុងស្ថានភាពនេះ អង្គជំនុំជម្រះគួរតែត្រូវបានផ្តល់ដំណឹងជាមុនពីសំណាក់ជនត្រូវចោទអំពីស្ថានភាពសុខភាពរបស់ខ្លួនពេលចូលដល់បន្ទប់សវនាការភ្លាម ។ ទីពីរ ពេលដែលជនត្រូវចោទផ្តល់ដំណឹងដល់តុលាការអំពីស្ថានភាពជំងឺរបស់ខ្លួន ជនត្រូវចោទត្រូវនៅឆ្ងាយពីបន្ទប់សវនាការ តែអាចធ្វើបានក្រោយពេលដែលតុលាការដឹងច្បាស់ពីស្ថានភាពទាំងនោះពេញលេញអំពីបញ្ហាសុខភាពនិងមូលដ្ឋាននៃការស្នើសុំ ។

ខាណាវ៉ាស បានឆ្លើយតបទៅចៅក្រមវិញ ដោយដំបូងធ្វើការសុំទោសដល់ចៅក្រមក្នុងពេលដែលខ្លួនបានធ្វើការឆ្កាំឆ្កងកន្លងមក ហើយគាត់បានពន្យល់ថា តាមទម្លាប់នៃយុត្តាធិការផ្លូវច្បាប់របស់ខ្លួន ខ្លួនមិនត្រូវអង្គុយទេបើសិនជាគាត់មិនត្រូវអនុញ្ញាតឲ្យអង្គុយ ។ ចំណុចនេះធ្វើឲ្យសាធារណជនសើចបន្តិចដែរ ។ ក្រោយមក ខាណាវ៉ាស បានបន្តដោយបញ្ជាក់ថា គាត់ក៏មានរបាយការណ៍ផ្នែកវេជ្ជសាស្ត្រទាក់ទងនឹងសុខភាពទន់ខ្សោយរបស់កូនក្តីរបស់ខ្លួនដែរ ហើយ ខាណាវ៉ាស សុខចិត្តបោះបង់ចោលសិទ្ធិក្នុងការមានវត្តមាននៅក្នុងតុលាការជាលាយលក្ខណ៍អក្សរ ។ ប៉ុន្តែ គាត់បានអះអាងបញ្ជាក់ទៀតថា «អៀង សារី កំពុងតែទទួលរងហើយនាពេលឥឡូវនេះ ហើយអង្គការសហប្រជាជាតិបានចំណាយលុយយ៉ាងច្រើនដើម្បីរៀបចំបន្ទប់ឃុំឃាំងនោះ» ហើយគាត់ស្នើថា អៀង សារី ត្រូវចេញពីបន្ទប់សវនាការ ។

ពេលកំពុងស្នើទៅតុលាការ មេធាវីតំណាងភាគីដើមបណ្តឹងរដ្ឋប្បវេណី អេលីហ្សាប៊ែត ស៊ីម៉ូណូ ហ្វុត បានឆ្លើយតបដោយបញ្ជាក់ថា នៅពេលដែលគាត់មើលទៅសេចក្តីសម្រេចរបស់តុលាការ បញ្ហានេះគឺជា «បញ្ហានៃការគោរពចំពោះជនរងគ្រោះនិងភាគីដើមបណ្តឹងរដ្ឋប្បវេណី» ។ ភាគីដើមបណ្តឹងរដ្ឋប្បវេណីខ្លះមានវ័យចំណាស់ហើយ ហើយនៅតែព្យាយាមនឹងមានវត្តមាននៅក្នុងបន្ទប់សវនាការ ដោយសារតែចង់ឃើញជនត្រូវចោទមានវត្តមាននៅក្នុងអង្គសវនាការនេះដែរ ។

បន្ទាប់ពីផ្លាស់ប្តូរយោបល់ជាមួយចៅក្រមផ្សេងទៀតរួចមក ប្រធាន និល ណុន បានឆ្លើយតបទៅនឹងសំណើរបស់ អៀង សារី ឲ្យនៅក្នុងបន្ទប់ឃុំឃាំងសម្រាប់ថ្ងៃនេះ ។ ប៉ុន្តែ គាត់បានបញ្ជាក់ថា តុលាការស្នើដល់ជនត្រូវចោទទាំងអស់ថា ត្រូវមានវត្តមាននៅក្នុងបន្ទប់សវនាការរៀងរាល់ព្រឹក ហើយថា តុលាការនឹងធ្វើការសម្រេចចិត្តថាតើត្រូវអនុញ្ញាតឲ្យត្រឡប់ទៅបន្ទប់ឃុំឃាំងវិញឬយ៉ាងណា ។ ក្រោយពីនិយាយចប់ សន្តិសុខបាននាំ អៀង សារី ចេញពីបន្ទប់សវនាការ ។

## ការមិនឲ្យមានករណីដូចគ្នាកើតឡើងពីរដងនៅតែបន្ត

ក្រោយមក តុលាការបានផ្តល់ឱកាសឲ្យសហព្រះរាជអាជ្ញាឆ្លើយតបទៅនឹងការជំទាស់ជាបឋមរបស់ អៀង សារី ដោយផ្អែកលើការដែលមិនឲ្យមានករណីដូចគ្នាកើតឡើងពីរដង ។ ខេលី បានឆ្លើយតបជាដំបូងទៅនឹងការជំទាស់ និងការស៊ើបអង្កេតដែលលើកឡើងដោយ ម៉ៃ យើល ដេស្តមេន គាំងនាមឲ្យ នួន ជា ។

ដោយចន្លុលទៅកាន់សាធារណជនដែលកំពុងអង្គុយស្តាប់ ខេលី បាននិយាយថា អ្វីៗត្រូវតែធ្វើឡើង «ដើម្បីបុព្វហេតុប្រជាជន» ។ ខេលី បានបញ្ជាក់ទៀតថា ម៉ៃឃើល ដេស្តមេន បានធ្វើខុសស្តីអំពី «ការស៊ើបសង្កេតដោយសម្ងាត់» ដែលជាការខុសពីចរិតលក្ខណៈ ។ ក្រុមរបស់ នួន ជា ត្រូវបានអនុញ្ញាតឲ្យមើលឯកសារអំពីការស៊ើបអង្កេតគ្រប់យ៉ាងទាំងអស់ ។ សំណុំឯកសារទាំងនោះទុកជាការសម្ងាត់សម្រាប់សាធារណជនដោយសារតែតម្រូវការរបស់សាលាក្តីខ្មែរក្រហម ។ ឥឡូវនេះ តុលាការចាប់ផ្តើមហើយ ការស៊ើបអង្កេតទាំងនោះត្រូវតែប្រកាសឲ្យដឹងជាសាធារណៈ ។

ក្រោយនិយាយចប់ ខេលី បានផ្តល់សិទ្ធិនៅឲ្យសហព្រះរាជអាជ្ញារបស់ខ្លួនគឺលោកស្រី ជា លាង បន្តឆ្លើយតបទៅនឹងការតវ៉ាស្តីអំពីការមិនឲ្យមានករណីដូចគ្នាកើតឡើងពីរដង ។ ដោយសម្អាងលើមាត្រា១២ នៃក្រមព្រហ្មទណ្ឌកម្ពុជា ជា លាង បានអះអាងថា ការកាត់ទោស អៀង សារី ក្នុងឆ្នាំ១៩៧៩ មិនបានប៉ះពាល់ដល់ដំណើរការកាត់ទោសនាពេលឥឡូវនេះទេ ។ ពេលដែល អៀង សារី ត្រូវបានកាត់ទោស ហើយតាមមាត្រា១២ មិនមានអ្វីប៉ះពាល់ទេ ។ ជា លាង បានធ្វើការសន្និដ្ឋានអំពីសេចក្តីថ្លែងការណ៍របស់គាត់ដោយឆ្លើយតបនឹងការអះអាងរបស់ជនត្រូវចោទ ។ ដោយទទួលស្គាល់អំពីគោលបំណងនៃការមិនឲ្យមានករណីដូចគ្នាកើតឡើងពីរដង គឺជាការការពារជនត្រូវចោទពីការទទួលរងនូវការដាក់ទោសទណ្ឌលើសពីម្តង ជា លាង បានអះអាងថា ចំណុចនេះមិនប៉ះពាល់ដល់ដំណើរការកាត់ទោសរាល់ថ្ងៃនេះទេ ដោយសារតែគាត់មិនមានវត្តមាននៅក្នុងតុលាការកាលពីឆ្នាំ១៩៧៩ ហើយគាត់ក៏មិនទទួលរងនូវទណ្ឌកម្មអ្វីដែរ ។ ហើយម្យ៉ាងទៀត ករណីថ្មីនេះមិនបានដាក់ អៀង សារី ក្នុងស្ថានភាពលំបាកណាមួយទេ ។

ខេលី បានបន្តឆ្លើយតបដោយការអះអាងពីការជនត្រូវចោទទាក់ទងនឹងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ។ ដោយអះអាងពីការទទួលស្គាល់របស់ខ្លួននៃតុលាការខ្មែរថាមានលក្ខណៈខុសពីតុលាការអន្តរជាតិដទៃទៀត ខេលី បានបញ្ជាក់ថា អង្គបុរេជំនុំជម្រះបានធ្វើការត្រឹមត្រូវ ហើយក្នុងការស្វែងរកឃើញថា គ្មានការការពារជាអន្តរជាតិណាមួយទេក្រោមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ និងពលរដ្ឋសម្រាប់តុលាការអន្តរជាតិ ។

ទីបញ្ចប់ ខេលី បានថ្លែងអះអាងទាក់ទងទៅនឹងវិធានបែបបទអន្តរជាតិដោយបញ្ជាក់ថា រាល់តុលាការអន្តរជាតិទាំងអស់ដែលកើតឡើងថ្មីៗនេះផ្តល់នូវការរាំងស្ទះដល់ការអនុវត្តច្បាប់នៅពេលដែលតុលាការជាតិមួយបានកាត់ទោសបុគ្គលណាម្នាក់រួចទៅហើយពីបទចោទប្រកាន់ដូចគ្នា លើកលែងតែតុលាការក្នុងស្រុកនោះមិនបានគោរពតាមទម្លាប់នៃដំណើរការដែលទទួលស្គាល់ដោយតុលាការអន្តរជាតិរួមទាំងសវនាការដោយតុលាការឯករាជ្យ ។ ករណី អៀង សារី ដែលបានកាត់ទោសក្នុងតុលាការបដិវត្តន៍ប្រជាជនមើលទៅខុសពីតម្រូវការនេះឆ្ងាយណាស់ ហេតុដូច្នេះការមិនឲ្យមានករណីដូចគ្នាកើតឡើងពីរដងមិនអាចយកមកប្រើប្រាស់បានក្នុងករណីសាលាក្តីខ្មែរក្រហមនេះទេ ។ ខេលី បានបញ្ចប់សេចក្តីសន្និដ្ឋានរបស់ខ្លួនដោយស្នើដល់តុលាការឲ្យបដិសេធនូវសំណើដើមរបស់ជនត្រូវចោទ ដោយទទូចដល់តុលាការថា «សូមទុកឲ្យយើងដំណើរការតុលាការទៅមុខទៀត» ។

សវនាការបានបញ្ចប់សម្រាប់ថ្ងៃនេះដោយមានសេចក្តីថ្លែងពីទាក់ទងនឹងការមិនឲ្យមានករណីដូចគ្នាកើតឡើងពីរដងចេញដោយមេធាវីតំណាងភាគីដើមបណ្តឹងរដ្ឋប្បវេណី ។ មេធាវីក្រុមមួយបានអះអាងថា ការមិនឲ្យមានករណីដូចគ្នាកើតឡើងពីរដងមិនអាចយកមកប្រើប្រាស់បានទេក្នុងករណីនេះ ព្រោះការធ្វើដូច្នេះប៉ះពាល់ដល់សិទ្ធិជនរងគ្រោះយ៉ាងខ្លាំង ។

មេធាវីម្នាក់ទៀតបាននិយាយសំដៅទៅ អៀង សារី ដោយផ្ទាល់ទោះបីជាគាត់មិនមានវត្តមានក៏ដោយថា ជនត្រូវចោទខ្លួនឯង «មិនដែលទទួលស្គាល់តុលាការ ឆ្នាំ១៩៧៩» ទេ ។ មេធាវីតំណាងភាគីរដ្ឋប្បវេណីបានទទូចឲ្យតុលាការជំទាស់ការអះអាងរបស់ជនត្រូវចោទ និងជួយ «នាំទៅរកការលុបបំបាត់ភាពក្រៀមក្រំ» សម្រាប់ជនរងគ្រោះ ។

នាសេចក្តីថ្លែងចុងក្រោយនេះ តុលាការបានបញ្ចប់កិច្ចការរបស់ខ្លួនសម្រាប់ថ្ងៃនេះដោយមានកម្មវិធីរបៀបវារៈបណ្តោះអាសន្ន ។ ថ្ងៃទី២៨ស្អែកនេះ តុលាការនឹងពិភាក្សាអំពីការលើកលែងទោស និងការអត់ឱនទោសទាក់ទងនឹងករណី អៀង សារី ។

**គ្រីស្ទីន អ៊ីវេន**




# តើព្រះរាជទានទោស និងការលើកលែងទោស អាចជួយ អៀង សារី បានដែរឬទេ?

ថ្ងៃទីពីរនៃសវនាការបឋមក្នុងសំណុំរឿង០០២នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបាននាំមកនូវភាពអាប់អួរដែលមានភាពប្លែកជាងកាលពីថ្ងៃបើកសវនាការថ្ងៃដំបូងដោយសារតែភាគីទាំងអស់មិនធ្វើការពិភាក្សាប្រកបដោយផ្លែផ្កា និងគិតពីស្ថានភាពជាក់លាក់ណាមួយដែលបានពិភាក្សាជាច្រើនកាលពីថ្ងៃចន្ទម្សិលមិញ ។ ចៅក្រមទាំងអស់ហាក់បីដូចជាអស់ភាពអត់ធ្មត់និងត្រឡប់ការពិភាក្សាទៅតាមរបៀបវារៈ ហើយភាគីទាំងអស់ហាក់បីដូចជារៀបរយរួចជាស្រេចក្នុងការបំពេញកិច្ចការងារដាក់កំណត់ក្នុងការផ្តល់យោបល់ចំពោះវិសាលភាពនៃដំណើរការសម្រាប់ស្ទើរពេញមួយថ្ងៃ ។

ពេញមួយថ្ងៃ បរិយាកាសនៅក្នុងបន្ទប់ដែលអ្នកចូលរួមអង្គុយក៏បានឆ្លុះបញ្ចាំងពីចរិតលក្ខណៈបម្រុងច្រើន ដោយសារតែមានការចំណាយពេលយូរជាងថ្ងៃម្សិលមិញចំពោះអ្នកចូលរួមដើម្បីមកអង្គុយឲ្យពេញនាពេលព្រឹក ហើយអ្នកចូលរួមមិនបានត្រឡប់មកកាន់កន្លែងរបស់ខ្លួនវិញទេ ក្រោយពីឈប់សម្រាកមក ។ ទោះបីជាអ្នកចូលរួមទូទៅកាលពីថ្ងៃច័ន្ទចម្រុះទៅដោយព្រះសង្ឃ ដូនជី អ្នកភូមិមកពីខេត្តនានា និស្សិតមហាវិទ្យាល័យក៏ដោយ ក៏ចំនួនអ្នកសង្កេតការបរទេសមានការធ្លាក់ចុះជាងថ្ងៃម្សិលមិញ ដោយសារតែគំនរកាសស្តាប់ត្រចៀកនៅមានគរច្រើនដែលកាលពីថ្ងៃម្សិលមិញមិនមានច្រើនដូចថ្ងៃនេះទេ ។

ទោះបីជាសេចក្តីសម្រេចកាលពីថ្ងៃច័ន្ទប្រកាសថា ត្រូវតែបិទវាំងននក្នុងបន្ទប់សវនាការខណៈពេលដែលចៅក្រមមិនមានវត្តមាននៅឯកៅអីក៏ដោយ ក៏វាំងននបានបើកឡើងនៅវេលាម៉ោង៩គត់ ដែលមានរយៈពេល១៥នាទីមុននឹងចៅក្រមអញ្ជើញមកដល់ ដែលបញ្ចេញឲ្យឃើញនូវបន្ទប់សវនាការ និងជនជាប់ចោទទៅនឹងបន្ទប់របស់អ្នកចូលរួម ។ អ្នកសង្កេតការខ្លះហាក់បីដូចជាមានការភ្ញាក់ផ្អើលពេលដែលបានឃើញជនជាប់ចោទទាំងបួនមានវត្តមាននៅក្នុងបន្ទប់សវនាការ ជាពិសេសពេលដែលឃើញ នួន ជា ពាក់មួកចាក់ និងវ៉ែនតាខ្មៅដែលបានដើរចេញពីបន្ទប់សវនាការកាលពីថ្ងៃច័ន្ទម្សិលមិញ ហើយបានប្តេជ្ញាចិត្តថានឹងត្រឡប់មកកាន់បន្ទប់សវនាការល្អិកណាមានការកោះហៅពីចៅក្រមប៉ុណ្ណោះ ។ វត្តមានរបស់គាត់នៅថ្ងៃនេះអាចឲ្យដឹងបានថា ការតវ៉ារបស់គាត់កាលពីថ្ងៃម្សិលមិញអាចនឹងមានលក្ខណៈជាការសម្តែងជាជាងការតវ៉ាពិតប្រាកដ ។

នៅវេលាម៉ោង៩ និង១៥នាទី ប្រធានចៅក្រម និល ណុន បានស្នើឲ្យតុលាការទាំងមូលប្រកាសអំពីកាលវិភាគសម្រាប់ការបកស្រាយផ្ទាល់មាត់សម្រាប់ថ្ងៃនេះរួមមាន ១) ការបញ្ចប់នូវការជំទាស់បឋមរបស់ អៀង សារី ទាក់ទងទៅនឹងការមិនយកបទឧក្រិដ្ឋតែមួយមកកាត់ទោសម្តងទៀត ២) ការជំទាស់បឋមរបស់ អៀង សារី ដោយផ្អែកលើការផ្តល់ព្រះរាជទានទោស ហើយនិងការលើកលែងទោស ៣) ការជំទាស់បឋមរបស់ អៀង សារី ទាក់ទងទៅនឹងលក្ខន្តិកៈកំណត់ទាក់ទងទៅនឹងការរំលោភបំពានធ្ងន់ធ្ងរចំពោះអនុសញ្ញាទីក្រុងហ្សឺណែវ និង ៤) ការជំទាស់បឋមដោយភាគីជនជាប់ចោទទាំងបួននាក់ទាក់ទងទៅនឹងដែនកំណត់លក្ខន្តិកៈ ទាក់ទងទៅនឹងបទល្មើសដែលបានចែងនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ ។ ទោះបីជាខិតខំធ្វើតាមកម្មវិធីថ្ងៃនេះក៏ដោយ ក៏តុលាការនៅតែមិនអាចបញ្ចប់នូវអ្វីដែលមាននៅក្នុងរបៀបវារៈសម្រាប់ថ្ងៃនេះដដែល ដោយរុញផ្នែកខ្លះយកទៅពិភាក្សានៅថ្ងៃស្អែកទៀត ។

## **នួន ជា ចេញពីបន្ទប់សវនាការទៀតហើយ**

នៅពេលដែល ម៉ៃឃើល ខាណាវ៉ាស សហមេធាវីរបស់ អៀង សារី រៀបនឹងនិយាយដើម្បីឆ្លើយតបទៅនឹងចម្លើយរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីនិងសហព្រះរាជអាជ្ញាទាក់ទងទៅនឹងបញ្ហាយកបទឧក្រិដ្ឋដដែលមកកាត់ទោសម្តងទៀត ម៉ៃឃើល ខាណាវ៉ាស បានផ្តល់ឱកាសទៅ នួន ជា ដែលបានក្រោកឈរដែរ ។ ប្រហែលជាដឹងថានឹងមានរឿងអ្វីកើតឡើង អ្នកតាមដានមើលដំណើរសវនាការនៅក្នុងបន្ទប់ដែលអ្នកចូលរួមអង្គុយបានអង្គុយនៅស្ងៀម ដោយមិនបង្ហាញចំណាប់អារម្មណ៍អ្វីច្រើនទេទាក់ទងនឹងសវនាការជនជាប់ចោទដូចដែលបានបង្ហាញកាលពីថ្ងៃច័ន្ទ ។ នួន ជា បានប្រកាសថា ដោយសារតែរបៀបវារៈសម្រាប់ថ្ងៃនេះមិនជាប់ពាក់ព័ន្ធទៅនឹងករណីរបស់គាត់ «ខ្ញុំសុំដើរចេញ» ។ ប៉ុន្តែខុសកាលពីថ្ងៃច័ន្ទម្សិលមិញ នួន ជា បានបញ្ជាក់ប្រាប់ថា គាត់នឹងត្រឡប់មកបន្ទប់សវនាការពេលណាដែលតុលាការនិយាយពីករណីរបស់គាត់ ។

ប្រធាន និល ណុន បានឆ្លើយតបថា នេះគឺជាសិទ្ធរបស់ជនជាប់ចោទក្នុងការចង់មានវត្តមាននៅក្នុងបន្ទប់សវនាការឬអត់ ហើយតុលាការនឹងអនុញ្ញាតឲ្យ នួន ជា ចេញពីបន្ទប់សវនាការទៅកាន់បន្ទប់ឃុំឃាំងវិញ ។ នៅពេលដែលសន្តិសុខនាំ នួន ជា ចេញពីបន្ទប់សវនាការ ប្រធាន និល ណុន បានប្រគល់តួនាទីទៅ ម៉ៃឃើល ខាណាវ៉ាស វិញដើម្បីនិយាយត ។

**ការកាត់ទោសពីរដងក្នុងបទល្មើសតែមួយពិភាក្សាបន្តទៀត**

ខាណាវ៉ាស បាននិយាយថា «ថ្ងៃណាមួយភាគីបណ្តឹងរដ្ឋប្បវេណីនឹងមានកំហឹង តែម្សិលមិញមិនមែនជាពេលល្អក្នុងការយករឿងនេះមកនិយាយទេ» ។

ដោយឆ្លើយតបទៅនឹងការអះអាងរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីដែលបានបកស្រាយថា បើសិនជាបញ្ឈប់ដំណើរការប្រឆាំងនឹង អៀង សារី ទាក់ទងទៅនឹងការកាត់ទោសពីរដងក្នុងបទល្មើសតែមួយ នោះគឺជាដកហូតសិទ្ធិជនរងគ្រោះចំពោះការពិត



ម៉ៃឃើល ខាណាវ៉ាស សហមេធាវីអន្តរជាតិរបស់ អៀង សារី

ម៉ៃឃើល ខាណាវ៉ាស ចាប់ផ្តើមឆ្លើយតបទៅនឹងការបកស្រាយផ្ទាល់មាត់ដែលថ្លែងដោយមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលហៅមេធាវីនោះថា «ជាការផ្លាស់ប្តូរនៃសេចក្តីថ្លែងការណ៍ដំបូង និងការអះអាងចុងក្រោយ» ។ ដោយបានហៅចម្លើយរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីថា «មិនមានការបង្អែកលើច្បាប់ត្រឹមត្រូវទេនៅពេលដែលនិយាយពាក់ព័ន្ធដល់ច្បាប់» ។ ម៉ៃឃើល ខាណាវ៉ាស បាននិយាយថា គាត់មិនជំទាស់កាលពីថ្ងៃម្សិលមិញដោយសារតែនោះគឺជាថ្ងៃដំបូងនៃសវនាការ ។ ខាណាវ៉ាស និយាយបែបនេះដោយបញ្ជាក់ថា នៅថ្ងៃអនាគត គាត់នៅតែមិនបោះបង់ចោលនូវការបដិសេធរបស់គាត់ទេ ។

ម៉ៃឃើល ខាណាវ៉ាស បានអះអាងថា «ប្រវត្តិសាស្ត្រពិតមិនអាចនឹងរកឃើញទេនៅក្នុងបន្ទប់សវនាការនេះ...ព្រោះបន្ទប់សវនាការនេះមិនបង្កើតឡើងដើម្បីស្វែងរកប្រវត្តិសាស្ត្រពិតទេ» ។ ចុងក្រោយ ខាណាវ៉ាស បានសន្និដ្ឋានថា ក្តីបារម្ភនេះមិនមែនជាហេតុផលមានសុពលភាពទៀតទេក្នុងការបដិសេធសំណើសុំរបស់ជនជាប់ចោទបែបនេះ ។

ដោយងាកត្រឡប់មកមើលការអះអាងរបស់ព្រះរាជអាជ្ញាវិញ ខាណាវ៉ាស កាលពីដំបូងបានបដិសេធសំណើសុំរបស់ព្រះរាជអាជ្ញាដែលថា អង្គបុរេជំនុំជម្រះបានចាត់ទុកមាត្រា៧នៃក្រមព្រហ្មទណ្ឌកម្ពុជាថាជាការផ្តល់ដោយឯកឯង ។ ដូចដែលសហ

មេធាវីរបស់គាត់ឈ្មោះ អាង ឧត្តម បានស្នើនៅក្នុងការអះអាងរបស់កាលពីថ្ងៃច័ន្ទ ម៉ែឃើល ខារណាវ៉ាស បានទទូចម្តងទៀតឲ្យអង្គជំនុំជម្រះមើលមាត្រា៧នៃក្រមព្រហ្មទណ្ឌកម្ពុជា ហើយចាត់ទុកសំណើសុំរបស់ខ្លួនដើម្បីយកមកដោះស្រាយមុននឹងរកទៅរកមាត្រាផ្សេងបន្ថែមទៀត ។

ម៉ែឃើល ខារណាវ៉ាស បានបញ្ជាក់ថា សេចក្តីថ្លែងការណ៍របស់សហព្រះរាជអាជ្ញាជាតិ ជា លាង ដែលថាការកាត់ទោស អៀង សារី ក្នុងឆ្នាំ១៩៧៩ គឺកាត់ទោសតែអំពើប្រល័យពូជសាសន៍តែមួយមុខគត់ ។ ខារណាវ៉ាស បានប្រកាសដោយបញ្ជាក់ថាការចោទប្រកាន់នោះគឺអាចចំពោះអំពើប្រល័យពូជសាសន៍ ប៉ុន្តែសមាសធាតុនៃការចោទប្រកាន់នោះរួមមានឧក្រិដ្ឋកម្មទាំងអស់ដែល អៀង សារី ត្រូវបានចោទប្រកាន់ដែរនៅពេលឥឡូវនេះ ។ ខារណាវ៉ាស បានប្រកាសថា «ការពិតនៅតែជាការពិត» ។ ខារណាវ៉ាស បានស្នើសុំតុលាការឲ្យពិចារណាទៅលើតារាងមួយដែលខ្លួនបានបង្កើតសម្រាប់អង្គបុរេជំនុំជម្រះ ដោយបង្ហាញថាតើសមភាពនៃបទឧក្រិដ្ឋខុសគ្នា និងស៊ីគ្នាដោយរបៀបណា ។

ក្រោយមកជាថ្មីម្តងទៀត ខារណាវ៉ាស ផ្តោតការពិភាក្សារបស់គាត់ទៅលើបញ្ហាដែលថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាជាតុលាការ «អន្តរជាតិ» ដោយនិយាយយ៉ាងច្បាស់ថាបញ្ហានេះនៅតែបន្តជាចំណុចដ៏សំខាន់មួយពេញអង្គសវនាការ ។ ជាថ្មីម្តងទៀត ខារណាវ៉ាស បានស្នើឲ្យមានសិទ្ធិច្រើនជាងមុនដែលទទួលស្គាល់ដល់ទស្សនៈនៃ «អន្តរជាតិ» ។ គាត់បានអះអាងថា ពាក្យថា «អន្តរជាតិ» ត្រូវបានបង្កើតឡើងដោយតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន ហើយក្រោយមកត្រូវបានយកមកតាក់តែងឡើងវិញដោយអង្គសវនាការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ប៉ុន្តែ ខារណាវ៉ាស បានរក្សាជំហររបស់គាត់ថាតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូនគឺជាប្រភេទផ្សេងគ្នាពីតុលាការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ហើយ «គ្រាន់តែតុលាការមួយនៅក្នុងប្រទេសដ៏ឆ្ងាយមួយ ហើយបង្កើតពាក្យនេះ» មិនបានធ្វើឲ្យអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាថាមានលក្ខណៈអន្តរជាតិទេ ។ ខារណាវ៉ាស បានអះអាងថា មានលក្ខណៈអន្តរជាតិមានន័យថា «វាមានលក្ខណៈអន្តរជាតិពេលដែលយើងចង់ឲ្យវាមានលក្ខណៈអន្តរជាតិ ។ ជាវិធីមួយដែលប្រើប្រាស់តែច្បាប់ជាតិនៅពេលដែលវិធីនោះមិនមានភាពងាយស្រួល ។ ខារណាវ៉ាស បានធ្វើសេចក្តីសន្និដ្ឋានទៅលើចំណុចនេះដោយបញ្ជាក់ឡើងវិញនូវសេចក្តីថ្លែងរបស់គាត់កាលពីដំបូងដែលថាកម្ពុជាបានស្នើសុំជំនួយសម្រាប់តែសាលាក្តីនេះតែប៉ុណ្ណោះមិនមែនសម្រាប់តុលាការអន្តរជាតិទេ ហើយដូច្នេះអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគឺជាតុលាការជាតិមិនមែនជាតុលាការ «អន្តរជាតិ» ទេ ។

ទីបញ្ចប់ ទាក់ទងទៅនឹងតុលាការឆ្នាំ១៩៧៩ ម៉ែឃើល ខារណាវ៉ាស បានទទួលស្គាល់ថា វាមិនអាចមានភាពឥតខ្ចោះនោះទេ ប៉ុន្តែគាត់បានបញ្ជាក់ម្តងទៀតថា គ្មាននរណាម្នាក់និយាយថាការកាត់ទោស និងការដាក់ទោសមកលើខ្លួនឯងអស់សុពលភាព ហើយមិនអាចត្រូវបានកាត់ទោសនោះទេ ។ ខារណាវ៉ាស បានបញ្ជាក់ថា ការកាត់ទោសនៅតែមានសុពលភាព ហេតុដូច្នេះហើយបានជាការលើកលែងទោស អៀង សារី ឆ្នាំ១៩៩៦ ជាការចាំបាច់ ។

ត្រង់ចំណុចនេះ ប្រធាន និល ណុន បាននិយាយកាត់ ខារណាវ៉ាស ដោយប្រាប់ថាពេលវេលារបស់គាត់អស់ហើយ និង ដើម្បីបង្ហាញថា តុលាការនឹងពង្រឹងរបៀបវារៈរបស់ខ្លួន ហើយមិនត្រូវចាកឆ្ងាយពីកាលវិភាគរបស់ខ្លួនដាងថ្ងៃម្សិលមិញទេ ។ ក្នុងករណីនេះ ខារណាវ៉ាស បានបញ្ចប់សេចក្តីសន្និដ្ឋានរបស់គាត់ ដោយធ្វើការសុំទោសដែល «មានការអត់ធ្មត់» ចំពោះដំណើរការកាលពីថ្ងៃច័ន្ទ ។ មេធាវីផ្សេងទៀតក៏បានធ្វើការសុំទោសដល់តុលាការដែរចំពោះការដែលនាំទៅរកការប្រាកចាកក្នុងកាលវិភាគកាលពីថ្ងៃច័ន្ទ ។

## ការជំទាស់បឋមទាក់ទងនឹងព្រះរាជទានទោស និងការលើកលែងទោសរបស់ អៀង សារី

បន្ទាប់ពីសេចក្តីសន្និដ្ឋានឆ្លើយតបរបស់ ខារណាវ៉ាស តុលាការបានងាកចំណាប់អារម្មណ៍មកលើការជំទាស់បឋមដោយ អៀង សារី ចំពោះការដាក់ទោសមកលើខ្លួនដោយសម្អាងលើព្រះរាជទានទោស និងការលើកលែងទោសឆ្នាំ១៩៩៦ ។ ប្រធាន និល ណុន បានស្នើឲ្យគ្រប់ភាគីទាំងអស់កំណត់នូវការផ្តល់យោបល់របស់ខ្លួនក្នុងការថ្លែងថាតើការអភ័យទោសនិងការលើកលែងទោស

អាចបន្តទៅរកការចោទប្រកាន់ពីបទឧក្រិដ្ឋផ្សេងទៀតដែរឬយ៉ាងណាចំពោះអ្វីដែល អៀង សារី ត្រូវបានចោទប្រកាន់ថ្មីៗនេះ ។

មុននឹងចាប់ផ្តើមបកស្រាយផ្ទាល់មាត់របស់ខ្លួន សហមេធាវីរបស់ អៀង សារី អាង ឧត្តម បានស្នើសុំ អៀង សារី ឲ្យចាកចេញពីបន្ទប់សវនាការ ហើយត្រឡប់ទៅកាន់បន្ទប់រង់ចាំដោយមិនចាំបាច់សុំពីតុលាការពេលណាក៏បានក្នុងអំឡុងពេលដំណើរការសវនាការ ។ ការធ្វើបែបនេះគឺមិនចាំបាច់រំខានដល់ដំណើរការសវនាការទេ។ ប្រធាន និល ណុន បានច្រានចោលនូវការអះអាងរបស់ អាង ឧត្តម ដោយអះអាងថា ត្រូវមានហេតុផលច្បាស់លាស់អំពីសំណើណាមួយ ដូច្នេះតុលាការអាចដឹងពីមូលដ្ឋានច្បាស់លាស់ថាតើត្រូវបដិសេធឬយល់ព្រម ។ និល ណុល បានបន្ទោស អាង ឧត្តម ថា «ក្នុងនាមជាមេធាវី អ្នកត្រូវតែបញ្ជាក់ឲ្យច្បាស់ និងមានហេតុផលច្បាស់លាស់» ។

ជាជាងបញ្ជាក់ហេតុផលនៃសំណើរបស់គាត់ ឧត្តម បានទុកសំណើនោះមួយអន្លើសិន ហើយចាប់ផ្តើមបកស្រាយផ្ទាល់មាត់ទាក់ទងទៅនឹងព្រះរាជទានទោស និងការលើកលែងទោសរបស់ អៀង សារី ។ អាង ឧត្តម បានចាប់ផ្តើមបកស្រាយអំពីប្រវត្តិនៃប្រធានបទនេះ ដោយបកស្រាយអំពីតុលាការកាត់ទោស អៀង សារី ឆ្នាំ១៩៧៩ ដោយកាត់ទោសប្រហារជីវិត ហើយក្រោយមកឆ្នាំ១៩៩៤ សភាជាតិកម្ពុជាបានអនុម័តច្បាប់ដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឲ្យនៅក្រៅច្បាប់ ហើយប្រកាសថា សមាជិករបស់ក្រុមនេះគឺជាក្រុមខុសច្បាប់ ។ អាង ឧត្តម បានដកស្រង់ច្បាប់ឆ្នាំ១៩៩៤ថា ជំហានដំបូងក្នុងការព្យាយាមបញ្ចប់សង្គ្រាម និងបន្តដំណើរការបង្រួបបង្រួមជាតិ ។ ក្នុងឆ្នាំ១៩៩៦ រដ្ឋាភិបាលនិង អៀង សារី ចាប់ផ្តើមចរចាអំពីការផ្តាច់ខ្លួនរបស់ អៀង សារី មកក្នុងសង្គមកម្ពុជា ដែលពេលនោះ អៀង សារី អះអាងថា គាត់នឹងមិនចរចាទេ លុះត្រាតែគាត់ទទួលបាននូវការលើកលែងទោសជាមុនសិន ដោយចៀសផុតពីការកាត់ទោសពីបទឧក្រិដ្ឋនាពេលអនាគត ។ អៀង សារី បានទទូចថា ការលើកលែងទោសមកលើរូបខ្លួនគឺជាតម្រូវការដែលនាំទៅរកចរចាដើម្បីធ្វើសមាហរណកម្ម ។ តាមសំណើរបស់សហនាយករដ្ឋមន្ត្រីនៅពេលនោះ សម្តេចព្រះនរោត្តម សីហនុ យល់ព្រមផ្តល់ការលើកលែងទោសបើសិនជាពីរភាគបីនៃរដ្ឋសភាពយល់ព្រមចំពោះសេចក្តីសម្រេចនេះ ហើយ អាង ឧត្តម បញ្ជាក់ថា សមាជិករដ្ឋសភាយល់ព្រមចំពោះករណីនេះ ។ ដូច្នេះ អៀង សារី ត្រូវបានផ្តល់ព្រះរាជទានទោសក្នុងឆ្នាំ១៩៩៦ ។

ក្រោយពីរៀបរាប់ពីប្រវត្តិនេះចប់ អាង ឧត្តម បានត្រឡប់ទៅរកដែនសមត្ថកិច្ចរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីពិនិត្យអំពីការអភ័យទោសនិងការលើកលែងទោសឆ្នាំ១៩៩៦ ។ អាង ឧត្តម បានបញ្ជាក់ថា អង្គជំនុំជម្រះមិនមានយុត្តាធិការក្នុងការពិចារណាអំពីសុពលភាពនៃការអភ័យទោសនិងការលើកលែងទោសទេ ។ ផ្ទុយមកវិញ សុពលភាពនៃច្បាប់ដែលប្រកាសដោយព្រះមហាក្សត្រ អាចនឹងត្រឹមតែពិនិត្យសារឡើងវិញដោយសភាជាតិទាក់ទងទៅនឹងធម្មនុញ្ញច្បាប់ប៉ុណ្ណោះ ។ អាង ឧត្តម បានអះអាងថា ដោយសារតែសាលាក្តីខ្មែរក្រហមមិនមែនជាតុលាការធម្មនុញ្ញ តុលាការនេះគ្រាន់តែកំណត់ដែនកំណត់ ហើយមិនមែនជាអ្នកកំណត់សុពលភាពនៃការលើកលែងទោសនិងការអភ័យទោសឆ្នាំ១៩៩៦ទេ ។

បន្ទាប់ អាង ឧត្តម បានងាកមកនិយាយពីសុពលភាពនៃព្រះរាជទានទោសនិងការលើកលែងទោសក្នុងដំណើរការក្តីនៅសាលាក្តីខ្មែរក្រហម ។ អាង ឧត្តម បានបញ្ជាក់ថា ព្រះរាជទានទោសនិងការលើកលែងទោសបានផ្តល់ដោយមានសុពលនៅឡើយនៅក្នុងមាត្រា២៧នៃរដ្ឋធម្មនុញ្ញកម្ពុជា ហើយមាត្រា២៧មិនមានដែនកំណត់ណាមួយចំពោះដែនកំណត់នៃព្រះរាជទានទោសនិងការលើកលែងទោស ។ ដោយសារតែការបង្កើតច្បាប់របស់សាលាក្តីខ្មែរក្រហមតម្រូវឲ្យធ្វើតាមច្បាប់កម្ពុជា ច្បាប់នេះត្រូវតែស្វែងរកព្រះរាជទានទោសនិងការលើកលែងទោសដើម្បីឲ្យមានសុពលភាពនៃគោលបំណងរបស់សាលាក្តីខ្មែរក្រហម ។ អាង ឧត្តម បានសន្និដ្ឋានការអះអាងរបស់គាត់ដោយបញ្ជាក់ឲ្យច្បាស់ថា ដែនកំណត់របស់ព្រះរាជទានទោសនិងការលើកលែងទោសគឺមានន័យគ្រប់គ្រាន់ល្មមដើម្បីដាក់បញ្ចូលគ្រប់បទឧក្រិដ្ឋទាំងអស់ដែល អៀង សារី ត្រូវបានចោទប្រកាន់នៅក្នុងសាលាក្តីខ្មែរក្រហម ហើយគាត់បានទទូចឲ្យតុលាការនេះចងចាំអំពីគោលបំណងនៃការព្រះរាជទានទោសនិងការលើកលែងទោស ។ អាង ឧត្តម បាននិយាយថា «ខ្ញុំ

មិនគិតថា អង្គជំនុំជម្រះត្រូវការរំពឹកថា បើគ្មានការចុះចូលរបស់ អៀង សារី ទេ ប្រទេសកម្ពុជានឹងមិនទាន់បញ្ចប់សង្គ្រាមស៊ីវិល ហើយសង្គ្រាមអាចនឹងបន្តរហូតដល់សព្វថ្ងៃនេះផង ហើយជាលទ្ធផលនឹងបង្កឲ្យមានមនុស្សស្លាប់រាប់មិនអស់» ។

សហសេវិករបស់ អាង ឧត្តម គឺ ម៉ៃឃើល ខាណាវ៉ាស បានបន្តបកស្រាយបញ្ជាក់អំពី អៀង សារី ដោយបញ្ជាក់សាឡើងវិញពីចំណុចចុងក្រោយដែលថា ការអភ័យទោស និងការលើកលែងទោសមិនទាក់ទងជាមួយនឹងនិទណ្ឌភាពទេ តែវិធីនេះដើម្បីបញ្ចប់នូវការបង្ហូរឈាមដែលកំពុងតែកើតឡើងនៅកម្ពុជាកាលពីពេលនោះ ។ ខាណាវ៉ាស បានអះអាងទៀតថា ខណៈពេលដែលការផ្តល់នូវការអភ័យទោស «អាចមានភាពមិនល្អពេលខ្លះ» តែគោលបំណងនៃការអភ័យទោសគឺដើម្បីបញ្ចប់អំពើហិង្សា ។ ខាណាវ៉ាស បានបន្តដោយបញ្ជាក់ថា ការអភ័យទោសនិងការលើកលែងទោសមិនមានភាពទូលំទូលាយនៃវិសាលភាពតាមការមើលឃើញនោះទេ តែការអភ័យទោសគឺធ្វើឡើងចំពោះបុគ្គលជាក់លាក់ណាមួយ ហើយមិនបានរារាំងសាលាក្តីខ្មែរក្រហមនេះក្នុងការទប់ស្កាត់មិនឲ្យមានការកាត់ទោសមេដឹកនាំឯទៀតទេ ។ ខាណាវ៉ាស បានធ្វើការប្រៀបធៀបការអភ័យទោសនិងការលើកលែងទោសទៅនឹងការលើកលែងទោសដែលកើតឡើងនៅក្នុងប្រទេសសេរ៉ាឡេអូនដែលយល់ព្រមដោយអង្គការសហប្រជាជាតិ ។ ខាណាវ៉ាស បានកត់សម្គាល់ថា ការលើកលែងទោសមិនអាចកើតឡើងបានទេដោយសារតែគ្រប់ភាគីមិនបានប្រកាន់ភ្ជាប់កិច្ចព្រមព្រៀង ។ សម្រាប់នៅសាលាក្តីខ្មែរក្រហមវិញ អៀង សារី គោរពកិច្ចព្រមព្រៀងជានិច្ច ហើយការអភ័យទោសនិងការលើកលែងទោស «នាំមកនូវផ្លែផ្កាដូចអ្វីដែលមានចែងក្នុងកិច្ចព្រមព្រៀងដូច្នោះដែរ គឺសន្តិភាពនៅក្នុងប្រទេសកម្ពុជា» ។

ក្រោយមក ខាណាវ៉ាស បានងាកមកបកស្រាយអំពីសំណួរដែលចោទសួរដោយតុលាការកាលពីគាត់ផ្តើមថ្លែងដំបូងទាក់ទងទៅនឹងសំណួរថាតើការអភ័យទោស ឬការលើកលែងទោសអាចនាំទៅរកបទឧក្រិដ្ឋផ្សេងទៀតក្នុងករណីថ្មីៗនេះបានដែរឬទេ ។ ខាណាវ៉ាស បាននិយាយថា អំណាចច្បាប់នៅក្នុងស្រុកមានសិទ្ធិនិងផ្តល់ការលើកលែងទោស សូម្បីតែពេលពិភាក្សាអំពីបទឧក្រិដ្ឋនៅទីនោះ ឬច្បាប់អ្វីទៀតក៏ដោយ ។ ខាណាវ៉ាស បានបញ្ជាក់ថាខណៈពេលដែលរដ្ឋត្រូវបានហាមឃាត់ក្នុងការប្រព្រឹត្តបទឧក្រិដ្ឋទាំងនេះតាមរយៈបរិបទអន្តរជាតិ គ្មានសិទ្ធិអំណាចស្រដៀងគ្នាណាមួយដែលគាត់ធ្លាប់ដឹង ហើយក៏គ្មានតំណាមអន្តរជាតិណាមួយដែលកំណត់នូវការកាត់ទោសដ៏ជាក់លាក់នៃឧក្រិដ្ឋកម្មនេះដែរ ។ ខាណាវ៉ាស នៅតែរក្សាជំហរថា ប្រទេសសេរ៉ាឡេអូនជាអ្នកធ្វើអ្វីដែលបានរៀបរាប់មកនេះគ្រន់ថា តំណាងរបស់អង្គការសហប្រជាជាតិបានចុះហត្ថលេខាផ្តល់ការលើកលែងទោសដើម្បីបញ្ចប់សង្គ្រាមស៊ីវិល ។

ទីបញ្ចប់ ខាណាវ៉ាស បានទទូចដល់តុលាការឲ្យយល់ព្រមដល់សំណើរបស់ អៀង សារី ដើម្បីធ្វើជាសាក្សីទាក់ទងនឹងការអានព្រះរាជទានទោសនិងការលើកលែងទោស ។ ខាណាវ៉ាស បានបញ្ជាក់ថា មានការបកប្រែចំនួនបីភាសាខុសគ្នានៃពាក្យអភ័យទោសនិងការលើកលែងទោសដែលប្រើប្រាស់ដោយភាគីទាំងអស់នៅក្នុងករណីរបស់ អៀង សារី នេះ ។ ការបកប្រែផ្សេងៗគ្នានេះបង្កើតឲ្យមានភាពមិនច្បាស់លាស់ទៅនឹងបំណងនៃអត្ថន័យដើមនៃពាក្យការអភ័យទោសនិងការលើកលែងទោស ដែលនឹងបញ្ជាក់ច្បាស់បំផុតតាមរយៈការនាំសាក្សីដែលពាក់ព័ន្ធនឹងការចរចានេះ ។ ក្រោយពីការថ្លែងរបស់ក្រុមការពារក្តី តុលាការបានចាប់ផ្តើមសម្រាករយៈពេលម្ភៃនាទី ។

ពេលតុលាការចាប់ផ្តើមឡើងវិញនៅពេលព្រឹក ប្រធាន និល ណុន បានឆ្លើយតបទៅនឹងសំណើដែលធ្វើឡើងដោយភាគីរដ្ឋប្បវេណីកាលពីថ្ងៃច័ន្ទដើម្បីដោះស្រាយទៅនឹងភាគីរដ្ឋប្បវេណីថ្មីដែលអនុញ្ញាតដោយអង្គបុរេជំនុំជម្រះតាមរយៈសេចក្តីសម្រេចកាលពីថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១១ ។ តុលាការបានជម្រាបដំណឹងដល់គ្រប់ភាគីទាំងអស់ថា តុលាការនឹងទុកពេលដប់នាទីមុននឹងបញ្ចប់ដំណើរការសវនាការថ្ងៃនេះ សម្រាប់ភាគីបណ្តឹងរដ្ឋប្បវេណីក្នុងការបកស្រាយអំពីសំណើរបស់ខ្លួន ។

ក្រោយមក អាង ឧត្តម បានបញ្ជាក់អំពីសំណើរបស់ខ្លួនសាឡើងវិញទៀតថាទៅកាន់ចៅក្រមថាតើត្រូវអនុញ្ញាតឲ្យ អៀង សារី ចេញពីបន្ទប់សវនាការឬអត់ដើម្បីទៅក្នុងបន្ទប់រង់ចាំវិញ ដោយសារតែគាត់ឈឺខ្លួន ។ តុលាការក៏បានអនុញ្ញាតដល់ អៀង

សារី ហើយ អៀង សារី ក៏បាននាំចេញពីបន្ទប់សវនាការដោយសន្តិសុខ ។

## ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាទៅកាន់សេចក្តីថ្លែងការណ៍ផ្ទាល់មាត់របស់ អៀង សារី ទាក់ទងនឹងការអភ័យទោស និងការលើកលែងទោស

សហព្រះរាជអាជ្ញារង ចាន់ តារារស្មី បានចាប់ផ្តើមឆ្លើយតបទៅនឹងការជំទាស់បឋមរបស់ អៀង សារី ដែលឆ្លើយដោយសហព្រះរាជអាជ្ញាទាក់ទងនឹងការអភ័យទោស និងការលើកលែងទោសកាលពីឆ្នាំ១៩៩៦ ។ តារារស្មី បានផ្តោតការអះអាងតាមផ្លូវច្បាប់ទាំងស្រុងទៅលើអ្វីដែលគាត់បញ្ជាក់ថា «ដែនកំណត់ដែលមានកំណត់ច្បាស់លាស់» នៃព្រះរាជទានទោស និងការលើកលែងទោសដែលមិនអាចលាក់បាំងបទឧក្រិដ្ឋធ្ងន់ធ្ងរដែល អៀង សារី បានប្រព្រឹត្តយ៉ាងជាក់ស្តែងក្នុងអំឡុងពីឆ្នាំ១៩៧៥ - ១៩៧៩ទេ ។

ដើម្បីកំណត់និយមន័យវិសាលភាពនេះ តារារស្មី បានទាញចំណាប់អារម្មណ៍របស់តុលាការឲ្យងាកមករកពាក្យនៃការបកប្រែវិញ ។ ខុសពីក្រុមការពារក្តី តារារស្មី នៅតែរក្សាជំហរថាការបកប្រែពាក្យការអភ័យទោស និងការលើកលែងទោសត្រូវបានប្រើប្រាស់មិនបានធ្វើឲ្យមានភាពខុសគ្នាចំពោះការអនុវត្តការអភ័យទោសនិងការលើកលែងទោសទេចំពោះករណីនេះ ព្រោះជម្លោះកើតឡើងតាមរយៈការប្រើប្រាស់ការបកប្រែជាភាសាអង់គ្លេស មិនមែនដោយសារតែការអានអំពីព្រះរាជទានទោសនិងការអភ័យទោសជាភាសាខ្មែរដើមឡើយ ។ តារារស្មី បានបញ្ជាក់ទៀតថា ក្រុមការពារក្តីអង្គបុរេជំនុំជម្រះ ហើយនិងក្រុមបកប្រែរបស់សាលាក្តីខ្មែរក្រហមសុទ្ធតែយល់ស្របថាពាក្យ «លើកទោស» ដែលបានប្រើប្រាស់ក្នុងឯកសារដើមអាចមានន័យស្មើនឹងពាក្យអង់គ្លេស «*amnesty*» និង «*pardon*» ។ នៅពេលដែលក្រុមការពាក្តីថា ពាក្យនេះបង្កើតឲ្យមានពាក្យមិនស៊ីសង្វាក់គ្នា តារារស្មី បាននិយាយថា ពាក្យ «ព្រះរាជទានទោស» និង «ការលើកលែងទោស» នៅតែមានអត្ថន័យស្រដៀងគ្នា ។ គាត់បានឲ្យនិយមន័យពាក្យ «លើកទោស» ថា «លើកទោសកំហុសដែលបានធ្វើខុស» ហើយថា ពាក្យនេះតម្រូវថាជនជាប់ចោទត្រូវតែយកមកកាត់ទោស ដាក់ទោសនិងទទួលទោសណាមួយដើម្បីទទួលបាននូវការលើកលែងទោស ។ ដោយសារតែ អៀង សារី មិនដែលទទួលទោសណាទេ តាមរយៈការកាត់ទោសក្នុងឆ្នាំ១៩៧៩ ទើបការលើកលែងទោសមិនអាចយកមកអនុវត្តបានទេ ។

តារារស្មី បាននិយាយបន្ថែមទៀតថា ការលើកលែងទោសដែលផ្តល់ជូន អៀង សារី ក្នុងឆ្នាំ១៩៩៦ គឺគ្រាន់តែដើម្បីគ្របដណ្តប់បទល្មើសរបស់គាត់ដែលបានដាក់កម្ពុជាប្រជាធិបតេយ្យនៅក្រៅច្បាប់ក្នុងឆ្នាំ១៩៩៤ប៉ុណ្ណោះ ។ តារារស្មី បានអះអាងថា តាមនិយមន័យការលើកលែងទោសនេះមិនបានគ្របដណ្តប់លើបទឧក្រិដ្ឋផ្សេងទៀតដែលបានប្រព្រឹត្តពីឆ្នាំ១៩៧៥ដល់១៩៧៩ ដែលមិនបានរាប់បញ្ចូលក្នុងការដាក់ខ្មែរក្រហមឲ្យនៅក្រៅច្បាប់កាលពីឆ្នាំ១៩៩៤ទេ ។ មាត្រា៥នៃច្បាប់នេះបានចែងថាគ្រាន់តែជាការបណ្តោះអាសន្នប៉ុណ្ណោះដែលផ្តល់ការលើកលែងទោសប្រតិសកម្ម ហើយមាត្រានេះបញ្ជាក់យ៉ាងច្បាស់ថាមិនទាក់ទងទៅនឹងមេដឹកនាំកម្ពុជាប្រជាធិបតេយ្យទេ ហើយករណី អៀង សារី គឺជាមេដឹកនាំកម្ពុជាប្រជាធិបតេយ្យ ។ តាមរយៈអំណាននេះ តារារស្មី បានទទូចឲ្យតុលាការជំទាស់ទាំងស្រុងទៅនឹងការអះអាងរបស់ជនជាប់ចោទដែលថា ច្បាប់ឆ្នាំ១៩៩៤បានផ្តល់នូវការលើកលែងទោសមកខ្លួនដោយរួចផុតពីការកាត់ទោសទោសទាំងឡាយពីបទឧក្រិដ្ឋក្នុងនាមជាមេដឹកនាំរបស់របបកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ១៩៧៥ដល់១៩៧៩ ។

សហព្រះរាជអាជ្ញារង វីលៀម ស្មីត បានបន្តការបកស្រាយពី តារារស្មី ដោយបញ្ជាក់ចំណុចសំខាន់ៗអំពីកាតព្វកិច្ចរបស់សាលាក្តីខ្មែរក្រហមក្នុងការកាត់ទោសបទឧក្រិដ្ឋដូចជាអំពើប្រល័យពូជសាសន៍ ។ កាតព្វកិច្ចនេះឆ្លុះបញ្ចាំងពីតម្រូវការក្រោមមាត្រា១នៃអនុសញ្ញាស្តីអំពីការការពារនិងការដាក់ទោសក្នុងឆ្នាំ១៩៤៨ នៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍សម្រាប់រដ្ឋជាសមាជិកទាំងអស់ «ដើម្បីការពារនិងដើម្បីទាក់ទោស» ឧក្រិដ្ឋកម្មនៃអំពើប្រល័យពូជសាសន៍ ។ វីលៀម ស្មីត បានបញ្ជាក់ទៀតថា បើសិនជាអង្គបុរេជំនុំជម្រះរកឃើញថា ការអភ័យទោសនិងការលើកលែងទោសអាចអនុវត្តបានចំពោះបទឧក្រិដ្ឋផ្សេងៗដូចជាអំពើប្រល័យពូជសាសន៍ អង្គបុរេជំនុំជម្រះ «មានកាតព្វកិច្ចជាមូលដ្ឋាននិង

ឯករាជ្យក្រោមច្បាប់អន្តរជាតិ» ដោយមិនអនុញ្ញាតឲ្យការលើកលែងទោសរារាំងការកាត់ទោសពីបទទាំងនេះបានដែរ ។

លោក វីលៀម ស្មីត បានជំទាស់នឹងការអះអាងរបស់មេធាវីការពារជនជាប់ចោទម្តងទៀតដែលអះអាងថាតុលាការខ្មែរក្រហមមិនមែនជាតុលាការអន្តរជាតិ ។ ក្នុងគោលបំណងបញ្ចប់បញ្ហាចម្រូងចម្រាសនេះ លោក វីលៀម ស្មីត បានសង្កត់ធ្ងន់លើអំណះអំណាងរបស់លោកដោយមើលចំមកលោក ម៉ៃ ឃើល ខាណាវ៉ាស ខណៈពេលដែលលោកលើកឡើងនូវអំណះអំណាងចំនួនប្រាំមួយដែលបញ្ជាក់ថាអង្គជំនុំជម្រះសាលាដំបូងគឺជាតុលាការអន្តរជាតិ ។

បន្ទាប់មកទៀត លោក វីលៀម ស្មីត បានបន្តលើកឡើងពីអំណាចតាមបទដ្ឋានអន្តរជាតិមួយចំនួនទៀតដែលក្នុងនោះរួមមានមតិយោបល់ដែលដកស្រង់ចេញពីតុលាការរបស់ប្រទេសយូហ្គោស្លាវី និងតុលាការរបស់ប្រទេសសេរ៉ាឡេអូន និងចេញពីឯកសាររបស់អង្គការសហប្រជាជាតិផ្សេងៗដែលចែងថា ការលើកលែងទោសមិនអាចលុបចោលកាតព្វកិច្ចក្នុងការកាត់ទោសឧក្រិដ្ឋកម្មដែលមាននៅក្នុងគោលការណ៍ទំនៀមទម្លាប់អន្តរជាតិបានឡើយ ។ លោកបានបន្តទៀតថា «អង្គជំនុំជម្រះសាលាដំបូងមានកាតព្វកិច្ចធានាថាការលើកលែងទោសសម្រាប់ឧក្រិដ្ឋកម្មទាំងអស់នេះមិនមានជាប់ពាក់ព័ន្ធ.....ឬយ៉ាងហោចណាស់ អង្គជំនុំជម្រះសាលាដំបូងត្រូវមានអំណាចសម្រេចថាការលើកលែងទោសនោះមិនមានសុពលភាពអ្វីទេ» ។

ក្រោយមក លោក វីលៀម ស្មីត បានអះអាងថាក្រុមមេធាវីការពារក្តីបានបង្រួមកាតព្វកិច្ចរបស់រដ្ឋជាសមាជិកក្នុងការមិនផ្តល់ការលើកលែងទោសនៅក្នុងស្ថានភាពទាំងអស់ នោះជាពិសេសគឺនៅក្នុងស្ថានភាព ប្រសិនបើរដ្ឋនោះគឺជាសមាជិករបស់អនុសញ្ញាអំពើប្រល័យពូជសាសន៍ឆ្នាំ១៩៤៨ ។ លោកបានបញ្ជាក់ថាមាត្រា៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជាតម្រូវឲ្យរដ្ឋាភិបាលកម្ពុជា «ទទួលស្គាល់និងគោរពសិទ្ធិមនុស្ស» ដូចដែលមានចែងនៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ ។ ភាសាធម្មតានៃការព្រះរាជទានទោសនិងការលើកលែងទោសបង្ហាញឲ្យឃើញច្បាស់ថា ការផ្តល់ព្រះរាជទានទោសនិងការលើកលែងទោសមិនបានរំលោភលើមាត្រា៣១នេះឡើយ ។ ការលើកលែងទោសមិនគោរពតាមគោលការណ៍រដ្ឋធម្មនុញ្ញ ប្រសិនបើការលើកលែងទោសនោះមិនធ្វើការពិចារណាលើកាតព្វកិច្ចរបស់ប្រទេសកម្ពុជាក្នុងការគោរពទៅតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិដូចដែលមានចែងនៅក្នុងមាត្រា៣១ ។ លោកក៏បាននិយាយបន្តទៀតថា ក្រុមមេធាវីការពារក្តីបានលើកឡើងនូវអំណះអំណាងពីរផ្ទុយគ្នា ហើយចង់ឲ្យមានការទទួលស្គាល់អំណះអំណាងទាំងពីរនេះ ។ ដើមឡើយកាលពីថ្ងៃច័ន្ទ ក្រុមមេធាវីការពារក្តីបានអះអាងថា មាត្រា៣១មានជាប់ពាក់ព័ន្ធនឹងតុលាការខ្មែរក្រហម ប៉ុន្តែក្រោយមកបានបដិសេធចោលកាតព្វកិច្ចដូចគ្នានេះដោយលើកហេតុផលទាក់ទងនឹងព្រះរាជទានទោស និងការលើកលែងទោស ។

លោក វីលៀម ស្មីត បានសន្និដ្ឋានបញ្ចប់ដោយនិយាយថា គោលបំណងនៃការផ្តល់ព្រះរាជទានទោស និងការលើកលែងទោសមានចែងយ៉ាងច្បាស់ដូចដែលបានរៀបរាប់ដោយលោកសហព្រះរាជអាជ្ញារង ចាន់ តារាស្មី ។ ហេតុដូច្នេះ សហព្រះរាជអាជ្ញាសូមស្នើសុំថា ចៅក្រមមិនចាំបាច់កោះហៅសាក្សីឲ្យមកបកស្រាយលើបញ្ហានេះឡើយ ។ យ៉ាងណាមិញ លោកបានស្នើសុំឲ្យចៅក្រមកំណត់ពីកាតព្វកិច្ចរបស់ខ្លួនដើម្បីបដិសេធមិនទទួលស្គាល់ភាពជាប់ពាក់ព័ន្ធរវាងការលើកលែងទោសនិងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់នៅក្នុងរឿងក្តីនេះ មុននឹងចៅក្រមពិចារណាលើការស្នើសុំឲ្យមានសាក្សីមកបកស្រាយពីបញ្ហានេះដូចដែលបានលើកឡើងដោយក្រុមមេធាវីការពារក្តី ។

បន្ទាប់ពីលោកសហព្រះរាជអាជ្ញារងបានបញ្ចប់អំណះអំណាងរបស់ខ្លួន ចៅក្រមបានផ្អាកដំណើរការនីតិវិធីសម្រាប់ការសម្រាកអាហារថ្ងៃត្រង់ ។

## ការឆ្លើយតបរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីទៅកាន់ការអះអាងផ្ទាល់មាត់របស់ អៀង សារី ស្តីពីព្រះរាជទានទោសនិងការលើកលែងទោស

នៅពេលរសៀល យើងសង្កេតឃើញថាចំនួនអ្នកតាមដានដំណើរការនីតិវិធីកាន់តែតិចជាងមុន ។ ក្នុងរយៈពេលពេញមួយថ្ងៃ យើងសង្កេតឃើញថាមនុស្សគ្រប់គ្នានៅក្នុងបន្ទប់សវនាការកាន់តែមាននឿយហត់ដោយសារតែការជជែកដេញដោលពី

ព័ត៌មានលម្អិតផ្នែកច្បាប់សម្រាប់ការពិភាក្សានៅក្នុងថ្ងៃនេះ ។ លើសពីនេះ ទាំងនៅក្នុងបន្ទប់សវនាការនិងសាលសាធារណៈ សម្រាប់អ្នកតាមដានមានភាពស្ងប់ស្ងាត់ជាទីបំផុត ។

អង្គនីតិវិធីបានចាប់ផ្តើមដំណើរការបន្តទៀតដោយមានការស្នើសុំឲ្យជនជាប់ចោទវិលត្រឡប់ទៅកាន់មន្ទីរឃុំឃាំងរបស់ខ្លួនវិញ ។ ក្រោយពីការឈប់សម្រាកអាហារថ្ងៃត្រង់ ហើយមានវគ្គមានម្តងទៀតនៅក្នុងបន្ទប់សវនាការ អៀង សារី ត្រូវបានអនុញ្ញាតឲ្យវិលត្រឡប់ទៅកាន់មន្ទីរឃុំឃាំងរបស់គាត់វិញ ។ បន្ទាប់ពី អៀង សារី ចាកចេញពីបន្ទប់សវនាការ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើការឆ្លើយតបទៅនឹងអំណះអំណាងផ្ទាល់មាត់របស់ អៀង សារី ទាក់ទងនឹងព្រះរាជទានទោស និងការលើកលែងទោស ។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីទីមួយបាននិយាយថា ព្រះរាជទានទោសនិងការលើកលែងទោសឆ្នាំ១៩៩៦ត្រូវបានផ្តល់ឲ្យ អៀង សារី ដោយសារការគំរាមកំហែងប្រដាប់អាវុធ និងអំពើហិង្សា ហើយក៏មិនបានត្រូវបានផ្តល់ឲ្យដោយព្រះមហាក្សត្រដែរ ។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា ប្រសិនបើគ្មានការគំរាមកំហែងនោះ ព្រះរាជទានទោសនិងការលើកលែងទោសនឹងមិនត្រូវបានផ្តល់ឲ្យ អៀង សារី ឡើយ ។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានសន្និដ្ឋានបញ្ចប់ដោយនិយាយថា ការទទួលស្គាល់ការលើកលែងទោសនឹងក្លាយជា «ភ័ស្តុតាងមួយដែលបញ្ជាក់ថាភេរវជនអាចប្រើប្រាស់អំពើហិង្សាដើម្បីលុបលាងឧក្រិដ្ឋកម្មដែលខ្លួនបានប្រព្រឹត្ត» ។

មេធាវីដើមបណ្តឹងរដ្ឋប្បវេណីទីពីរ និងទីបីបានជំទាស់ជារួមថា ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងទទួលស្គាល់ព្រះរាជទានទោស និងការលើកលែងទោសនេះ នោះអង្គជំនុំជម្រះសាលាដំបូងនឹងរំលោភបំពានសិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបានសំណងដ៏មានប្រសិទ្ធភាពមួយជាពុំខាន ។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថាសិទ្ធិទទួលបានសំណងដ៏មានប្រសិទ្ធភាពមួយនោះបែងចែកជាបួនប្រភេទសំខាន់ៗ :

១) ការទទួលបានយុត្តិធម៌ដែលតម្រូវឲ្យមានការកាត់ទោសជនឧក្រិដ្ឋដើម្បីទទួលបានសំណង ហើយយុត្តិធម៌នេះអាចទទួលបាន លុះត្រាតែឧក្រិដ្ឋជនត្រូវបានស្គាល់អត្តសញ្ញាណហើយនាំមកប្រឈមមុខនឹងយុត្តិធម៌ ។ ២) សិទ្ធិទទួលបានការស៊ើបអង្កេតកាត់ទោស និងដាក់ទោសលើបទឧក្រិដ្ឋកម្ម ។ ៣) ការទទួលបានព័ត៌មានទាក់ទងនឹងការរំលោភបំពាន និងការទទួលបានការពិត ។ ៤) ការទទួលបានសំណង ។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានអះអាងថាព្រះរាជទានទោសនិងការលើកលែងទោសនៅក្នុងរឿងក្តីនេះបានបង្កជាឧបសគ្គមួយដល់ជនរងគ្រោះក្នុងការទទួលបានសិទ្ធិខាងលើទាំងអស់នេះ ។ ប្រសិនបើព្រះរាជទានទោស និងការលើកលែងទោសត្រូវបានទទួលស្គាល់ នោះជនរងគ្រោះនឹងគ្មានទីពំនាក់ដើម្បីស្វែងរកសំណងសម្រាប់ការរំលោភបំពានធ្ងន់ធ្ងរលើសិទ្ធិរបស់ជនរងគ្រោះ ជាពិសេសគឺជនដែលរងគ្រោះផ្ទាល់ឬរងគ្រោះដោយសារបញ្ហារបស់ អៀង សារី ។ ហេតុដូច្នេះ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំឲ្យចៅក្រមបដិសេធចោលអំណះអំណាងរបស់មេធាវីការពារក្តី ។

## ការឆ្លើយតបរបស់ អៀង សារី ទៅកាន់សហព្រះរាជអាជ្ញានិងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី

ជាថ្មីម្តងទៀត លោកម៉ៃឃើល ខាណាវ៉ាស បានចាត់ចែងធ្វើការឆ្លើយតបជូនសឲ្យ អៀង សារី ទៅកាន់អំណះអំណាងរបស់សហព្រះរាជអាជ្ញា និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ។ ទាក់ទិននឹងការស្នើសុំរបស់ជនជាប់ចោទដើម្បីនាំសាក្សីមកធ្វើសក្ខីកម្មស្តីពីគោលបំណងដែលស្ថិតនៅពីក្រោយការផ្តល់ព្រះរាជទានទោសនិងការលើកលែងទោសនេះ លោកម៉ៃឃើល ខាណាវ៉ាស បាននិយាយថា ការជំទាស់របស់សហព្រះរាជអាជ្ញាលើការស្នើសុំនេះគឺផ្អែកលើ «ពាក្យចចាមអារ៉ាម» ដែលលេចចេញពីលោកនាយករដ្ឋមន្ត្រី និងការបកស្រាយរបស់អង្គបុរេជំនុំជម្រះដែលមិនមានជាប់ពាក់ព័ន្ធនៅក្នុងកិច្ចចរចាដំបូងពីការលើកលែងទោសនិងព្រះរាជទានទោស ។ លោក ម៉ៃឃើល ខាណាវ៉ាស បានជំរុញឲ្យចៅក្រមអនុញ្ញាតឲ្យជនជាប់ចោទនាំយក «ភ័ស្តុតាងដែលមាន» មកបញ្ជាក់លើបញ្ហានេះ ។ ភ័ស្តុតាងនោះគឺសំដៅលើបុគ្គលដែលមានជាប់ពាក់ព័ន្ធផ្ទាល់នៅក្នុងការចរចាផ្តល់ព្រះរាជទានទោសនិងការលើកលែងទោសឲ្យ អៀង សារី ។

បន្ទាប់មកទៀត លោកម៉ៃឃើល ខាណាវ៉ាស បានចាត់ទុកការបកស្រាយរបស់សហព្រះរាជអាជ្ញាលើព្រះរាជទានទោសនិង

ការលើកលែងទោសថា «មិនសមហេតុផល» ដោយអះអាងថា តាមរយៈការបកស្រាយបែបនេះ ជនជាប់ចោទអាចនឹងប្រើប្រាស់បទបញ្ញត្តិនៃការលើកលែងទោស ប្រសិនបើជនជាប់ចោទត្រូវបានចោទប្រកាន់នៅឯតុលាការខ្មែរក្រហម ។ លោកបានជំរុញឲ្យអង្គជំនុំជម្រះសាលាដំបូងអានខ្លឹមសារនៃបទព្រះរាជទានទោសនិងការលើកលែងទោសទាំងស្រុង ហើយសម្រេចថាតើគោលបំណងនៃព្រះរាជទានទោសនិងការលើកលែងទោសនោះមានន័យច្បាស់ដូចអ្វីដែលព្រះរាជអាជ្ញាយល់ឃើញឬយ៉ាងណា ។

ក្រោយមកទៀត ម៉ៃឃើល ខាណាវ៉ាស បានរំឭកចៅក្រមថាចៅក្រមត្រូវតែចេញសេចក្ដីសម្រេច ហើយអនុវត្តច្បាប់កម្ពុជា ឬច្បាប់ទំនៀមទម្លាប់អន្តរជាតិ ពីព្រោះថាចៅក្រមត្រូវតែចាត់វិធានការឲ្យទាន់ពេលវេលា ។ នៅក្នុងករណីនេះ ការលើកលែងទោសត្រូវបានផ្ដល់ឲ្យនៅឆ្នាំ១៩៩៦ ។ លោកបានចោទសួរថាប្រសិនបើច្បាប់ដែលទាក់ទងនឹងការមិនមានជាប់ពាក់ព័ន្ធរវាងការលើកលែងទោស ឬព្រះរាជទានទោស និងឧក្រិដ្ឋកម្មដែលមានចែងនៅក្នុងគោលការណ៍ទំនៀមទម្លាប់អន្តរជាតិត្រូវបានដោះស្រាយនៅអំឡុងពេលនោះដូចដែលសហព្រះរាជអាជ្ញាបានស្នើឡើងមែន ចុះហេតុអ្វីបានជាអង្គការសហប្រជាជាតិចូលរួមនៅក្នុងការចរចាទាមទារឲ្យមានការលើកលែងទោសនៅប្រទេសសេរ៉ាឡេអូន?

ជាចុងក្រោយ ម៉ៃឃើល ខាណាវ៉ាស បានឆ្លើយតបទៅកាន់អំណះអំណាងរបស់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ។ បើនិយាយពីការអះអាងដែលថា អៀង សារី «បានបង្ខិតបង្ខំ» រដ្ឋាភិបាលកម្ពុជានោះ ម៉ៃឃើល ខាណាវ៉ាស បាននិយាយថា «នេះគឺជាខ្លឹមសារទាំងស្រុង ។ គោលបំណងនៃព្រះរាជទានទោស និងការលើកលែងទោសគឺដើម្បីបញ្ឈប់អំពើហិង្សា» ។ លោកបានឆ្លុះបញ្ចាំងឲ្យឃើញថាសន្តិភាព និងលទ្ធិប្រជាធិបតេយ្យនាពេលបច្ចុប្បន្នរបស់ប្រទេសកម្ពុជាកើតមានឡើងដោយសារតែសេចក្ដីសម្រេចរបស់ អៀង សារី ក្នុងការទាមទារព្រះរាជទានទោសនិងការលើកលែងទោសពីព្រះមហាក្សត្រ ។

បើនិយាយពីអំណះអំណាងទាក់ទងនឹងសិទ្ធិទទួលបានសំណងដ៏មានប្រសិទ្ធភាពវិញ ម៉ៃឃើល ខាណាវ៉ាស បាននិយាយថា «ខ្ញុំគឺជាអ្នកជឿលើអំណាចនៃច្បាប់ ហេតុដូច្នេះច្បាប់ត្រូវតែយកមកអនុវត្ត» ។ ក្នុងករណីនេះ លោកបានអះអាងថាច្បាប់តម្រូវឲ្យមានការទទួលស្គាល់ព្រះរាជទានទោស និងការលើកលែងទោសនេះ ។ លោកបានជំរុញឲ្យចៅក្រមធ្វើសេចក្ដីសម្រេចដោយផ្អែកលើ «អ្វីដែលច្បាប់ចែង» ជាជាងផ្អែកលើហេតុផលថាជនជាប់ចោទត្រូវតែឆ្លងកាត់ការកាត់ទោសរបស់តុលាការ ។

អង្គសវនាការបានឈប់សម្រាករយៈពេលម្ភៃនាទី ។

**ការបដិសេធបឋមរបស់ អៀង សារី លើអាជ្ញាយុកាលទាក់ទងនឹងការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ**

ចំនួនអ្នកតាមដាននៅសាលសាធារណៈបានថយចុះនៅពេលដែលជនជាប់ចោទនៅក្នុងបន្ទប់សវនាការមានចំនួនកាន់តែតិចដែរ ។ ជាការចាប់ផ្ដើមនៃដំណើរការនីតិវិធីចុងក្រោយសម្រាប់ថ្ងៃនេះ លោក ផាត ពៅស៊ាង មេធាវីការពារក្ដីជនជាប់ចោទបានស្នើសុំឲ្យកូនក្ដីរបស់លោកគឺ អៀង ធីរិទ្ធ អាចវិលត្រឡប់ទៅកាន់មន្ទីរឃុំឃាំងរបស់ខ្លួនវិញ «ដោយសារបញ្ហាសុខភាពមិនអំណោយផល» ។ ចៅក្រមបានយល់ស្របតាមសំណូមពររបស់លោកមេធាវី ។ នៅក្នុងបន្ទប់សវនាការមានតែវត្តមាន ខៀវ សំផន តែម្នាក់គត់ដែលនឹងត្រូវចូលរួមដំណើរការនីតិវិធីថ្ងៃនេះរហូតដល់ចុងបញ្ចប់ ។

បន្ទាប់មកទៀត ចៅក្រមបានចាប់ផ្ដើមដំណើរការនីតិវិធីចុងបញ្ចប់សម្រាប់ថ្ងៃនេះដោយលើកឡើងពីការបដិសេធផ្ទាល់មាត់របស់មេធាវីការពារក្ដីស្ដីពីការបដិសេធបឋមរបស់ជនជាប់ចោទ អៀង សារី លើអាជ្ញាយុកាលទាក់ទងនឹងការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ។ ជាក់ស្ដែង ចៅក្រមបានស្នើសុំឲ្យភាគីទាំងអស់ពិភាក្សាបញ្ហាពីរគឺ : ១) បញ្ហាដែលចោទសួរថាតើអាជ្ញាយុកាលទាក់ទងនឹងការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ត្រូវបានចែងឬកើតមាននៅក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅអំឡុងឆ្នាំ១៩៧៥ - ១៩៧៩ មែនដែរឬយ៉ាងណា ហើយ ២) បញ្ហាទាក់ទងនឹងការពង្រីកសេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់មេធាវីការពារក្ដីទាក់ទិននឹងបញ្ហានេះ ប្រសិនបើចៅក្រមសម្រេចដូច្នោះ ។

លោក អាង ឧត្ដម បានចាប់ផ្ដើមឆ្លើយតបសម្រាប់ការ

ការពារឲ្យ អៀង សារី ដោយលើកឡើងពីបញ្ហាទីពីរដែលចៅក្រមបានចោទសួរ ។ នៅក្នុងសេចក្តីសន្និដ្ឋានលើកទី៦របស់ក្រុមមេធាវីការពារក្តី (ឯកសារលេខ E83 របស់តុលាការខ្មែរក្រហម) មេធាវីការពារក្តីបានអះអាងថា មាត្រា៦នៃច្បាប់បង្កើតតុលាការខ្មែរក្រហមចាត់ទុកការរំលោភបំពានធ្ងន់ធ្ងរជាបទឧក្រិដ្ឋដូចដែលបានចែងនៅក្នុងអនុសញ្ញាទីក្រុងហ្សឺណែវ ប៉ុន្តែច្បាប់នេះមិនអនុញ្ញាតឲ្យមាន «ការជាប់ពាក់ព័ន្ធផ្ទាល់នៃបទបញ្ញត្តិទាំងអស់នៃអនុសញ្ញាទីក្រុងហ្សឺណែវទេ» ។ ខុសគ្នាពីមាត្រា៤ (ទាក់ទងនឹងឧក្រិដ្ឋកម្មអំពើប្រល័យពូជសាសន៍) និងមាត្រា៥ (ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ) មាត្រា៦នេះមិនមានផ្ទុកនូវពាក្យគន្លឹះ «ដែលគ្មានបញ្ហាក់ពីអាជ្ញាយុកាលទេ» ។ លោក អាង ឧត្តម បានអះអាងថា ដោយសារតែតុលាការខ្មែរក្រហមគឺជាតុលាការកម្ពុជា តុលាការនេះត្រូវតែគោរពតាមគោលការណ៍ច្បាប់កម្ពុជា ។ ដោយសារតែអាជ្ញាយុកាលមិនបានកាត់ផ្តាច់ការរំលោភបំពានចេញពីការអនុវត្តរបស់អាជ្ញាយុកាល នោះការពិតដែលច្បាប់ត្រូវតែអនុវត្តនៅក្នុងប្រទេសកម្ពុជាបានតម្រូវឲ្យអាជ្ញាយុកាលរបស់តុលាការខ្មែរក្រហមអនុវត្តតាមច្បាប់កម្ពុជា ។

លោក ម៉ៃឃើល ខាណាវ៉ាស បានបន្តធ្វើអំណះអំណាងរបស់លោកដោយលើកឡើងពីបញ្ហាទីពីរដែលចៅក្រមបានចោទសួរ ។ លោកបានអះអាងថា ការអនុវត្តច្បាប់កម្ពុជានៅតុលាការខ្មែរក្រហមនិងកង្វះខាតការកាត់ផ្តាច់អាជ្ញាយុកាលសម្រាប់ការរំលោភបំពានធ្ងន់ធ្ងរនៅក្នុងច្បាប់បង្កើតតុលាការខ្មែរក្រហមបានតម្រូវឲ្យចៅក្រមពឹងផ្អែកលើសេចក្តីណែនាំរបស់ក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ដែលបានកំណត់អាជ្ញាយុកាលនេះឲ្យមានរយៈពេលត្រឹមដប់ឆ្នាំសម្រាប់បទល្មើសឧក្រិដ្ឋ ។ ដោយសារតែមាត្រា៥៩នៃច្បាប់បង្កើតតុលាការខ្មែរក្រហមកំណត់ឲ្យមានការដាក់ទោសកម្រិតទាបបំផុតសម្រាប់ឧក្រិដ្ឋកម្មទាំងអស់ដែលត្រូវបានកាត់ទោសដោយតុលាការខ្មែរក្រហមមកនៅត្រឹមការជាប់ពន្ធធនាគាររយៈពេលប្រាំឆ្នាំ នោះការរំលោភបំពានធ្ងន់ធ្ងរអាចចាត់ទុកជាបទល្មើសឧក្រិដ្ឋ ហើយតម្រូវឲ្យដើរតាមអាជ្ញាយុកាលដែលមានរយៈពេលដប់ឆ្នាំ បើយោងតាមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ។

ដោយព្រួយបារម្ភខ្លាចថាលោកបាន «សង្កត់ធ្ងន់តែចំណុចដដែលនេះជ្រុលពេក» (ដែលនេះគឺជាការព្រួយបារម្ភមួយដែលលោកបានលើកឡើងជាច្រើនដងនៅក្នុងដំណើរការនីតិវិធីសម្រាប់ថ្ងៃនេះ) លោក ម៉ៃឃើល ខាណាវ៉ាស បានបញ្ឈប់ការពិភាក្សាបន្ថែមលើបញ្ហានេះ ហើយងាកមកបកស្រាយបញ្ហាទីមួយដែលចោទសួរដោយចៅក្រម ។ បន្ទាប់ពី «កោតសរសើរ» ចំពោះការវិវឌ្ឍច្បាប់ចាប់តាំងពីឆ្នាំ១៩៧៩មក ដើម្បីកាត់ផ្តាច់ការរំលោភបំពានធ្ងន់ធ្ងរចេញពីការអនុវត្តនៃអាជ្ញាយុកាលមក លោក ម៉ៃឃើល ខាណាវ៉ាស បាននិយាយថា ការវិវឌ្ឍនៃច្បាប់នេះមិនកើតឡើងនៅក្នុងចន្លោះឆ្នាំ១៩៧៥-១៩៧៩ទេ ។ លោកបានលើកឡើងនូវឧទាហរណ៍មួយចំនួនដែលលោកអះអាងថាអាចឆ្លុះបញ្ចាំងឲ្យឃើញថា ការមិនអនុវត្តតាមអាជ្ញាយុកាលសម្រាប់ការរំលោភបំពានធ្ងន់ធ្ងរមិនក្លាយជាច្បាប់គោលការណ៍ទំនៀមទម្លាប់អន្តរជាតិនៅឡើយទេសព្វថ្ងៃនេះ ។ លោកបាននិយាយថា ភាគច្រើនឧទាហរណ៍ទាំងអស់នេះគឺដកស្រង់ចេញពីការការពារក្តីរបស់ប្រទេសបារាំងទាក់ទងនឹងអាជ្ញាយុកាលរយៈពេលម្ភៃឆ្នាំសម្រាប់ឧក្រិដ្ឋកម្មសង្គ្រាមដែលមិនត្រូវបានចាត់ចូលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ បន្ទាប់មកទៀត លោកម៉ៃឃើល ខាណាវ៉ាស បានអះអាងថា ដោយសារតែការមិនអនុវត្តអាជ្ញាយុកាលទៅលើការរំលោភបំពានធ្ងន់ធ្ងរមិនមែនជាច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅចន្លោះឆ្នាំ១៩៧៥-១៩៧៩ នោះអាជ្ញាយុកាលរយៈពេលដប់ឆ្នាំសម្រាប់បទល្មើសឧក្រិដ្ឋត្រូវតែអនុវត្តតាមច្បាប់កម្ពុជាដែលមិនអនុញ្ញាតឲ្យមានការកាត់ទោសជនជាប់ចោទ អៀង សារី សម្រាប់ការចោទប្រកាន់ពីបទរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឡើយ ។

## ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាទៅកាន់ការបដិសេធបឋមលើបញ្ហាអាជ្ញាយុកាលទាក់ទងនឹងការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ

ជាការឆ្លើយតបនឹងការធ្វើអំណះអំណាងផ្ទាល់មាត់របស់មេធាវីការពារក្តី លោក ចាន់ តារារស្មី សហព្រះរាជអាជ្ញារងបានអះអាងថា អាជ្ញាយុកាលទាក់ទងនឹងការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ មិនត្រូវបានទទួលស្គាល់ជាផ្លូវការក្រោម

ច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅចន្លោះឆ្នាំ១៩៧៥-១៩៧៩ទេ ។ លោកបានជំទាស់ថា ដោយសារតែអនុសញ្ញាទីក្រុងហ្សឺណែវបានឈានមកដល់កម្រិតច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅឆ្នាំ ១៩៧៥ នោះការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទាំងអស់នេះបានឈានទៅដល់ឋានៈឧក្រិដ្ឋកម្មនៃគោលការណ៍ទំនៀមទម្លាប់អន្តរជាតិដែលថែងថា អាជ្ញាយុកាលមិនអាចយកមកអនុវត្តបានទេ ។ យោងតាមសម្ដីរបស់លោក ចាន់ តាភារស្មី អនុសញ្ញាទីក្រុងហ្សឺណែវមិនបង្គាប់ថា រដ្ឋអាចដាក់កម្រិតលើកាតព្វកិច្ចរបស់ខ្លួនក្នុងការកាត់ទោសនិងដាក់ទោសសម្រាប់ការរំលោភបំពានធ្ងន់ធ្ងរទេ ។ មានតែអាជ្ញាយុកាលទេដែលអាចដាក់កម្រិតលើកាតព្វកិច្ចកាត់ទោសនេះបាន ។ លោក ចាន់ តាភារស្មី បានសន្និដ្ឋានបញ្ចប់ដោយជំរុញឲ្យចៅក្រមគោរពទៅតាមសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះដែលកំណត់ថាអាជ្ញាយុកាលរបស់កម្ពុជាមិនមានជាប់ពាក់ព័ន្ធនឹងការរំលោភបំពានធ្ងន់ធ្ងរ បើយោងតាមអនុសញ្ញាទីក្រុងហ្សឺណែវ ។

ការិយាល័យរបស់សហព្រះរាជអាជ្ញាបានបន្តធ្វើការឆ្លើយតបរបស់ខ្លួនដោយផ្ដោតលើមាត្រា៦នៃច្បាប់បង្កើតតុលាការខ្មែរក្រហម ។ ផ្ទុយពីការអះអាងដោយក្រុមមេធាវីការពារក្ដីដែលនិយាយថាមាត្រា៦ ចាត់ទុកការគ្រប់គ្រងជាបទឧក្រិដ្ឋនោះ លោកសហព្រះរាជអាជ្ញាក៏បានអះអាងថា មាត្រា៦នេះបានផ្ដល់ជាយុត្តាធិការ និងអនុញ្ញាតឲ្យចៅក្រមពឹងផ្អែកលើអនុសញ្ញាទីក្រុងហ្សឺណែវ ដើម្បីកំណត់និងគូសបញ្ជាក់ពីការរំលោភបំពានធ្ងន់ធ្ងរ ។ លោកក៏បានកត់សម្គាល់ថាការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ គឺគ្រាន់តែជាប្រភេទមួយនៃឧក្រិដ្ឋកម្មដែលមានកាតព្វកិច្ចហ្មត់ចត់ និងវិជ្ជមានក្នុងការកាត់ទោស ។ នៅពេលដែលកាតព្វកិច្ចវិជ្ជមានសម្រាប់ការកាត់ទោសកើតមានឡើងនោះ រដ្ឋមិនអាចគេចវេះពីការទទួលខុសត្រូវក្នុងការកាត់ទោសនេះដោយផាកមកអនុវត្តច្បាប់ក្នុងស្រុកដូចជាអាជ្ញាយុកាលនេះជាដើម ។ លោកសហព្រះរាជអាជ្ញារងក៏បានសន្និដ្ឋានបញ្ចប់ដោយនិយាយថា គោលបំណងរបស់មេធាវីការពារក្ដីជនជាប់ចោទក្នុងការបង្កឲ្យមានភាពខុសគ្នារវាងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនិងការរំលោភបំពានធ្ងន់ធ្ងរ គឺមិនត្រឹមត្រូវទេ ។ លោកបានអះអាងថា «ច្បាប់ទំនៀមទម្លាប់អន្តរជាតិមិនបង្កើតឋានានុក្រមបែបនេះទេ» ហើយឧក្រិដ្ឋកម្មទាំងអស់នេះមិនត្រូវបានយកមកអនុវត្តចំពោះមុខច្បាប់តាមវិធីសាស្ត្រដូចគ្នាទេ ។

លោកប្រធានចៅក្រម និល ណុន បានបញ្ចប់ការពិភាក្សាលើការរំលោភបំពានធ្ងន់ធ្ងរសម្រាប់ដំណើរការនីតិវិធីត្រង់ចំណុចនេះ ដោយទុកឲ្យមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីធ្វើការឆ្លើយតបលើបញ្ហានេះនៅថ្ងៃពុធ ទី២៩ ខែមិថុនា ។

## ការគូសបញ្ជាក់លើការស្នើសុំរបស់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី

យ៉ាងណាមិញ មុននឹងបញ្ចប់ដំណើរការនីតិវិធីនៅក្នុងថ្ងៃនេះ ចៅក្រមបានអនុញ្ញាតឲ្យលោកស្រី អេលីហ្សាប៊ែត ស៊ីម៉ូណូ ហូត មានឱកាសធ្វើការគូសបញ្ជាក់លើការស្នើសុំរបស់លោកស្រីដែលបានលើកឡើងនៅក្នុងអំឡុងដំណើរការនីតិវិធីកាលពីថ្ងៃច័ន្ទទាក់ទិននឹងបញ្ជីរាយនាមដើមបណ្ដឹងរដ្ឋប្បវេណី ។ បន្ទាប់ពីធ្វើការកត់សម្គាល់លើសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះដែលអនុញ្ញាតទទួលស្គាល់ដើមបណ្ដឹងរដ្ឋប្បវេណីចំនួន១.៨០០នាក់បន្ថែមចូលក្នុងដំណើរការនីតិវិធីនេះមក លោកស្រីបានស្នើសុំការពន្យារពេលពីរខែសម្រាប់ការដាក់ជូនចៅក្រមនូវបញ្ជីរាយនាមដើមបណ្ដឹងរដ្ឋប្បវេណីដែលជ្រើសរើសយកដើមបណ្ដឹងរដ្ឋប្បវេណីណាដែលនឹងធ្វើសក្ខីកម្មនៅចំពោះមុខចៅក្រម ។ លោកស្រីបានអះអាងថារយៈពេលពីរខែនេះត្រូវការជាចាំបាច់ដើម្បីកំណត់ថាតើដើមបណ្ដឹងរដ្ឋប្បវេណីណាខ្លះដែលអាចផ្ដល់សក្ខីកម្មដែលមានជាប់ពាក់ព័ន្ធនឹងរឿងក្ដីនេះជាងគេបង្អស់សម្រាប់តុលាការនេះ ពីព្រោះថាដើមបណ្ដឹងទាំង៣០០០នាក់មិនអាចធ្វើសក្ខីកម្មទាំងអស់គ្នាបានទេ ។ យ៉ាងណាមិញ លោកស្រីបាននិយាយថា ប្រធានមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីនឹងដាក់ជូនចៅក្រមនូវបញ្ជីរាយនាមដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់នៅថ្ងៃទីព្រហស្បតិ៍ ទី៣០ ខែមិថុនា ។

ក្រោយពីការលើកមានមតិរបស់លោកស្រី អេលីហ្សាប៊ែត ស៊ីម៉ូណូ ហូត ចៅក្រមបានពិភាក្សាគ្នាមួយរយៈពេល ហើយក៏សម្រេចផ្អាកដំណើរការនីតិវិធីថ្ងៃនេះ ដោយមិនចេញសេចក្ដីសម្រេចលើការស្នើសុំរបស់លោកស្រីប្រធានមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ។

**គ្រីស្ទីន អ៊ីវេន**

# ថ្ងៃដែលនិយាយពីអាជ្ញាយុកាល និងសំណងជំងឺចិត្ត

ក្រោយពីការចំណាយពេលពីរថ្ងៃពិភាក្សាពីការបដិសេធបឋមរបស់ជនជាប់ចោទ អៀង សារី មក នៅថ្ងៃទីបីនៃដំណើរការអង្គជំនុំជម្រះរបស់សំណុំរឿង០០២ បានផ្តល់ឱកាសឲ្យជនជាប់ចោទបីរូបផ្សេងទៀតគឺ នួន ជា, អៀង ធីរិទ្ធ និង ខៀវ សំផន លើកឡើងពីអំណះអំណាងរបស់ខ្លួនចំពោះការចោទប្រកាន់របស់សាលាក្តីខ្មែរក្រហមខណៈពេលដែលតុលាការបានចំណាយពេលមួយភាគធំនៃអង្គជំនុំជម្រះនេះពិភាក្សាពីការបដិសេធបឋមរបស់ជនជាប់ចោទទាក់ទិននឹងអាជ្ញាយុកាលរបស់តុលាការដែលមានជាប់ពាក់ព័ន្ធនឹងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ។ ប៉ុន្តែ ខណៈពេលដែលដំណើរការអង្គជំនុំជម្រះក្តីបានចាប់ផ្តើម យើងបានឃើញយ៉ាងច្បាស់ថា ក្រុមមេធាវីការពារក្តីរបស់ អៀង សារី នឹងឈរជាសំឡេងតែឯកឯងប្រឆាំងនឹងសហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី ។

ដោយសារតែការជជែកដេញដោលផ្នែកច្បាប់ឥតឈប់ឈរកាលពីម្សិលមិញនេះយើងអាចស្មានគិតទុកជាមុនថា នៅថ្ងៃនេះ សាធារណជនភាគច្រើនអាចនឹងមិនអញ្ជើញមកចូលរួមតាមដានដំណើរការអង្គជំនុំជម្រះក្តីនៅក្នុងបន្ទប់សវនាការក៏ថាបាន ។ ប៉ុន្តែផ្ទុយទៅវិញ មានសាធារណជនជាច្រើននាក់បានអញ្ជើញមកចូលរួមតាមដានអង្គជំនុំជម្រះរបស់តុលាការនាពេលព្រឹកនេះ ។ មាននិស្សិតសកលវិទ្យាល័យមួយក្រុមធំបានមកចូលរួមច្រើនជាងថ្ងៃច័ន្ទ និងថ្ងៃអង្គារ ប្រហែលជានិស្សិតទាំងអស់នោះត្រូវបាននាំមកចូលរួមតាមដានដំណើរការរបស់តុលាការជំនួសឲ្យចំនួនអ្នកអង្កេតបរទេសដែលបានថយចុះ ។ ខណៈពេលដែលសាធារណជនចូលទៅក្នុងសាលសវនាការ សន្តិសុខបានធ្វើការចាត់ចែងកន្លែងអង្គុយដល់សាធារណជន ដោយមានការប្រទាញប្រទង់គ្នាដែលតម្រូវឲ្យអ្នកតាមដានខ្លះផ្លាស់ពីកន្លែងមួយទៅកន្លែងមួយទៀត ហើយបណ្តាលឲ្យអ្នកតាមដានមួយចំនួនដើរចេញដោយភាពអាក់អន់ចិត្ត ។ យ៉ាងណាមិញ បើទោះបីជាមានការរំខានបន្តិចបន្តួចនេះក៏ដោយ ក៏អង្គសវនាការពោរពេញទៅដោយអ្នកតាមដានពេញមួយថ្ងៃតែម្តង ។

ជនជាប់ចោទទាំងបួនរូបមានវត្តមានសាជាថ្មីម្តងទៀតនាពេលចាប់ផ្តើមដំបូងនៃអង្គនីតិវិធី បើទោះបីជាដូចកាលពីម្សិលមិញនេះ នួន ជា និង អៀង សារី បានចាកចេញពីបន្ទប់សវនាការក៏ដោយ ។ ក្រោយអង្គជំនុំជម្រះក្តីនាពេលព្រឹកបានបញ្ចប់ផុតទៅ មានតែជនជាប់ចោទពីររូបទេគឺ អៀង ធីរិទ្ធ និង ខៀវ សំផន ដែលនៅមានវត្តមាននៅក្នុងបន្ទប់សវនាការ ហើយស្ថានភាពបែបនេះអាចនឹងបន្តរហូតដល់ដំណើរការនីតិវិធីនៅថ្ងៃពុធ ។



និស្សិតសាកលវិទ្យាល័យកំពុងដើរចូលបន្ទប់សវនាការ

ក្នុងគោលបំណងចាប់ផ្តើមអង្គជំនុំជម្រះក្តីតាមពេលវេលាកំណត់ ចៅក្រមបានមានវត្តមាននៅក្នុងបន្ទប់សវនាការនៅវេលាម៉ោងប្រាំបួនត្រឹមនាពេលព្រឹក

នេះ ។ លោកប្រធានចៅក្រម និល ណុន បានចាប់ផ្ដើមដំណើរនីតិវិធី ហើយបានផ្ទេរភារកិច្ចឲ្យមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់បន្តអំណះអំណាងផ្ទាល់មាត់របស់ខ្លួនស្ដីពីភាពជាប់ពាក់ព័ន្ធរបស់អាជ្ញាយុកាលទៅនឹងការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ដែលត្រូវបានលើកឡើងកាលពីម្សិលមិញនេះ ។

មុននឹងមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីបានចាប់ផ្ដើម នួន ជា បានក្រោកឈរឡើង ហើយក៏ត្រូវបានកត់សម្គាល់ដោយអង្គសវនាការទាំងមូល ។ ដូចកាលពីម្សិលមិញ នួន ជា បានស្នើសុំវិលត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញដោយសារតែអង្គជំនុំជម្រះនេះជាប់ពាក់ព័ន្ធតែរឿងក្ដីរបស់ អៀង សារី ម្នាក់គត់ ហើយមិនមានជាប់ពាក់ព័ន្ធអ្វីនឹងរឿងក្ដីរបស់គាត់ឡើយ ។ ដូច្នេះ នួន ជា បាននិយាយថា គាត់នឹងវិលត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ ហើយនឹងចូលរួមយ៉ាងសកម្មនៅពេលដែលអង្គជំនុំជម្រះមានជាប់ពាក់ព័ន្ធនឹងរឿងក្ដីរបស់គាត់ ។ ដោយយោងតាមវិធានផ្ទៃក្នុង ៨១(៤) របស់សាលាក្ដីខ្មែរក្រហម លោកប្រធានចៅក្រម និល ណុន បានយល់ថាការស្នើសុំរបស់ នួន ជា មានខ្លឹមសារពាក់ព័ន្ធ ហើយក៏យល់ព្រមទទួលយកការស្នើសុំរបស់ នួន ជា ។ ដោយពិចារណាឃើញថាតុលាការបានរៀបចំឲ្យមានការសួរដេញដោលផ្ទាល់មាត់ដោយជនជាប់ចោទទាំងអស់ទាក់ទិននឹងបញ្ហាអាជ្ញាយុកាលនៃបទល្មើសក្នុងស្រុកដែលត្រូវបានចោទប្រកាន់នោះ ការថ្លែងរបស់ នួន ជា ដែលថាអង្គសវនាការអាចនឹងមិនមានជាប់ពាក់ព័ន្ធនឹងរឿងក្ដីរបស់គាត់បានគូសបញ្ជាក់ឲ្យឃើញថា ក្រុមមេធាវីការពារក្ដីរបស់ នួន ជា នឹងមិនចូលរួមនៅក្នុងដំណើរការនីតិវិធីថ្ងៃនេះទេ ។

មុននឹងអង្គជំនុំជម្រះសាលាដំបូងអាចងាកមកស្ដាប់ភាគីមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីបាន សហមេធាវីអន្តរជាតិរបស់ អៀង ធីរិទ្ធ គឺលោកស្រី ដាយណា អេលីស បានស្នើសុំផ្ញើសំណូមពរមួយនៅចំពោះមុខតុលាការ ។ ដំបូង លោកស្រីបានកត់សម្គាល់ថាតុលាការបានគូសបញ្ជាក់ប្រាប់ដល់ភាគីទាំងអស់ក្នុងអំឡុងដំណើរការនីតិវិធីកាលពីថ្ងៃអង្គារថា អង្គសវនាការអាចចាំបាច់ត្រូវពន្យារពេលដល់ថ្ងៃសុក្រ ទី១ ខែកក្កដា ដោយសារតែតុលាការមានភាពយឺតយ៉ាវជាងការកំណត់ ។ ដោយថ្លែងថាលោកស្រីត្រូវវិលត្រឡប់ទៅកាន់អឺរ៉ុបវិញនៅយប់ថ្ងៃព្រហស្បតិ៍ លោកស្រីអេលីស បានស្នើសុំឲ្យតុលាការកំណត់ពេលវេលានៃអង្គសវនាការឲ្យបានច្បាស់ ដើម្បីឲ្យការបដិសេធលើបញ្ជីឈ្មោះសាក្សីអាចនឹងត្រូវបានលើកឡើងយកមកពិភាក្សានៅថ្ងៃព្រហស្បតិ៍បាន ។ លោកប្រធានចៅក្រម និល ណុន បានឆ្លើយតបថា តុលាការរំពឹងឲ្យមេធាវីគ្រប់ភាគីទាំងអស់មានវត្តមាននៅថ្ងៃសុក្រ ប្រសិនបើអង្គសវនាការនឹងត្រូវពន្យារពេលមែននោះ ។ ប៉ុន្តែ លោកប្រធានក៏មានប្រសាសន៍ថា តុលាការ «បានស្ដាប់ឮសំណូមពររបស់លោកស្រី» ហើយនឹងធ្វើការពិចារណាលើសំណូមពរនេះ ។

## ការឆ្លើយតបរបស់ដើមបណ្ដឹងរដ្ឋប្បវេណីទៅនឹងការបដិសេធបឋមលើអាជ្ញាយុកាលទាក់ទិននឹងការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ

ក្រោយពីបញ្ហាបឋមទាំងអស់នេះមក មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីបានចាប់ផ្ដើមបន្តអំណះអំណាងផ្ទាល់មាត់របស់ខ្លួនដែលស្ដីពីការជាប់ពាក់ព័ន្ធនៃអាជ្ញាយុកាលទៅនឹងការរំលោភធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ។ សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីទីមួយបានអះអាងថា អំណះអំណាងរបស់មេធាវីការពារក្ដីស្ដីពីបញ្ហាខាងលើនេះមិនមានជាប់ពាក់ព័ន្ធនឹងច្បាប់បង្កើតសាលាក្ដីខ្មែរក្រហមឡើយ ។ លោកបានបញ្ជាក់ថា អ្នកតាក់តែងច្បាប់នេះបានយល់ដឹងច្បាស់ពីក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ខណៈពេលដែលច្បាប់បង្កើតសាលាក្ដីខ្មែរក្រហមត្រូវបានតាក់តែងឡើង ។ មេធាវីការពារក្ដីអះអាងថា ការព្រងើយកន្តើយនឹងអាជ្ញាយុកាលដែលមានចែងនៅក្នុងមាត្រា៦នៃច្បាប់បង្កើតសាលាក្ដីខ្មែរក្រហមគឺជាការគូសបញ្ជាក់ឲ្យឃើញថាអាជ្ញាយុកាលមានភាពពាក់ព័ន្ធនឹងការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ។ មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីបានជំទាស់ថា ការអះអាងរបស់មេធាវីការពារក្ដីជនជាប់ចោទបណ្ដាលឲ្យមាន «លទ្ធផលមិនសមហេតុផល» មួយ ៖ ប្រសិនបើអាជ្ញាយុកាលមានជាប់ពាក់ព័ន្ធនឹងការរំលោភបំពានធ្ងន់ធ្ងរនោះ គ្មានជនជាប់ចោទណាម្នាក់អាចនឹងត្រូវបានកាត់ទោសសម្រាប់ឧក្រិដ្ឋកម្មទាំងអស់នេះទេ ហើយជាក់ស្ដែងបំផុតនោះគឺថា ឧក្រិដ្ឋកម្មទាំងអស់នេះត្រូវបានជំនុំជម្រះក្ដីដោយតុលាការកាត់ទោសកាលពីឆ្នាំ១៩៧៩រួចហើយដែរ ។ ហើយ

តុលាការនេះមានរយៈពេលជប់បួនឆ្នាំមុនពេលច្បាប់បង្កើតសាលាក្តីខ្មែរក្រហមត្រូវបានគាត់តែងឡើងទៅទៀតនោះ ។ លោកបានជំទាស់ថាអ្នកតាក់តែងច្បាប់អាចនឹងមិនចាំបាច់ដាក់បញ្ចូលបទបញ្ញត្តិនៃការរំលោភបំពានធ្ងន់ធ្ងរក៏បាន ប្រសិនបើអ្នកតាក់តែងច្បាប់ទាំងអស់នោះបានរំពឹងថាអាជ្ញាយុកាលដែលមានរយៈពេលជប់ឆ្នាំអាចនឹងជាប់ពាក់ព័ន្ធនឹងការរំលោភបំពានធ្ងន់ធ្ងរនោះ ។

បន្ទាប់មកទៀត សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីទីពីរបានបន្តលើកឡើងពីអំណះអំណាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីដោយទទួលស្គាល់ថាការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ បានឈានមកដល់ដំណាក់កាលគោលការណ៍ទំនៀមទម្លាប់អន្តរជាតិតាំងពីឆ្នាំ១៩៧៩មកម្ល៉េះ ។ លោកស្រីបានថ្លែងថា គោលការណ៍ទំនៀមទម្លាប់អន្តរជាតិគឺជាគោលការណ៍ទាំងឡាយណាដែលមិនអនុញ្ញាតឲ្យមានការតាំងបទបញ្ញត្តិប្រឆាំងដែលហេតុផលនេះបង្កជា «ករណីយកិច្ចដែលមិនអាចប្រកែកតវ៉ាបាន» មួយដែលជាប់ពាក់ព័ន្ធនឹងប្រទេសជាភាគីទាំងអស់ ។ នៅក្នុងចន្លោះឆ្នាំ១៩៧៥-១៩៧៩ ប្រទេសជាសមាជិករបស់អង្គការសហប្រជាជាតិចំនួន៩៦ភាគរយជាសមាជិកនៃអនុសញ្ញាទីក្រុងហ្សឺណែវ ។ ចំណែកប្រទេសកម្ពុជាក៏បានក្លាយជាភាគីមួយនៃអនុសញ្ញាទីក្រុងហ្សឺណែវនៅឆ្នាំ១៩៥៨ ដោយគ្មានការត្រៀមទុកបទបញ្ញត្តិបម្រុងណាមួយឡើយ ។ លោកមេធាវីបានបន្តអះអាងថាការគាំទ្រសម្រាប់អនុសញ្ញាទីក្រុងហ្សឺណែវនេះបានពង្រឹងឋានៈនៃអនុសញ្ញាទាំងអស់នោះឲ្យក្លាយជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ ហើយផ្តល់ជាគោលការណ៍ទំនៀមទម្លាប់អន្តរជាតិមួយសម្រាប់ការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទាំងអស់នេះ ។ ដោយលើកឡើងពីអនុសញ្ញាទីក្រុងវីយែនឆ្នាំ១៩៦៩ស្តីពីច្បាប់សន្ធិសញ្ញានោះ លោកស្រីមេធាវីបានទទួលស្គាល់ថា គោលការណ៍ទំនៀមទម្លាប់អន្តរជាតិអាចនឹងមិនមានលក្ខណៈត្រឹមត្រូវតាមផ្លូវច្បាប់ដោយសារតែគោលការណ៍ដែលមានកម្រិតដូចគ្នា ហើយអាចនឹងមានលក្ខណៈត្រឹមត្រូវតាមផ្លូវច្បាប់ដោយសារលក្ខន្តិកៈនីតិវិធីក្នុងស្រុកដែលមានលក្ខណៈផ្ទុយគ្នា ។ លោកស្រីមេធាវីបានអះអាងថា បទបញ្ញត្តិអាជ្ញាយុកាលរបស់ក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦មានផលប៉ះពាល់ដល់លក្ខណៈនៃគោលការណ៍ទំនៀមទម្លាប់អន្តរជាតិនៃការរំលោភបំពានធ្ងន់ធ្ងរ និងកាតព្វកិច្ចឆ្លើយតបទៅនឹងការកាត់ទោស ។ ដូច្នេះ លោកស្រីបានសន្និដ្ឋានថា ក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦មិនអាចយកមកអនុវត្តសម្រាប់ការរំលោភបំពាន



អតីតអ្នកទោសមន្ទីរស-២១ ប៊ូ ម៉េង កំពុងផ្តល់បទសម្ភាសដល់អ្នកសារព័ត៌មាន

ធ្ងន់ធ្ងរដែលមានចែងនៅក្នុងមាត្រា៦ នៃច្បាប់បង្កើតសាលាក្ដីខ្មែរក្រហមឡើយ ។

សម្រាប់ការអះអាងបញ្ចប់របស់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីស្ដីពីបញ្ហាខាងលើនេះ សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីទីបីបានធ្វើការសង្កត់ធ្ងន់ឡើងវិញលើអំណះអំណាងរបស់សហមេធាវីដទៃទៀត ។ លោកមេធាវីបានលើកឡើងពីកត្តាដែលថាអនុសញ្ញាទីក្រុងហ្សឺណែវត្រូវបានព្រងើយកន្ដើយមានជាប់ពាក់ព័ន្ធនឹងបញ្ហាអាជ្ញាយុកាលស្ដីពីការរំលោភបំពានធ្ងន់ធ្ងរ ហើយលោកបានកត់សម្គាល់ឃើញថា គ្មានការត្រៀមទុកនូវបទបញ្ញត្តិណាមួយត្រូវបានធ្វើឡើងដោយប្រទេសជាភាគីរបស់អនុសញ្ញានេះដើម្បីទាញភ្ជាប់វាមកជាមួយនឹងបញ្ហាអាជ្ញាយុកាលនោះទេ ។ លោកបានអះអាងថា កត្តាទាំងអស់នេះបានគាំទ្រការអះអាងដែលថា បញ្ហាអាជ្ញាយុកាលមិនមានជាប់ពាក់ព័ន្ធនឹងការរំលោភបំពានធ្ងន់ធ្ងរនោះទេ ហើយលោកមេធាវីបានជំរុញឲ្យចៅក្រមបដិសេធមិនទទួលយកមតិជំទាស់របស់ក្រុមមេធាវីការពារក្ដីជនជាប់ចោទ ។

## ការឆ្លើយតបរបស់ អៀង សារី ទៅកាន់សហព្រះរាជអាជ្ញា និងដើមបណ្ដឹងរដ្ឋប្បវេណីស្ដីពីការរំលោភបំពានធ្ងន់ធ្ងរ

ដោយស្ថិតក្នុងសភាពទ្រុឌទ្រោមបន្ទាប់ពីការជជែកដេញដោលដ៏ទូលំទូលាយអស់រយៈពេលពីរកន្លងមក សហមេធាវីអន្ដរជាតិរបស់ អៀង សារី គឺលោក ម៉ៃឃើល ខាណាវ៉ាស បានក្រោកឈរឡើងធ្វើការឆ្លើយតបនឹងសេចក្ដីជំទាស់របស់សហព្រះរាជអាជ្ញា និងមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ។ លោកបាននិយាយថា បទបង្ហាញរបស់សហព្រះរាជអាជ្ញា និងមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីពិតជា «អស្ចារ្យ» ហើយអាចនឹងគួរឲ្យជឿ ។ ប៉ុន្ដែលោកបានលើកឡើងពីការជំទាស់ត្រង់មួយចំណុចថា ៖ «យើងសូមជំទាស់នឹងត្រង់ចំណុចដែលថា ការរំលោភបំពានធ្ងន់ធ្ងរបានឈានដល់គោលការណ៍ទំនៀមទម្លាប់អន្ដរជាតិនៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ។ ក្រោយពីបានលើកឡើងពីកិច្ចព្រមព្រៀងមួយចំនួនតូចរបស់ប្រទេសជាភាគីរបស់អនុសញ្ញាទីក្រុងហ្សឺណែវដែលធ្វើឡើងកាលពីឆ្នាំ១៩៦៨ ស្ដីពីការមិនមានជាប់ពាក់ព័ន្ធនឹងបញ្ហាអាជ្ញាយុកាលសម្រាប់ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅឆ្នាំ១៩៧៥ លោកមេធាវីការពារក្ដីបានអះអាងថា ក្នុងអំឡុងពេលនោះមានការជជែកដេញដោលគ្មានឥតឈប់ឈរស្ដីពីការជាប់ពាក់ព័ន្ធនៃអាជ្ញាយុកាលទៅនឹងការរំលោភបំពានធ្ងន់ធ្ងរដែលបណ្ដាលឲ្យមានផលប៉ះពាល់ដល់ឋានៈក្នុងសមាសធាតុជាឧក្រិដ្ឋកម្មដែលស្របតាមគោលការណ៍ទំនៀមទម្លាប់អន្ដរជាតិរបស់ការរំលោភបំពានធ្ងន់ធ្ងរនេះ ។ ដោយធ្វើការឆ្លើយតបយ៉ាងសង្ខេប លោកមេធាវី ខាណាវ៉ាស បានសន្និដ្ឋានបញ្ចប់ដោយលើកឡើងពីការដាក់សេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់ភាគីដើមបណ្ដឹងរដ្ឋប្បវេណីស្ដីពីបញ្ហានេះ ហើយបានជម្រាបចៅក្រមថា «ខ្ញុំជឿជាក់យ៉ាងច្បាស់ថាចៅក្រមនឹងឈានទៅរកសេចក្ដីសម្រេចមួយដែលត្រឹមត្រូវ» ។

ការជជែកដេញដោលផ្ទាល់មាត់ស្ដីពីការបដិសេធបឋមរបស់ជនជាប់ចោទលើបញ្ហាអាជ្ញាយុកាលទាក់ទិននឹងបទល្មើសទាំងឡាយណាដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ។

បន្ទាប់មកទៀត ចៅក្រមបានងាកមកស្ដាប់ការបដិសេធបឋមចុងក្រោយដែលនឹងត្រូវជជែកដេញដោលនៅក្នុងអង្គសវនាការដំបូងទាំងនេះ ៖ អាជ្ញាយុកាលទាក់ទិននឹងបទល្មើសដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ (ក្រមឆ្នាំ១៩៥៦) ។ ជនជាប់ចោទទាំងបួនរូបនេះត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មមនុស្សឃាត ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញផ្នែកសាសនាក្រោមក្រមឆ្នាំ១៩៥៦ ហើយជនជាប់ចោទទាំងបួនរូបនេះបានដាក់ជូនការបដិសេធជាលាយលក្ខណ៍អក្សររបស់ខ្លួនដល់ចៅក្រមដោយផ្អែកលើអង្គហេតុដែលថាអាជ្ញាយុកាលដែលមានចែងនៅក្នុងក្រមឆ្នាំ១៩៥៦ នេះមិនអនុញ្ញាតឲ្យមានការកាត់ទោសលើបទចោទប្រកាន់ទាំងអស់នេះឡើយ ។ ចៅក្រមបានប្រគល់ពេលវេលាពីរម៉ោងសម្រាប់សេចក្ដីជំទាស់របស់មេធាវីការពារក្ដីទាំងអស់ដោយមេធាវីការពារក្ដីមួយក្រុមទទួលបានរយៈពេលសាមសិបនាទីសម្រាប់ការដាក់សេចក្ដីសន្និដ្ឋានដោយផ្ទាល់មាត់របស់ខ្លួន ។

មុននឹងការឈានមកដល់នៃការជជែកដេញដោលដោយផ្ទាល់មាត់ លោកមេធាវីការពារក្ដី ម៉ៃឃើល ខាណាវ៉ាស បាន

ជម្រាបដល់អង្គសវនាការថាក្រុមមេធាវីរបស់ នួន ជា បានសម្រេចមិនមានមតិយោបល់ទាក់ទិននឹងបញ្ហាខាងលើនេះទេ ហើយសូមជូនវេទិកានេះដល់ក្រុមមេធាវីការពារក្តីរបស់ អៀង សារី ។ គ្មានការលើកឡើងពីហេតុផលសម្រាប់សេចក្តីសម្រេចចិត្តបែបនេះរបស់ក្រុមមេធាវីការពារក្តីរបស់ នួន ជា ឡើយ ហើយសេចក្តីសម្រេចចិត្តនេះបានធ្វើឲ្យចៅក្រម និងភាគីដទៃទៀតមានភាពឆ្ងើងឆ្ងល់ ។

**ការដេញដោលដោយផ្ទាល់មាត់របស់ក្រុមមេធាវីការពារក្តី**

ក្រោយមកទៀត លោកមេធាវី ខាណាវ៉ាស បានផ្ទេរវេទិកាទៅឲ្យសហមេធាវីរបស់គាត់គឺលោក អាង ឧត្តម ដើម្បីចាប់ផ្តើមអំណះអំណាងផ្ទាល់មាត់របស់មេធាវីការពារក្តី ។ ស្ថិតនៅក្រោមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ លោកបានធ្វើការបកស្រាយថា ឧក្រិដ្ឋកម្មមនុស្សឃាត ការធ្វើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញផ្នែកសាសនាគឺជាប្រធានបទនៃអាជ្ញាយុកាលរយៈពេលដប់ឆ្នាំដែលមិនអនុញ្ញាតឲ្យមានការកាត់ទោសសម្រាប់ឧក្រិដ្ឋកម្មទាំងអស់នេះឡើយក្រោយរយៈពេលដប់ឆ្នាំដែលឧក្រិដ្ឋកម្មទាំងអស់នេះត្រូវបានប្រព្រឹត្តឡើង ។ លោក អាង ឧត្តម បានជំរុញឲ្យចៅក្រមធ្វើការស្វែងយល់ថាអាជ្ញាយុកាលនេះមិនអនុញ្ញាតឲ្យមានការកាត់ទោសជនជាប់ចោទសម្រាប់ឧក្រិដ្ឋកម្មទាំងអស់នេះដូចដែលកំពុងធ្វើនាពេលបច្ចុប្បន្ននេះទេ ដោយសារតែរយៈពេលដែលស្ថិតនៅក្រោមឧក្រិដ្ឋកម្មក្នុងស្រុកដែលត្រូវបានគ្របដណ្តប់ដោយសាលាក្តីខ្មែរក្រហមបានហួសពេលកំណត់តាំងពីខែមករា ឆ្នាំ១៩៨៩ ម្ល៉េះ ។

ដោយវិលមកលើកឡើងពីច្បាប់បង្កើតសាលាក្តីខ្មែរក្រហម លោកមេធាវី អាង ឧត្តម បានពន្យល់ថា នៅពេលដែលច្បាប់បង្កើតសាលាក្តីខ្មែរក្រហមនេះត្រូវបានតាក់តែងឡើងនៅឆ្នាំ២០០១ មាត្រា៣នៃច្បាប់នេះបានផ្តល់យុត្តាធិការឲ្យសាលាក្តីខ្មែរក្រហមលើក្រមឆ្នាំ១៩៥៦ធ្វើការកាត់ទោសឧក្រិដ្ឋកម្មមនុស្សឃាត ការធ្វើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញផ្នែកសាសនា ហើយបានពង្រីកអាជ្ញាយុកាលលើក្រមនេះរយៈពេលម្ភៃឆ្នាំបន្ថែមទៀត ។ នៅឆ្នាំ២០០៤ មាត្រា៣ត្រូវបានធ្វើវិសោធនកម្ម ហើយបានប្រែក្លាយជាមាត្រា៣ថ្មីដើម្បីពង្រីកអាជ្ញាយុកាលរហូតដល់រយៈពេលសាមសិបឆ្នាំក្រោយពេលដែលឧក្រិដ្ឋកម្មទាំងអស់នេះត្រូវបានប្រព្រឹត្តឡើង ខណៈពេលដែលការពង្រីកអាជ្ញាយុកាលដើមអាចនឹងហួសពេលកំណត់មុននឹងការកាត់ទោសលើជនជាប់ចោទទាំងបួន ដោយសាលាក្តីខ្មែរក្រហមអាចចាប់ផ្តើម ។ លោក អាង ឧត្តម បានថ្លែងថា «ច្បាប់បង្កើតសាលាក្តីខ្មែរក្រហមហាក់ដូចជាត្រូវបានតាក់តែង ហើយកែប្រែឡើងវិញដើម្បីឲ្យអាជ្ញាយុកាលនេះគ្មានថ្ងៃនឹងហួសពេលកំណត់ទៅវិញទេ» ។ លោកបានអះអាងថាការពង្រីកអាជ្ញាយុកាលនេះបណ្តាលឲ្យមានបញ្ហាពីរសម្រាប់សាលាក្តីខ្មែរក្រហម ៖ ១) ការពង្រីកអាជ្ញាយុកាលនេះរំលោភលើគោលការណ៍នៃភាពត្រឹមត្រូវតាមផ្លូវច្បាប់ដែលមិនអនុញ្ញាតឲ្យមានការអនុវត្តប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ និង ២) រំលោភលើគោលការណ៍នៃការប្រតិបត្តិដោយសមភាពក្រោមផ្លូវច្បាប់ចំពោះជនជាប់ចោទនៅក្នុងអង្គសវនាការដែលថា សាលាក្តីខ្មែរក្រហមមិនអាចធ្វើការចោទប្រកាន់ជនជាប់ចោទពីបទឧក្រិដ្ឋកម្មទាំងអស់នេះឡើយ ។

លោក អាង ឧត្តម បាននិយាយថា បញ្ហានេះបានបង្កឲ្យមាន «ស្ថានភាពមិនឈ្នះចាញ់ផ្នែកនីតិវិធី» រវាងសហចៅក្រមស៊ើបអង្កេតទាំងអស់នៅក្នុងរឿងក្តីបច្ចុប្បន្ននេះ ។ នៅក្នុងដីកាដំណោះស្រាយរបស់ខ្លួន សហចៅក្រមស៊ើបអង្កេតបានថ្លែងថា សហចៅក្រមបានព្យាយាមចេញសេចក្តីសម្រេចជារួមមួយទាក់ទិននឹងបញ្ហានេះ ប៉ុន្តែអាក់ខានមិនបានចេញសេចក្តីសម្រេចនេះ ។ ចៅក្រមបានសម្រេចមិនអនុវត្តយន្តការដើម្បីដោះស្រាយជម្លោះប្រភេទនេះ ដោយជឿជាក់ថាវាអាច «បណ្តាលឲ្យមានផលប៉ះពាល់ដល់ដំណើរការផ្លូវច្បាប់ទាំងមូល» របស់សាលាក្តីខ្មែរក្រហម ហេតុដូច្នេះសហចៅក្រមស៊ើបអង្កេតបានសម្រេចផ្ទេរភារកិច្ចនេះជូនដល់អង្គជំនុំជម្រះសាលាដំបូងដើម្បីធ្វើការសម្រេចចាត់វិធានការនីតិវិធីដោះស្រាយបញ្ហានេះជំនួសវិញ ។

លោកបានសន្និដ្ឋានបញ្ចប់ដោយអះអាងថាការពង្រីកអាជ្ញាយុកាលស្ថិតនៅក្រោមមាត្រា៣ថ្មីនេះមិនមានជាប់ពាក់ព័ន្ធនឹងរឿងក្តីនាពេលបច្ចុប្បន្នទេ ពីព្រោះថា ក) សហចៅក្រមស៊ើបអង្កេតមិនបានយល់ព្រមលើការអនុវត្តរបស់ការពង្រីកអាជ្ញាយុកាលនេះ ហើយ ខ) ការអនុវត្តនៃការពង្រីកអាជ្ញាយុកាលនេះ

រំលោភលើសិទ្ធិចម្លងក្នុងការទទួលបានការប្រតិបត្តិដោយសមភាពនៅចំពោះមុខច្បាប់ និង គ) ការអនុវត្តនៃការពង្រីកអាជ្ញាយុកាលនេះរំលោភគោលការណ៍ច្បាប់ស្តីពីការគ្មានប្រតិសកម្មលើច្បាប់ព្រហ្មទណ្ឌ ។

មុននឹងអនុញ្ញាតឲ្យមេធាវីការពារក្តីរបស់ អៀង សារី ថ្លែងបន្ត លោកប្រធានចៅក្រម និល ណុន បានសួរទៅកាន់ក្រុមមេធាវីការពារក្តីផ្សេងទៀតឲ្យធ្វើការគូសបញ្ជាក់ម្តងទៀតថាតើក្រុមរបស់ខ្លួននឹងធ្វើឡើងមានមតិប្រឆាំងទាក់ទិននឹងបញ្ហានេះដែរឬទេ ដើម្បីឲ្យចៅក្រមអាចបែងចែកពេលវេលាសម្រាប់ការអះអាងនេះសាជាថ្មីម្តងទៀត ។ ក្រុមមេធាវីការពារក្តីរបស់ នួន ជា និង អៀង ធីរិទ្ធ បាននិយាយថាក្រុមរបស់ខ្លួននឹងមិនធ្វើការលើកឡើងពីអំណះអំណាងផ្ទាល់មាត់ទេ ពីព្រោះថាក្រុមមេធាវីទាំងអស់នេះបានដាក់ជូនសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររួចហើយ ។ សហមេធាវីកម្ពុជារបស់ ខៀវ សំផន គឺលោក ស សូវ៉ាន ទំនងជាមិនយល់សំណួរដោយសម្លឹងមើលទៅកាន់សហមេធាវីកម្ពុជាដទៃទៀតខាងក្រុមមេធាវីការពារក្តី ហើយនិយាយថា «ជូនកាលពាក្យដែលប្រើប្រាស់នៅក្នុងអង្គសវនាការមានលក្ខណៈបច្ចេកទេសពេក ហើយពិបាកយល់សម្រាប់ខ្ញុំ» ។ ថ្ងៃនេះ សហមេធាវីអន្តរជាតិរបស់ ខៀវ សំផន គឺលោក ហ្សាក់ វែរហេ្ស មិនមានវត្តមាននៅក្នុងបន្ទប់សវនាការទេ ។ ក្រោយពេលដែលចៅក្រមបានគូសបញ្ជាក់ពីសំណូមពរនេះហើយ លោកបាននិយាយថាភាគីរបស់លោកស្នើសុំរយៈពេលម្ភៃនាទីសម្រាប់ការលើកឡើងអំណះអំណាងរបស់ខ្លួន ដោយជំរុញឲ្យចៅក្រមប្រគល់ពេលវេលាដែលនៅសេសសល់ទាំងប៉ុន្មានដល់ក្រុមមេធាវីការពារក្តីរបស់ អៀង សារី ។

បន្ទាប់មកទៀត លោក ម៉ៃឃើល ខាណាវ៉ាស បានបន្តលើកឡើងពីអំណះអំណាងរបស់ខ្លួនដោយធ្វើការកត់សម្គាល់ថាលោកសូមអរគុណចំពោះភាពសប្បុរសធម៌របស់អង្គជំនុំជម្រះសាលាដំបូង ហើយធានាចៅក្រមថា លោកនឹងមិន «បំពានភាពសប្បុរធម៌នេះ» ឡើយ ដោយប្រើប្រាស់ពេលវេលាតាមការកំណត់ ។ បន្ទាប់មកទៀត លោក ខាណាវ៉ាស បានអះអាងថាក្រុមប្រឹក្សារដ្ឋធម្មនុញ្ញរបស់កម្ពុជាដែលបានកំណត់ថាការពង្រីកអាជ្ញាយុកាលនៅក្នុងមាត្រា៣ថ្មីនៃច្បាប់បង្កើតសាលាក្តីខ្មែរក្រហមថាជាច្បាប់រដ្ឋធម្មនុញ្ញនោះមានផ្ទុកកំហុសឆ្គង ។ យ៉ាងណាមិញ លោកបានទទួលស្គាល់ថា សាលាក្តីខ្មែរក្រហមជាពិសេសគឺអង្គជំនុំជម្រះសាលាដំបូងមិនអាចពិនិត្យឡើងវិញ ឬកែប្រែសេចក្តីសម្រេចនេះឡើយ ។

លោក ខាណាវ៉ាស បានងាកមកឆ្លើយតបសេចក្តីជំទាស់របស់សហព្រះរាជអាជ្ញាដែលមានចែងនៅក្នុងការដាក់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ ។ សហព្រះរាជអាជ្ញាបានជំទាស់ថា មាត្រា៣ថ្មីអាចយកមកអនុវត្តបាន ពីព្រោះថាអាជ្ញាយុកាលដែលស្ថិតនៅក្រោមក្រមឆ្នាំ១៩៥៦ត្រូវបានប្រកាសនៅចន្លោះឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩២ ហេតុដូច្នេះអាជ្ញាយុកាលត្រូវបានពង្រីកជាផ្លូវការមុនពេលកាលកំណត់ដំបូងហួសពេលកំណត់ទៅទៀត ។ លោក ខាណាវ៉ាស បានជំទាស់ថាអាជ្ញាយុកាលមិនត្រូវបានប្រកាសនៅក្នុងអំឡុងពេលនោះទេ ពីព្រោះក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ត្រូវបានដាក់ចូលជាធរមាន ហើយប្រព័ន្ធច្បាប់ក៏ត្រូវបានដំណើរការនៅក្នុងអំឡុងពេលនោះ ប៉ុន្តែរដ្ឋាភិបាលនៃរបបកម្ពុជាប្រជាធិបតេយ្យ និងរបបនៃព្រះរាជាណាចក្រកម្ពុជាថ្មីខ្វះឆន្ទៈនយោបាយក្នុងការស៊ើបអង្កេតលើការពង្រីកអាជ្ញាយុកាលនោះ ។ លោកបាននិយាយថា ដូចគ្នានឹងពេលបច្ចុប្បន្ននេះដែរ ប្រទេសកម្ពុជាកំពុងតែខ្វះឆន្ទៈនយោបាយក្នុងការស៊ើបអង្កេតលើសំណុំរឿង០០៣ និង០០៤ (នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា) ។ លោកបានអះអាងថា «ការខ្វះឆន្ទៈនយោបាយគឺមិនមែនជាករណីលើកលែងនោះទេ» សម្រាប់បញ្ហាអាជ្ញាយុកាលនោះ ។

លើសពីនេះទៅទៀត លោក ខាណាវ៉ាស បានឆ្លើយតបនឹងការអះអាងដែលថាការពង្រីកអាជ្ញាយុកាលមិនរំលោភលើគោលការណ៍ប្រតិសកម្មទេ ពីព្រោះថាការពង្រីកអាជ្ញាយុកាលនេះពាក់ព័ន្ធនឹងបញ្ហានីតិវិធីតែប៉ុណ្ណោះ មិនមែនបញ្ហាគោលការណ៍ច្បាប់នោះទេ ។ លោកបាននិយាយថា អាជ្ញាយុកាលមិនអនុញ្ញាតឲ្យមានការជំនុំជម្រះក្តី និងការកាត់ទោសតាមវិធីសាស្ត្រដែលប៉ះពាល់ដល់យុត្តិធម៌តាមគោលការណ៍ច្បាប់របស់ជនជាប់ចោទ ។ បន្ថែមលើនេះ លោកបានអះអាងថា ជនជាប់ចោទគឺ «មានសិទ្ធិ

ទទួលបានយុត្តិធម៌តាមនីតិវិធីដូចគ្នា និងយុត្តិធម៌តាមគោលការណ៍ច្បាប់» ។ យោងតាមហេតុផលទាំងអស់នេះ លោកមេធាវីការពារក្តីសូមជំរុញឲ្យចៅក្រមស្វែងយល់ឃើញថាអាជ្ញាយុកាលក្រោមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ មិនអនុញ្ញាតឲ្យមានការកាត់ទោស អៀង សារី សម្រាប់ឧក្រិដ្ឋកម្មក្នុងស្រុកដែល អៀង សារី ត្រូវបានចោទប្រកាន់នោះទេ ។

បន្ទាប់មកទៀត លោកមេធាវី ស សូវ៉ាន បានថ្លែងនូវអំណះអំណាងមិនច្បាស់លាស់របស់ខ្លួនដែលបណ្តាលឲ្យមានការផ្ទុះសំណើចពីសំណាក់អ្នកតាមដាននៅសាលសាធារណៈ និងភាពងឿងឆ្ងល់នៅក្នុងបន្ទប់សវនាការផ្ទាល់ ។ ក្នុងកាយវិការចាប់ម៉ៃក្រូហ្វូនដ៏រស់រវើក លោកមេធាវី ស សូវ៉ាន បានជំរុញឲ្យចៅក្រម និងសាធារណជនចងចាំថាកូនក្តីរបស់គាត់ ខៀវ សំផន គឺជាអតីតប្រធានប្រមុខរដ្ឋ ជាមុខតំណែងដែល ខៀវ សំផន ទទួលបន្តពីព្រះមហាក្សត្រកម្ពុជា នៅពេលដែលព្រះអង្គបានលាលែងចេញពីមុខតំណែងកាលពីខែមេសា ឆ្នាំ១៩៧៦ ហើយនៅក្នុងអំឡុងពេលនេះ ប្រទេសកម្ពុជាមានរដ្ឋធម្មនុញ្ញតែមួយគត់គឺរដ្ឋធម្មនុញ្ញខ្មែរក្រហម ។ បន្ទាប់មកទៀត លោកបានចាប់ផ្តើមប្រៀបធៀបកូនក្តីរបស់ខ្លួនទៅនឹងលោកប្រធានាធិបតីបារាំង លោក សាកូហ្ស៊ី ប៉ុន្តែបែរជាបោះបង់ចោលគំនិតប្រៀបធៀបនេះនៅពាក់កណ្តាលទី ហើយងាកមកនិយាយនៅចំពោះសាលសាធារណៈថា «ខ្ញុំមិនមែនកំពុងតែព្យាយាមការពារជនជាប់ចោទណាម្នាក់ឡើយ» ។

មកដល់ត្រង់ចំណុចនេះ លោកប្រធានចៅក្រម និល ណុន បានបង្អាក់សេចក្តីថ្លែងការណ៍របស់លោកមេធាវី ស សូវ៉ាន ហើយបានណែនាំថាលោកមេធាវីគ្រាន់តែត្រូវបានអនុញ្ញាតឲ្យធ្វើអំណះអំណាងផ្ទាល់មាត់នាពេលនេះស្តីពីបញ្ហាអាជ្ញាយុកាលដែលស្ថិតនៅក្រោមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ និងថាតើក្រមព្រហ្មទណ្ឌនោះមានជាប់ពាក់ព័ន្ធអ្វីខ្លះនៅចំពោះមុខសាលាក្តីខ្មែរក្រហមតែប៉ុណ្ណោះ ។ លោកប្រធានចៅក្រមបាននិយាយយ៉ាងច្បាស់ថា «នេះគឺជារបៀបវារៈសំខាន់» ។ ការថ្លែងរបស់លោកប្រធានចៅក្រមបានធ្វើឲ្យអ្នកសើចនៅក្នុងសាលសាធារណៈមានភាពស្ងប់ស្ងាត់ ។

លោក ស សូវ៉ាន បានបន្តសេចក្តីថ្លែងការណ៍ផ្ទាល់មាត់របស់ខ្លួន ហើយទំនងជាបានលើកឡើងពីបញ្ហាអាជ្ញាយុកាល ។ លោកបាននិយាយថា គ្រប់តុលាការទាំងអស់ត្រូវតែគោរពភាពគ្មានប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ ។ ប៉ុន្តែ ក្រោយមកទៀត លោកបែរជានិយាយចាកប្រធានដោយអះអាងថា «យើងសូមឲ្យសង្គមទាំងមូលធ្វើការអត់ឱនទោស និងបំភ្លេច ។ ឪពុករបស់ខ្ញុំបានស្លាប់ ហើយប្រសិនបើជនជាប់ចោទណាម្នាក់ត្រូវបានរកឃើញថាមានទោស នោះជនជាប់ចោទនោះគួរតែត្រូវបានកាត់ទោស និងដាក់ទោស» ។ លោកទំនងជានិយាយទៅកាន់អ្នកតាមដាននៅក្នុង



មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ម៉ាទីន ហ្សាកាំង និងសហមេធាវីដើម

សាលសាធារណៈ ដោយសន្និដ្ឋានបញ្ចប់ថា «ខ្ញុំមិនមែនព្យាយាមជួយនរណាម្នាក់ទេ ។ ខ្ញុំសូមឲ្យប្រជាជនកម្ពុជាទាំងអស់យល់ពីការពិត» ។ ខណៈពេលដែលលោក សូវ៉ាន អង្គុយចុះ អ្នកតាមដានជាច្រើនបាននាំគ្នាផ្ទុះសំណើច ស្របពេលដែលភាគីផ្សេងៗទៀតនៅក្នុងបន្ទប់សវនាការបាននាំគ្នាសម្លឹងមើលតុ ឬផ្ទាំងកញ្ចក់កុំព្យូទ័ររបស់ខ្លួន រង់ចាំដំណើរការនីតិវិធីចាប់ផ្តើមបន្ត ។

ក្នុងគោលបំណងបន្ធូរបន្ថយភាពតានតឹង លោកមេធាវីការពារក្តី អាង ឧត្តម បានក្រោកឈរឡើង ហើយសំណូមពរទៅ

ចៅក្រមអនុញ្ញាតឲ្យ អៀង សារី វិលត្រឡប់ទៅកាន់បន្ទប់រង់ចាំវិញដើម្បីចូលរួមក្នុងដំណើរការនីតិវិធីដែលនៅមានបន្តបន្ទាប់ទៀតតែម្នាក់ឯង ដោយសារបញ្ហាឈឺចង្កេះ ។ ចៅក្រមបានទទួលយកសំណូមពរនេះ ហើយស្នើសុំឲ្យសហព្រះរាជអាជ្ញាបន្តលើកឡើងពីអំណះអំណាងផ្ទាល់មាត់របស់ខ្លួន ។

**សហព្រះរាជអាជ្ញាឆ្លើយតបនឹងការបដិសេធបឋមរបស់ជនជាប់ចោទលើបញ្ហាអាជ្ញាយុកាលទាក់ទិននឹងបទល្មើសដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦**

លោកសហព្រះរាជអាជ្ញារងជាតិបានអះអាងថា អាជ្ញា



ហាមេធាវីដើមបណ្តឹងរដ្ឋប្បវេណីនាំមុខ អេលីហ្សាប៊ែត ស៊ីម៉ូណូ ហ្វូត

យុកាលអាចនឹងត្រូវបានពង្រីក ប្រសិនបើមានហេតុផលសមរម្យមួយចំនួនគាំទ្រ ។ នៅក្នុងករណីនេះ លោកបានលើកឡើងថាមានហេតុផលបីយ៉ាងដែលបញ្ជាក់ថាការពង្រីកអាជ្ញាយុកាលមានលក្ខណៈត្រឹមត្រូវតាមផ្លូវច្បាប់ក្រោមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ៖ ១)គ្មានអាជ្ញាយុកាលណាមួយត្រូវបានគាត់កែងឡើងនៅចន្លោះឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩២ឡើយ ។ ២)ក្នុងអំឡុងពេលដូចគ្នានោះគ្មានដំណើរការប្រព័ន្ធច្បាប់ត្រូវបានកើតមានឡើងឡើយ និង៣)ទាក់ទិននឹងកំហុសធ្ងន់របស់ជនជាប់ចោទ ។ លោកសហព្រះរាជអាជ្ញារងបានពន្យល់បកស្រាយថា ដោយសារតែចៅក្រម មេធាវី និងក្រុមអ្នកជំនាញវិជ្ជាជីវៈជាច្រើនត្រូវបានសម្លាប់បំផុតពូជដោយរបបខ្មែរក្រហម នោះប្រព័ន្ធច្បាប់របស់កម្ពុជានិងសមត្ថភាពរបស់ប្រជាជនកម្ពុជាទាំងមូលក្នុងការគាត់កែងប្រព័ន្ធច្បាប់ឡើងវិញត្រូវបានបំផ្លាញអស់រយៈពេលជាច្រើនឆ្នាំក្រោយពេលដែលរបបនេះបានដួលរលំផុតទៅ ។ លោកបាននិយាយថា «វាទាមទារពេលវេលាដ៏យូរដើម្បីធានាឲ្យមានការគាត់កែងប្រព័ន្ធច្បាប់អនុវត្តមួយដ៏រឹងមាំ» ។

លោកសហព្រះរាជអាជ្ញារងបានគូសបញ្ជាក់ពីអស្ថិរភាពក្នុងសង្គមរបស់កម្ពុជាក្រោយឆ្នាំ១៩៧៩ ដោយធ្វើការកត់សម្គាល់ថាសង្គ្រាមស៊ីវិលនៅតែគាមយាយីប្រទេសកម្ពុជាអស់រយៈពេលជាច្រើនឆ្នាំ ។ បើទោះបីជាមានកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស និងការបង្កើតឡើងនូវព្រះរាជាណាចក្រកម្ពុជាថ្មីនៅឆ្នាំ១៩៩៣ក៏ដោយ ក៏ការវាយប្រយុទ្ធគ្នានៅតែបន្តកើតមានដដែល ដែលការប្រយុទ្ធនេះផ្ទាល់មានការចូលរួមដឹកនាំយ៉ាងសកម្មពីសំណាក់ជនជាប់ចោទទាំងអស់នេះ ។ ការចរចាដើម្បីសន្តិភាពមានរយៈពេលយូរ ហើយការវាយប្រយុទ្ធគ្នាបានបញ្ចប់ជាស្ថាពរនៅឆ្នាំ១៩៩៨ នៅពេលដែលជនជាប់ចោទ នួន ជា និង ខៀវ សំផន បានយល់ព្រមចុះចូលជាមួយនឹងរដ្ឋាភិបាលកម្ពុជា ។ លោកសហព្រះរាជអាជ្ញារងបានសង្កត់ធ្ងន់ថា រហូតមកទល់ពេលនោះឯងទើបប្រទេសកម្ពុជាអាចធ្វើដំណើរឆ្ពោះទៅមុខជាមួយនឹងតុលាការកាត់ក្តីខ្មែរក្រហម ។

បន្ទាប់មកទៀត លោកសហព្រះរាជអាជ្ញារងបានគូសបញ្ជាក់ថាសកម្មភាពរបស់ជនជាប់ចោទក្រោយពីឆ្នាំ១៩៧៩ ជាក់ស្តែងគឺតួនាទីដឹកនាំរបស់ជនជាប់ចោទនៅក្នុងការធ្វើសង្គ្រាមប្រឆាំងនឹងរដ្ឋាភិបាលថ្មីរបស់កម្ពុជាគឺត្រូវបានទទួលខុសត្រូវមួយផ្នែកតូចដោយសារការកន្ទះខាតដំណើរការប្រព័ន្ធច្បាប់នៅក្នុងប្រទេសកម្ពុជារហូតមកដល់ទសវត្សរ៍៩០ ។ លោកបានអះអាងថា «ជនជាប់ចោទមិនអាចទទួលបានប្រយោជន៍ពីអំឡុងពេលនោះទេ ប្រសិនបើជនជាប់ចោទមានការទទួលខុសត្រូវដោយផ្នែកសម្រាប់ការអសមត្ថកិច្ចនៃដំណើរការប្រព័ន្ធច្បាប់ និងការអសមត្ថភាពក្នុងការនាំជនជាប់ចោទមកកាត់ទោសនោះ» ។

ចុងបញ្ចប់ លោកសហព្រះរាជអាជ្ញារងបានអះអាងថា សេចក្តីសម្រេចរបស់ក្រុមប្រឹក្សារដ្ឋធម្មនុញ្ញលើមាត្រា៣នៃច្បាប់បង្កើតសាលាក្តីខ្មែរក្រហមជាច្បាប់ធម្មនុញ្ញគឺជាសេចក្តីសម្រេចចុងក្រោយ ហើយគោរពតាមគោលការណ៍របស់សាលាក្តីខ្មែរក្រហម ។ លោកបានសន្និដ្ឋានបញ្ចប់ថា «ក្នុងនាមជាអ្នកអនុវត្តច្បាប់ យើងត្រូវតែគោរពតាមករណីយកិច្ចរបស់យើងក្នុងការអនុវត្តទៅតាមច្បាប់ដែលគាត់តែងឡើង ពីព្រោះវាគឺជា..... ហើយយើងត្រូវអនុវត្តច្បាប់នោះដោយពេញចិត្ត» ។

នៅចុងបញ្ចប់នៃការជជែកដេញដោលនេះ ចៅក្រមបានធ្វើការឈប់សម្រាកសម្រាប់ដំណើរការនីតិវិធីនាពេលព្រឹក ហើយបានបន្តាប់ជាលើកដំបូងនៅក្នុងសប្តាហ៍នេះដោយក្រើនរំឭកពីដំណោះស្រាយថ្មីរបស់តុលាការក្នុងការធ្វើឲ្យដំណើរការនីតិវិធីមានដំណើរការទៅមុខតាមពេលវេលាកំណត់ ។

លោកសហព្រះរាជអាជ្ញារងអន្តរជាតិ វីនស៊ីន ដឺ វ៉ាលដ៍ ឌីអ៊ីសម៉ែល បានបន្តលើកឡើងពីអំណះអំណាងផ្ទាល់មាត់របស់សហព្រះរាជអាជ្ញាបន្ទាប់ពីការឈប់សម្រាក ។ ដោយធ្វើការឆ្លើយតបនឹងការជជែកដេញដោលពីការគ្មានប្រតិសកម្មដែលលើកឡើងដោយមេធាវីការពារក្តី លោក ឌីអ៊ីសម៉ែល បានបញ្ជាក់ថា បទដ្ឋាននីតិវិធី និងបទដ្ឋានគោលការណ៍ច្បាប់មានលក្ខណៈខុសគ្នា ហេតុដូច្នេះការពន្រ្យាកអាជ្ញាយុកាលមិនមានប៉ះពាល់អ្វីដល់ស្ថានភាពរបស់ជនជាប់ចោទ ពីព្រោះទោះបីជាយ៉ាងណាក្តី ក៏ជនជាប់ចោទអាចនឹងត្រូវបានកាត់ទោសសម្រាប់ឧក្រិដ្ឋកម្មដូចគ្នានោះដដែល ។

ដោយបន្តការអះអាងរបស់ដៃគូសហព្រះរាជអាជ្ញារបស់ខ្លួនដែលថាអាជ្ញាយុកាលនៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ មិនបានអនុវត្តនៅចន្លោះឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩២នោះ លោក ឌីអ៊ីសម៉ែល បានអះអាងថាក្រមឆ្នាំ១៩៥៦ត្រូវបានទុកជាមោឃៈជាផ្លូវការ ហើយក៏ត្រូវបានពន្យារការទុកជាមោឃៈនេះនៅឆ្នាំ១៩៧៩ ដោយព្រះរាជក្រឹត្យនីតិបញ្ញត្តិដែលត្រូវបានគាត់តែងឡើងនៅខែមករា ឆ្នាំ១៩៧៩ ។ លោកបានគូសបញ្ជាក់ថា ព្រះរាជក្រឹត្យនីតិបញ្ញត្តិនេះដែលធ្វើការកាត់ទោសសម្រាប់បទល្មើសមួយចំនួននោះ ហើយដែលផ្តោតសំខាន់ទៅលើអំពើក្បត់ប្រឆាំងនឹងរដ្ឋាភិបាលមិនអាចត្រូវបានគាត់តែងឡើងស្របពេលជាមួយគ្នានោះទេ ហើយក៏មិនអាចជំនួសឲ្យគ្នាបានដែរ ។ រហូតមកដល់ឆ្នាំ១៩៩២ ទើបព្រះរាជក្រឹត្យនេះត្រូវបានជំនួសដោយច្បាប់ថ្មីដែលធ្វើឲ្យអាជ្ញាយុកាលនេះអាចត្រូវយកមកអនុវត្តបាន ។ ដូច្នេះ សហព្រះរាជអាជ្ញារងបានសន្និដ្ឋានបញ្ចប់ថា នៅពេលដែលច្បាប់បង្កើតសាលាក្តីខ្មែរក្រហមត្រូវបានអនុម័ត នោះអាជ្ញាយុកាលស្តីពីឧក្រិដ្ឋកម្មទាំងអស់នេះនៅតែដំណើរការ ហេតុដូច្នេះ អាជ្ញាយុកាលនេះអាចត្រូវបានពន្រ្យាកដោយសមស្របតាមផ្លូវច្បាប់ ។

បន្ទាប់មកទៀត លោក ឌីអ៊ីសម៉ែល បានប្រើប្រាស់ពេលវេលាដែលនៅសេសសល់របស់ខ្លួនធ្វើការសង្កត់ធ្ងន់លើអំណះអំណាងរបស់ដៃគូលោកដែលថា អាជ្ញាយុកាលមិនបានអនុវត្តនៅចំន្លោះឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩២ទេ ដោយសារតែកង្វះខាតដំណើរការប្រព័ន្ធច្បាប់ ស្ថានភាពក្រោមសង្រ្គាម និងកត្តាដែលថាជនជាប់ចោទបានចូលរួមនៅក្នុងការវាយប្រយុទ្ធប្រឆាំងនឹងរដ្ឋា-ភិបាល ។ នៅពេលដែលខ្មែរក្រហមត្រូវបានកម្ចាត់ចោល អាទិភាពចម្បងរបស់ប្រជាជនកម្ពុជាគឺជាការស្តាបនាសង្គមជាតិឡើងវិញ និងបញ្ចប់សង្រ្គាមជាជាងការបង្កើតតុលាការ និងនាំយកជនដៃដល់មករកយុត្តិធម៌ ។

លោក ឌីអ៊ីសម៉ែល បានសន្និដ្ឋានបញ្ចប់ដោយជំរុញឲ្យចៅក្រមទទួលស្គាល់ថា ការទទួលខុសត្រូវរបស់ជនជាប់ចោទសម្រាប់ការបំផ្លិចបំផ្លាញប្រព័ន្ធច្បាប់កម្ពុជានៅក្នុងរបបខ្មែរក្រហមចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ គឺជាការបំផ្លិចបំផ្លាញមួយដែលប៉ះពាល់ដល់ដំណើរការយុត្តិធម៌នៅក្នុងប្រទេសកម្ពុជាអស់រយៈកាលជាច្រើនឆ្នាំ ។ លោកបានអះអាងថា «ជនជាប់ចោទទាំងនេះបានរំខានដល់ដំណើរការយុត្តិធម៌ ដូច្នេះជនជាប់ចោទទាំងអស់នេះមិនគួរត្រូវបានទទួលផលប្រយោជន៍ជាពិសេសគឺផលប្រយោជន៍ពីនិទណ្ឌភាពពីបទឧក្រិដ្ឋកម្មជាតិនោះទេ» ។

**ការឆ្លើយតបរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីទៅកាន់ការបដិសេធបឋមរបស់ជនជាប់ចោទលើបញ្ហាអាជ្ញាយុកាលទាក់ទិននឹងបទល្មើសដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦**

បន្ទាប់មកទៀត មេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លើយ

តបនឹងអំណះអំណាងផ្ទាល់មាត់របស់មេធាវីការពារក្តីលើចំណុចថាតើការកាត់ទោសជនជាប់ចោទសម្រាប់ឧក្រិដ្ឋកម្មក្នុងស្រុកមិនត្រូវបានអនុញ្ញាតដោយអាជ្ញាយុកាលនៅក្នុងក្រមឆ្នាំ១៩៥៧ឬយ៉ាងណា ។ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីពីររូបបានពិភាក្សាពីបញ្ហានេះមុនពេលការឈប់សម្រាកអាហារថ្ងៃត្រង់ឈានមកដល់ ដោយធ្វើការលើកឡើងវិញសាជាថ្មីម្តងទៀតនូវសេចក្តីអំណះអំណាងដែលត្រូវបានលើកឡើងដោយសហព្រះរាជអាជ្ញា ។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមមួយបានរៀបរាប់ពីបរិបទរបស់ប្រទេសកម្ពុជាចាប់ពីឆ្នាំ១៩៧៩ដល់ទសវត្សរ៍៩០ ដោយអះអាងថា ស្ថានភាពបែបនោះបានតម្រូវឲ្យមានការប្រកាសអាជ្ញាយុកាលនៅក្នុងអំឡុងពេលនោះ ។

យ៉ាងណាមិញ ក្រោយពេលដែលមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ចប់ការលើកឡើងពីអំណះអំណាងរបស់ខ្លួនដែលនិយាយពីថិរវេលាតាមប្រវត្តិកាលនៃសង្គ្រាមស៊ីវិលមក លោក ខាណាវ៉ាស សហមេធាវីការពារក្តីរបស់ អៀង សារី បានបន្ទាក់ការលើកឡើងរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីដោយធ្វើការក្រើនរំឭកដល់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាក់ទិននឹងការផ្តល់អង្គហេតុគាំទ្រដ៏សមរម្យសម្រាប់អង្គសវនាការបឋមដូចដែលបានលើកឡើងម្តងហើយកាលពីព្រឹកថ្ងៃអង្គារនោះ ។ លោក ខាណាវ៉ាស បាននិយាយថា មេធាវីដើមបណ្តឹងរដ្ឋប្បវេណីទំនងជានាំមកនូវសក្ខីកម្មដែលស្តីពីបទពិសោធន៍បុគ្គលនិងស្ថានភាពជាក់ស្តែងនៅក្នុងប្រទេសកម្ពុជាក្រោយពីឆ្នាំ១៩៧៩ ដែលនេះមិនមែនជាអំណះអំណាងតាមផ្លូវច្បាប់នោះទេ ប៉ុន្តែផ្ទុយទៅវិញទាំងអស់នេះគឺជាភស្តុតាងដែលគួរតែរក្សាទុកសម្រាប់ដំណើរអង្គជំនុំជម្រះក្តីល្អជាង ។ លោកមេធាវីបានស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់ភាគីទាំងអស់រួមទាំងមេធាវីការពារក្តីផងឲ្យមានការប្រុងប្រយ័ត្នចំពោះសេចក្តីអំណះអំណាងរបស់ខ្លួនទាក់ទងនឹងសំណួរផ្នែកច្បាប់ស្តីពីបញ្ហានេះ ។

ដោយមិនអើពើនឹងការជំទាស់របស់លោក ខាណាវ៉ាស អង្គជំនុំជម្រះសាលាដំបូងមិនធ្វើការឆ្លើយតបនឹងសំណូមពររបស់លោក ខាណាវ៉ាស ទេ ហើយក៏មិនទទួលស្គាល់ការបន្ទាក់រំខាននេះឡើយ ។ ផ្ទុយទៅវិញ លោកប្រធានចៅក្រម និល ណុន បានបន្តដំណើរការនីតិវិធីទៅមុខទៀតដោយកោះហៅសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបន្ទាប់បន្តលើកឡើងអំណះអំណាងរបស់ខ្លួន ។ ខុសពីចៅក្រម សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរបានសម្រេចធ្វើការឆ្លើយតបនឹងការបដិសេធរបស់មេធាវីការពារក្តីដោយនិយាយថាការជជែកដេញដោលពីបញ្ហានេះមិនអាចដំណើរការទៅមុខបានទេ ប្រសិនបើគ្មានសេចក្តីយោងពីព្រឹត្តិការណ៍ទាំងអស់នេះនោះ ពីព្រោះថាព្រឹត្តិការណ៍ទាំងអស់នេះមានជាប់ពាក់ព័ន្ធផ្ទាល់នឹងបញ្ហាផ្លូវច្បាប់ ។ ក្រោយពីការគូសបញ្ជាក់ពីអំណះអំណាងរបស់សហព្រះរាជអាជ្ញាមក មេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់ព័ត៌មានសំខាន់ស្តីពីស្ថានភាពនៅក្នុងប្រទេសកម្ពុជានៅក្នុងអំឡុងពេល និងក្រោយរបបខ្មែរក្រហម ។ ប៉ុន្តែ លោកមេធាវីបានធ្វើការលើកឡើងខុសប្លែកពីអំណះអំណាងមុនៗត្រង់ថា ការពង្រីកអាជ្ញាយុកាលគឺធ្វើឡើងក្នុងគោលបំណងនាំយកមេដឹកនាំជាន់ខ្ពស់នៃរបបខ្មែរក្រហមមកប្រឈមមុខនឹងយុត្តិធម៌ និងដើម្បី «ធានាឲ្យបាននូវសិទ្ធិទទួលបានយុត្តិធម៌ និងការពិត» ដល់ជនរងគ្រោះ ។ ភាពចាំបាច់ក្នុងការកសាងជីវិតរបស់ជនរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេក្រោយពីការដួលរលំទៅនៃរបបខ្មែរក្រហម និងក្នុងអំឡុងសង្គ្រាមស៊ីវិលបានឆក់យកឱកាសទទួលបាននូវសំណងសម្រាប់ជនរងគ្រោះនៅចន្លោះឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩២ ។ លោកបានសន្និដ្ឋានបញ្ចប់ដោយអះអាងថា ដើម្បីការពារសិទ្ធិរបស់ភាគីពាក់ព័ន្ធទាំងអស់ ការពង្រីកអាជ្ញាយុកាលត្រូវតែអនុញ្ញាតឲ្យធ្វើឡើង ។

ក្រោយពីការបញ្ចប់ទៅនៃសេចក្តីអះអាងទាំងអស់នេះ ចៅក្រមបានផ្អាកដំណើរការនីតិវិធីសម្រាប់ការសម្រាកអាហារថ្ងៃត្រង់ ។

ក្រោយពីការឈប់សម្រាកអាហារថ្ងៃត្រង់មក លោកប្រធានចៅក្រម និល ណុន បានបង្គាប់ភាគីទាំងអស់ទាក់ទងនឹងការប្រើប្រាស់ពេលវេលានៅក្នុងចំណោមមេធាវីទាំងអស់ដែលឡើងធ្វើសេចក្តីអះអាងក្នុងក្រុមតែមួយ ដោយឆ្លុះបញ្ចាំងឲ្យឃើញពីការធុញទ្រាន់នូវការលើកឡើងតែអំណះអំណាងដដែលៗនៅក្នុងអំឡុងដំណើរការនីតិវិធីកាលពីពេលព្រឹកមិញនេះ ។ លោកប្រធានបានថ្លែងថា «ដោយសារតែមានមេធាវីជាច្រើនឡើងធ្វើសេចក្តី

*អំណះអំណាង នោះមេធាវីនីមួយៗត្រូវតែចៀសវាងការនិយាយជាន់គ្នាទៅវិញទៅមក ហើយមិនត្រូវជាន់គ្នានឹងការដាក់សេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់ខ្លួនឡើយ» ។ លោកប្រធានក៏បានថ្លែងថា ចៅក្រមសូមណែនាំឲ្យភាគីនីមួយៗមានតំណាងមេធាវីមិនលើសពីពីរនាក់ឡើងមានមតិចំពោះបញ្ហានីមួយៗ ហើយសូមឲ្យមេធាវីទាំងពីររូបនោះប្រើប្រាស់ពេលវេលាឲ្យបានត្រឹមត្រូវ ។ ជាថ្មីម្ដងទៀត លោកចៅក្រម ហ្សង់ម៉ាក ឡាវើញ បានបន្តដំណើរការនីតិវិធីដោយរំឭកនូវអ្វីដែលលោក ប្រធាន និល ណុន ទើបតែនិយាយដោយថ្លែងថា «យើងត្រូវតែធានាថាយើងធ្វើការដោយមានប្រសិទ្ធភាព» ។*

*សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីពីរចុងក្រោយបានបញ្ចប់ការឆ្លើយតបរបស់ខ្លួនស្ដីពីបញ្ហាអាជ្ញាយុកាល ដោយមិនបានយកចិត្តទុកដាក់នឹងការក្រើនរំឭករបស់ចៅក្រមពីមុននេះទេ ហើយបែរជាសង្កត់ធ្ងន់ចំណុចដដែលៗចំពោះអ្វីដែលបានលើកឡើងរួចម្ដងហើយ ។ សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីឈានមុខគឺលោក ពេជ អង្គ បានសន្និដ្ឋានបញ្ចប់លើសេចក្ដីអះអាងរបស់ភាគីដើមបណ្ដឹងរដ្ឋប្បវេណីស្របពេលដែលចរន្តអគ្គិសនីនៅក្នុងសាលសាធារណៈសម្រាប់អ្នកតាមដានបានដាច់ ។ ដូច្នេះ លោកក៏ស្នើសុំឲ្យចៅក្រមបញ្ឈប់ដំណើរការអង្គសវនាការរហូតដល់ពេលចរន្តអគ្គិសនីភ្ជាប់មកវិញនៅប៉ុន្មាននាទីក្រោយមក ។*

***មេធាវីការពារក្ដីជនជាប់ចោទឆ្លើយតបនឹងសហព្រះរាជអាជ្ញា និងមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី***

*ខណៈពេលដែលសន្តិសុខបានដើរត្រួតពិនិត្យមើលអ្នកចូលរួមដែលបានដេកលក់នៅពេលដែលដាច់ចរន្តអគ្គិសនី លោក ម៉ៃឃើល ខាណាវ៉ាស បានចាប់ផ្ដើមធ្វើការឆ្លើយតបទៅនឹងសហព្រះរាជអាជ្ញា និងមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ។ ក្រោយពីធ្វើការកត់សម្គាល់នូវការលើកឡើងអំណះអំណាងជាន់គ្នាដដែលៗរបស់ក្រុមមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីមក លោក ខាណាវ៉ាស បានឆ្លើយតបទៅវិញទាក់ទិននឹង «បញ្ហាជាប់គាំង» ដែលបានលើកឡើង ។ ដោយធ្វើការឆ្លើយតបជាពិសេសទៅកាន់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី លោកបានបកស្រាយថា មេធាវីការពារក្ដីជនជាប់ចោទបានយល់ស្របថា សាលាក្ដីខ្មែរក្រហមគឺជាតុលាការពិសេសមួយដែលបង្កើតឡើងដោយច្បាប់ពិសេសដូចគ្នា ហេតុដូច្នេះ តុលាការនេះចាំបាច់ត្រូវតែមានសមភាព និងផ្ដល់ការការពារស្មើគ្នាតាមផ្លូវច្បាប់ជូនដល់ភាគីទាំងអស់ ។ ប៉ុន្តែ លោកបាននិយាយថា មេធាវីការពារក្ដីជនជាប់ចោទសុំមិនយល់ស្របត្រង់ថា ជនរងគ្រោះនិងដើមបណ្ដឹងរដ្ឋប្បវេណីគឺជាភាគីដែលទទួលបានផលប្រយោជន៍រហូត ពីព្រោះប្រសិនបើច្បាប់ធ្វើការប្រឆាំងនឹងការទាមទាររបស់អ្នកទាំងអស់នេះ នោះក៏គ្មានសំណងថ្លៃខូចខាតសម្រាប់អ្នកទាំងអស់នេះដែរ ។ លោកបានអះអាងថា «ការក្លាយជាជនរងគ្រោះគឺមិនមែនជាហេតុផលត្រឹមត្រូវមួយដែលត្រូវតែយកមកអនុវត្តតាមផ្លូវច្បាប់ មិនថាវាពិបាកប៉ុណ្ណានោះទេ» ។*

*ដោយកត់សម្គាល់ថាខ្លួនកំពុងតែនិយាយការពារជនជាប់ចោទជ្រុល លោក ខាណាវ៉ាស បានងាកមកបកស្រាយថា «មេធាវីការពារក្ដីជនជាប់ចោទគ្រាន់តែបំពេញកិច្ចការរបស់ខ្លួនដើម្បីកំណត់សណ្ឋាននៃច្បាប់មុននឹងបន្តកិច្ចការទៅមុខទៀត» តែប៉ុណ្ណោះ ហើយនេះគឺជាហេតុផលមួយដែលក្រុមមេធាវីការពារក្ដីរបស់លោកបានដាក់ការបដិសេធបឋម «មួយចំនួនដែលមិនដែលមានពីមុនមក» នៅក្នុងអង្គសវនាការនេះ ។ លោកក៏បានបន្ត ដោយនិយាយទៀតថា ក្រុមមេធាវីការពារក្ដីរបស់លោកមិនមែនព្យាយាមបដិសេធមិនទទួលស្គាល់សិទ្ធិរបស់ភាគីណាមួយឡើយ ។*

*ងាកមកពិភាក្សាការជជែកដេញដោលពីគោលការណ៍ច្បាប់ លោក ខាណាវ៉ាស បានលើកឡើងពីសេចក្ដីអះអាងជាច្រើនដែលលើកឡើងដោយសហព្រះរាជអាជ្ញា និងមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីទាក់ទិននឹងស្ថានភាពដែលភាគីទាំងពីរបានអះអាងថាបានឆ្លុះបញ្ចាំងឲ្យឃើញពីកង្វះខាតដំណើរការប្រព័ន្ធតុលាការមួយនៅចន្លោះឆ្នាំ១៩៧៩ដល់ឆ្នាំ១៩៩២ ។ លោកបានជំទាស់ថា សេចក្ដីអះអាងជាច្រើនទាំងនោះមានលក្ខណៈដូចជាការធ្វើសក្ខីកម្ម ។ លោកបានចាត់ទុកថាសេចក្ដីអះអាងដែលសហព្រះរាជអាជ្ញាណែនាំឲ្យចៅក្រមធ្វើសេចក្ដីសម្រេចចិត្តដោយផ្អែកលើបទពិសោធន៍ផ្ទាល់ខ្លួនជាជាងផ្អែកតាមភស្តុតាងដែលមាននៅក្នុងកំណត់ត្រានោះថាមានលក្ខណៈមិនត្រឹមត្រូវ ហើយអាចបង្កជាហានិភ័យបាន ។ លោកបានបន្តទៀតថា ការណែនាំដូច្នេះអាច*

ធ្វើឲ្យចៅក្រមក្លាយជាសាក្សីទៅវិញទេ ។

បន្ទាប់មកទៀត លោក ខាណាវ៉ាស បានពិភាក្សាពីបញ្ហាប្រតិបត្តិដោយសមភាពក្រោមផ្លូវច្បាប់ ដោយធ្វើការសង្កត់ធ្ងន់លើគោលជំហររបស់មេធាវីការពារក្តីជនជាប់ចោទដែលថាមាត្រា៣ថ្មីរំលោភលើសិទ្ធិទទួលការប្រតិបត្តិដោយសមភាពនេះ ។ លោកបាននិយាយថា វាមិនសមទេដែលថាក្រុមប្រឹក្សារដ្ឋធម្មនុញ្ញកម្ពុជាពិចារណាលើសិទ្ធិទទួលបានការប្រតិបត្តិដោយសមភាពនៅពេលដែលក្រុមប្រឹក្សាបានចេញសេចក្តីសម្រេចថាមាត្រា៣ជាមាត្រារដ្ឋធម្មនុញ្ញនោះ ។ លោកបានជំរុញឲ្យចៅក្រមធ្វើការកែតម្រូវកំហុសឆ្គងនេះដោយធ្វើការពិចារណាលើការប្រតិបត្តិដោយសមភាព នៅពេលដែលចៅក្រមចេញសេចក្តីសម្រេចលើការបដិសេធបឋមនេះ ។

លោក ខាណាវ៉ាស បានសន្និដ្ឋានបញ្ចប់ការឆ្លើយតបរបស់លោកដោយសង្កត់ធ្ងន់ម្តងទៀតនូវហេតុផលទាំងឡាយក្នុងការធ្វើសេចក្តីបដិសេធបឋមនេះដែលដាក់ដោយក្រុមមេធាវីការពារក្តីរបស់ អៀង សារី ។ លោកបានថ្លែងថា «គោលបំណងនៃការដាក់ការបដិសេធបឋមនេះគឺដើម្បីធានាឲ្យបានថា ភាគីទាំងអស់យល់ពីសណ្ឋាននៃច្បាប់មុននឹងបន្តកិច្ចការរបស់ខ្លួនទៅមុខទៀត» ។ លោកបាននិយាយបន្ថែមទៀតថា ដោយសារបញ្ហាជាច្រើនទាំងអស់នេះជាបញ្ហាដំបូងដែលមានឡើងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង នោះច្បាប់ស្តីពីបញ្ហាទាំងអស់នេះចាំបាច់ត្រូវតែកំណត់ឲ្យបានច្បាស់លាស់ ។ ប៉ុន្តែ លោកបានធានាថា «យើងមិនព្យាយាមរំលោភលើឆន្ទានុសិទ្ធិ» ដែលចៅក្រមបានប្រគល់មកឲ្យយើងឡើយ ។

បន្ទាប់មកទៀត លោក ផាត់ ពៅស៊ាង សហមេធាវីការពារក្តីរបស់ អៀង ធីរិទ្ធ បានស្នើសុំចៅក្រមឡើងធ្វើការឆ្លើយតបនឹងសេចក្តីអះអាងផ្ទាល់មាត់របស់សហព្រះរាជអាជ្ញា និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីដោយផ្តល់ជាអំណះអំណាងជាក់លាក់របស់ក្រុមមេធាវីការពារក្តីស្តីពីការបដិសេធបឋមដែលត្រូវបានរៀបចំឡើងដោយក្រុមមេធាវីការពារក្តីរបស់ អៀង សារី ។ ប្រហែលជាដោយសារតែមិនបានត្រៀមខ្លួនចូលរួមនៅក្នុងការជជែកដេញដោលដោយផ្ទាល់នៅក្នុងថ្ងៃនេះ ការឆ្លើយតបរបស់លោក ផាត់ ពៅស៊ាង មានលក្ខណៈមិនច្បាស់ ហើយមិនតាមលំដាប់លំដោយដូចក្រុមមេធាវីការពារក្តីរបស់ អៀង សារី ទេ ។ លោកបានលើកឡើងពីចំណុចជាច្រើនដែលលោក ខាណាវ៉ាស បានលើកឡើងម្តងហើយ ។ ក្រោយពីការលើកឡើងនូវអំណះអំណាងដដែលៗដូចកាលពីដំណើរការនីតិវិធីនៅថ្ងៃច័ន្ទមក លោកបានងាកមកឆ្លើយតបនឹងការអះអាងដែលថាគ្មានដំណើរប្រព័ន្ធតុលាការនៅចន្លោះឆ្នាំ១៩៧៩ដល់ឆ្នាំ១៩៩២ ដោយនិយាយថានៅក្នុងអំឡុងពេលនោះ បុគ្គលគ្រប់រូបត្រូវបានកាត់ទោស ហើយមនុស្សជាច្រើនត្រូវបានកាត់ទោសឲ្យស្លាប់ ។ លោកបាននិយាយថា «យើងមិនអាចនិយាយថា តុលាការនោះជាតុលាការដែលប្រកបដោយយុត្តិធម៌នោះទេ» ប៉ុន្តែ យ៉ាងហោចណាស់ តុលាការនោះបានធ្វើការកាត់ទោស និងដាក់ទោសជនជាប់ចោទដែរ ។ នេះគឺជាគុណសម្បត្តិដ៏សមរម្យសម្រាប់តុលាការមួយក្នុងការដើរតួរជាប្រព័ន្ធតុលាការនោះ ។

ក្រោយបញ្ចប់សេចក្តីសន្និដ្ឋានពីការធ្វើអំណះអំណាងរបស់លោក ផាត់ ពៅស៊ាង ចៅក្រមបានសម្រាករយៈពេលម្ភៃនាទីដើម្បីជួសជុលប្រព័ន្ធអ៊ីនធឺណេតដែលត្រូវបានផ្តាច់ដោយសារដាច់ចរន្តអគ្គិសនី ។

## ការត្រៀមសម្រាប់អង្គសវនាការថ្ងៃព្រហស្បតិ៍

ក្រោយពីការឈប់សម្រាក លោកប្រធានចៅក្រម និល ណុន បានណែនាំភាគីទាំងអស់ពីប្រធានបទដែលចៅក្រមនឹងយកមកពិភាក្សាសម្រាប់អង្គសវនាការថ្ងៃព្រហស្បតិ៍ដែលស្តីពីបញ្ជីឈ្មោះសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ។ ភាគីទាំងអស់ត្រូវបានរំពឹងឲ្យដាក់កំណត់លើការបញ្ចេញមតិយោបល់របស់ខ្លួនទាក់ទិននឹងបុគ្គលដែលមានរាយនាមនៅក្នុងបញ្ជី ហើយត្រូវចាំទុកថាបញ្ជីឈ្មោះនេះគឺមានជាប់ពាក់ព័ន្ធនឹងផ្នែកដំបូងគេនៃអង្គជំនុំជម្រះនេះតែប៉ុណ្ណោះ ។

ចុងបញ្ចប់ ចៅក្រមបានរំឭកដល់ភាគីទាំងអស់ថា គ្មានសាក្សីអ្នកជំនាញ ឬដើមបណ្តឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានស្នើសុំធ្វើជាភាគីចូលរួមនៅក្នុងអង្គសវនាការត្រូវបានបដិសេធមិនទទួលស្គាល់ដោយតុលាការឡើយ លុះត្រាតែមានសេចក្តីសម្រេចចុងក្រោយពីចៅក្រម ។

## ព័ត៌មានដំបូងស្តីពីខ្លឹមសារនៃសំណងសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី

ដើម្បីបញ្ចប់ដំណើរការនីតិវិធី និងដើរទៅតាមកាលវិភាគកំណត់ ចៅក្រមបានងាកមកពិភាក្សាពីព័ត៌មានដំបូងស្តីពីខ្លឹមសារនៃសំណងថ្លៃខូចខាតសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ។ លោកប្រធានចៅក្រមបានចាប់ផ្តើមការពិភាក្សានេះដោយថ្លែងពីច្បាប់របស់សាលាក្តីខ្មែរក្រហមទាក់ទងនឹងសំណង ។ ដូចដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង២៣(៣)ក និង ខ របស់សាលាក្តីខ្មែរក្រហម មានវិធីសាស្ត្រពីរយ៉ាងទាក់ទងនឹងសំណងសម្រាប់ជនរងគ្រោះ ។ ទីមួយ) ការអះអាងផ្ទាល់ប្រឆាំងនឹងជនជាប់ចោទដែលវិធីសាស្ត្រទីមួយនេះត្រូវបានប្រតិបត្តិដោយតុលាការកម្ពុជាមិនមែនសាលាក្តីខ្មែរក្រហមទេ ។ វិធីសាស្ត្រនេះគឺជាវិធីសាស្ត្រតែមួយគត់ដែលមានសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងអំឡុងអង្គជំនុំជម្រះសំណុំរឿង០០១របស់សាលាក្តីខ្មែរក្រហម ហើយវិធីសាស្ត្រនេះត្រូវបានរក្សាទុកដើម្បីយកមកអនុវត្តនៅក្នុងអង្គជំនុំជម្រះនេះដែរ ។

លោកប្រធានចៅក្រម បាននិយាយថា វិធីសាស្ត្រទីពីរដែលមានសម្រាប់សំណងគឺហៅថា «សំណងផ្តួចផ្តើម» ។ វិធីសាស្ត្រនេះមិនមែនកើតឡើងដោយសារការអះអាងប្រឆាំងនឹងជនជាប់ចោទនោះទេ ហើយវាចាំបាច់ត្រូវពឹងផ្អែកលើសមត្ថភាពរបស់ផ្នែកគាំពារជនរងគ្រោះក្នុងការធានាឲ្យបាននូវមូលនិធិឧបត្ថម្ភគ្រប់គ្រាន់ ។ លោកប្រធានបាននិយាយថា សំណងទាំងអស់នេះគឺជាសំណងរួម និងជាសំណងផ្នែកសីលធម៌ ហើយមាន «លក្ខណៈជានិមិត្តរូប» ។ បន្ទាប់មកទៀត លោកប្រធានចៅក្រមបានផ្ទេរភារកិច្ចទៅឲ្យភាគីមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីផ្តល់ជាព័ត៌មានដំបូងស្តីពីខ្លឹមសារនៃសំណងសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ។

មេធាវីដើមបណ្តឹងរដ្ឋប្បវេណីឈានមុខបានឡើងមានមតិជួសមុខឲ្យភាគីដើមបណ្តឹងរដ្ឋប្បវេណីទាំងស្រុង ដើម្បីចូលរួមនៅក្នុងផ្នែកដំបូងនៃអង្គសវនាការបឋមដើម្បីបង្ហាញឲ្យចៅក្រម ភាគីផ្សេងៗ និងសាធារណជនទាំងអស់ដឹងពីសារសំខាន់នៃតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌនេះ និងក្នុងការកំណត់សិទ្ធិទទួលបានសំណងដែលស្ថិតនៅក្រោមច្បាប់ជាតិ និងអន្តរជាតិ ។

លោក ពេជ អង្គ បានចាប់ផ្តើមដោយរៀបរាប់ពីសិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបានសំណង ។ យោងតាមមាត្រា៣៩នៃរដ្ឋធម្មនុញ្ញកម្ពុជា ជនរងគ្រោះមានសិទ្ធិក្នុងការទាមទារសំណង ហើយសិទ្ធិនេះត្រូវបានផ្តល់ឲ្យជនរងគ្រោះដោយក្រមព្រហ្មទណ្ឌកម្ពុជា ។ លោកបានសង្កត់ធ្ងន់ពីចំណុចដែលលោកប្រធានចៅក្រមបានលើកឡើង ជាពិសេសត្រង់ចំណុចដែលថាវិធានផ្ទៃក្នុងរបស់សាលាក្តីខ្មែរក្រហមមានចែងនូវវិធីសាស្ត្រពីរខុសគ្នាសម្រាប់សំណងនៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌរបស់ខ្លួន ។

លោកស្រី អេលីហ្សាប៊ែត ស៊ីម៉ុននៀ ហ្វុត បានមានមតិបន្ថែមលើសេចក្តីអះអាងរបស់លោក ពេជ អង្គ ដោយរៀបរាប់បន្ថែមពីសិទ្ធិទទួលបានសំណងដែលមានចែងនៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ ។ ទាំងសេចក្តីប្រកាសទទួលស្គាល់ដោយពិភពលោកពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ បានផ្តល់សិទ្ធិឲ្យជនរងគ្រោះស្វែងរកសំណងសម្រាប់ការរំលោភមកលើសិទ្ធិរបស់ខ្លួន ។ លោកស្រីក៏បានលើកឡើងពីសេចក្តីសម្រេចពីររបស់មហាសន្និបាតនៃអង្គការសហប្រជាជាតិដែលមានចែងពីសិទ្ធិរបស់ជនរងគ្រោះនៃបទឧក្រិដ្ឋកម្មក្នុងការទាមទាររកសំណង ។ លោកស្រីបាននិយាយថា សេចក្តីសម្រេចទាំងនេះផ្ទុកនូវគោលការណ៍ដែលថា ប្រសិនបើជនរងគ្រោះមិនអាចទាមទារបាននូវសំណងដ៏ពេញលេញពីជនជាប់ចោទបាននោះ រដ្ឋាភិបាលត្រូវបានទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុជូនដល់ជនរងគ្រោះ ។ សេចក្តីសម្រេចនេះជំរុញឲ្យរដ្ឋាភិបាលបង្កើតនិងពង្រឹងមូលនិធិជាតិសម្រាប់ការផ្តល់ជាសំណងដល់ជនរងគ្រោះ ។

បន្ទាប់មកទៀត លោកស្រីបានសង្កត់ធ្ងន់ពីសារសំខាន់នៃតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងអង្គនីតិវិធីព្រហ្មទណ្ឌ ។ លោកស្រីបាននិយាយថា បើគ្មានដើមបណ្តឹងរដ្ឋប្បវេណីក៏គ្មានសំណងដែរ ។ លោកស្រីបានបកស្រាយបន្ថែមទៀតថា «ដើមបណ្តឹងរដ្ឋប្បវេណីមិនមែនជាភ្ញៀវដែលអញ្ជើញឲ្យចូលរួមនោះទេ ។ ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិ និងឋានៈស្មើគ្នានឹងភាគីផ្សេង

ទៀត» ហើយអាចដាក់សេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរស្នើសុំឯកសារ និងអាចធ្វើសេចក្ដីអះអាងផ្ទាល់មាត់ដូចភាគីផ្សេងៗទៀតដែរ ។ យ៉ាងណាមិញ ដើមបណ្ដឹងរដ្ឋប្បវេណីអាចទាមទារសំណងបានទៀតផង ។ ការបាត់ទុកសំណងឲ្យដាច់ដោយឡែកពីដំណើរនីតិវិធីព្រហ្មទណ្ឌអាចធ្វើឲ្យតុលាការបោះបង់ចោលផ្នែកមួយដ៏សំខាន់នៃដំណើរនីតិវិធីនេះ ពីព្រោះថា ប្រសិនបើគ្មានជនរងគ្រោះទេ នោះឧក្រិដ្ឋកម្មក៏មិនអាចកើតមានបានដែរ ។

បន្ទាប់មកទៀតលោក ពេជ អង្គ បានបន្តការពិភាក្សានេះដោយរៀបរាប់ពីតួនាទីរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទិននឹងបញ្ហាសំណង ។ លោកបាននិយាយថា វិធានផ្ទៃក្នុងរបស់សាលាក្ដីខ្មែរក្រហមតម្រូវឲ្យដើមបណ្ដឹងរដ្ឋប្បវេណីបង្ហាញថាខ្លួនបានរងគ្រោះដោយគ្រោះថ្នាក់មួយដែលបណ្ដាលមកពីឧក្រិដ្ឋកម្មផ្ទាល់ ដូច្នេះ ទើបសំណងនិងគ្រោះថ្នាក់ដែលដើមបណ្ដឹងរដ្ឋប្បវេណីបានទទួលរងមានភាពជាប់ពាក់ព័ន្ធគ្នា ។ ហើយនេះគឺជាការទទួលខុសត្រូវរបស់សហចៅក្រមស៊ើបអង្កេតក្នុងការសម្រេចថាដើមបណ្ដឹងរដ្ឋប្បវេណីមានផ្ទុកនូវសមាសធាតុដូចខាងលើនេះ ។ ដូច្នេះ លោកបានពន្យល់បកស្រាយថា អង្គជំនុំជម្រះសាលាដំបូងអាចនឹងសម្រេចជ្រើសយកសំណងដែលត្រឹមត្រូវតាមការគួរ ។

ដោយបន្តរៀបរាប់ពីព័ត៌មានដំបូងស្ដីពីខ្លឹមសារនៃសំណង លោក ពេជ អង្គ បានរំឭកចៅក្រមថាព័ត៌មានដែលមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីផ្ដល់ នៅក្នុងថ្ងៃនេះមិនមានផ្ទុកនូវសំណងដែលដើមបណ្ដឹងរដ្ឋប្បវេណីថ្មីទទួលស្គាល់ដោយអង្គបុរេជំនុំជម្រះនោះទាមទារទេ ។

១) បូជនីយដ្ឋាន និងការចងចាំ ៖

ក) ថ្ងៃនៃការចងចាំ ឬថ្ងៃឈប់សម្រាកជាផ្លូវការដើម្បីចងចាំអំពើប្រល័យពូជសាសន៍

ខ) ការតាំងបូជនីយដ្ឋានតាមទីតាំងសមរម្យ

គ) ការអភិរក្សវាលពិឃាត

២) នីតិសម្បទា ៖

ក) ការបង្កើតប្រព័ន្ធមួយដើម្បីផ្ដល់ការព្យាបាល និងសេវាកម្មប្រឹក្សាបញ្ហាសតិអារម្មណ៍ដល់ជនរងគ្រោះ

ខ) កម្មវិធីផ្ដល់ការប្រឹក្សាដល់ជនរងគ្រោះតាមទីកន្លែងដែលជនរងគ្រោះអាចទៅជួប និងទាក់ទងសម្រាប់ជំនួយ

៣) ការចងក្រងឯកសារ និងការអប់រំ ៖

ក) កម្មវិធីអប់រំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យដែលកម្មវិធីខ្លះត្រូវបានអនុវត្តរួចហើយ

ខ) ការបង្កើតជាបណ្ណសារ ឬបណ្ណាល័យ

គ) សារមន្ទីរស្ដីពីប្រវត្តិសាស្ត្រខ្មែរក្រហមមានទីតាំងនៅទីក្រុងភ្នំពេញ

ឃ) ការចងក្រងបញ្ជីឈ្មោះជនរងគ្រោះទាំងអស់

**៤) សំណងផ្សេងៗ ៖**

ក) គម្រោងស្ដីពីការបែងចែកសំណងដល់ជនរងគ្រោះជនជាតិវៀតណាម

ខ) គម្រោងអប់រំក្មេងជំនាន់ក្រោយពីការរៀបការដោយបង្ខំ

គ) មូលនិធិសម្រាប់សំណង

ឃ) ការផ្សព្វផ្សាយជាសាធារណៈនូវសាលក្រមរបស់រឿងក្ដី០០២

លោកស្រីបានសន្និដ្ឋានបញ្ចប់អង្គសវនាការស្ដីពីព័ត៌មានដំបូងនៃខ្លឹមសារសំណងដោយនិយាយថា សំណងខាងលើចាំបាច់ត្រូវកំណត់ឡើងវិញនាពេលអនាគត ហើយលោកស្រីបានក្រើនរំឭកដល់ចៅក្រម និងភាគីទាំងអស់ថា ក្រោយពេលដែលកិច្ចការរបស់សាលាក្ដីខ្មែរក្រហមបានបញ្ចប់ទៅ កេរដំណែលដែលនៅសល់គឺសច្ចាប័ន និងសំណង ។ ដោយសារតែសំណងជាសិទ្ធិដ៏ចម្បងដែលជនរងគ្រោះ និងដើមបណ្ដឹងរដ្ឋប្បវេណីមិនត្រូវបានដកហូតនោះ លោកស្រីបានជំរុញឲ្យតុលាការជួយធ្វើយ៉ាងណាឲ្យដើមបណ្ដឹងរដ្ឋប្បវេណីអាចអនុវត្តសិទ្ធិទទួលបានសំណងដើម្បីឲ្យសិទ្ធិនេះឋិតថេរគង់វង្ស ហើយដើម្បីកុំឲ្យសិទ្ធិនេះក្លាយជាកាតព្វកិច្ចឬបន្ទុកសម្រាប់ជនរងគ្រោះ ។

ដោយសារតែគ្មានភាគីណាមួយមានបំណងបញ្ចេញមតិបន្ថែមលើបញ្ហាសំណង ចៅក្រមបានផ្អាកដំណើរការនីតិវិធីថ្ងៃនេះដោយត្រៀមរបៀបវារៈសម្រាប់អង្គសវនាការបឋមគឺការជជែកដេញដោលផ្ទាល់មាត់ស្ដីពីបញ្ជីឈ្មោះសាក្សីដែលត្រូវបានស្នើសុំធ្វើជាសាក្សីសម្រាប់ដំណើរការនីតិវិធីថ្ងៃព្រហស្បតិ៍ទី៣០ ខែមិថុនា ។ **គ្រីស្ទីន អ៊ីវេន**




# "គួរតែស្តាប់សាក្សីរបស់ខ្ញុំ"

អង្គសវនាការបឋមក្នុងអង្គជំនុំជម្រះក្តីលើសំណុំរឿង ០០២ នៅសាលាក្តីខ្មែរក្រហមដែលលោក អេនឌ្រូ ខេលី បាន ចាត់ទុកថាជា «អង្គសវនាការនីតិវិធីដ៏ក្រឹត្យក្រម និងជោគជ័យបំផុតដែលលោកធ្លើបានសម្រេច» បានចូលទីបញ្ចប់ទៅដោយស្ថានភាពតានតឹង និងជជែកដេញដោលដូចគ្នានឹងថ្ងៃដែលអង្គសវនាការនេះចាប់ផ្តើមដែរ ។

ប្រធានបទសម្រាប់ការពិភាក្សាថ្ងៃនេះគឺទាក់ទងនឹងបញ្ជីរាយនាមសាក្សីបម្រុងរបស់អង្គជំនុំជម្រះសាលាដំបូងដែលក្នុងនោះរួមមានដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលនឹងត្រូវកោះហៅឲ្យធ្វើសក្ខីកម្មសម្រាប់អង្គជំនុំជម្រះរបស់មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម នួន ជា, អៀង សារី, អៀង ធីរិទ្ធ និង ខៀវ សំផន ដែលនឹងចាប់ផ្តើមដំណើរការនាពេលមុខឆាប់ៗនេះ ។ ជនជាប់ចោទទាំងបួនមានវត្តមាននៅក្នុងបន្ទប់សវនាការ ខណៈពេលដែលអង្គសវនាការចាប់ផ្តើម លើកលែងតែ អៀង សារី ដែលបានចាកចេញពីបន្ទប់មន្ទីរឃុំឃាំងវិញនៅចុងបញ្ចប់នៃអង្គសវនាការបឋមនេះ ។ នេះគឺជាលើកដំបូងនៅក្នុងអង្គសវនាការបឋមនេះហើយដែល នួន ជា មានវត្តមាននៅក្នុងបន្ទប់សវនាការក្នុងអំឡុងដំណើរការនីតិវិធីនៅថ្ងៃព្រហស្បតិ៍នេះ ដោយគោរពតាមពាក្យសន្យារបស់គាត់ដែលថា គាត់នឹងចូលរួមអង្គសវនាការនៅពេលដែលអង្គហេតុមានជាប់ពាក់ព័ន្ធនឹងរឿងក្តីរបស់គាត់ត្រូវបានយកមកពិភាក្សាចំពោះមុខចៅក្រម ។

សាធារណជនក៏បន្តចូលរួមតាមដានអង្គសវនាការរហូតដល់ទីបញ្ចប់ដូចគ្នាដែរ ។ បើទោះបីជាអង្គសវនាការបានចាប់ផ្តើមឡើងដោយនៅមានកៅអីទំនេរជាច្រើននៅក្នុងសាលសាធារណៈ

សម្រាប់អ្នកតាមដានដំណើរការសវនាការក៏ដោយ ។ មិនយូរប៉ុន្មាន សិស្សានុសិស្សជាច្រើននាក់បានមកចូលរួមតាមដានដំណើរការនីតិវិធីថ្ងៃនេះ ដោយចូលបំពេញកន្លែងដែលទំនេរទាំងអស់នោះ ។

## សេចក្តីបង្គាប់របស់ចៅក្រមស្តីពីការបដិសេធចំពោះបញ្ជីរាយនាមសាក្សីដែលត្រូវបានស្នើសុំ

លោកប្រធានចៅក្រម និល ណុន បានចាប់ផ្តើមដំណើរការអង្គសវនាការក្រោយម៉ោងប្រាំបួនបន្តិច ហើយបានសង្កត់ធ្ងន់លើសេចក្តីបង្គាប់របស់ចៅក្រមដែលបានលើកឡើងកាលពីថ្ងៃពុធទាក់ទងនឹងការពិភាក្សាពីបញ្ជីរាយនាមសាក្សី ។ ក្រោយពីលោកប្រធានបានបញ្ជាក់ថាបញ្ជីរាយនាមសាក្សីនេះគ្រាន់តែជាបញ្ជីបម្រុងតែប៉ុណ្ណោះ ហើយថាគ្មានសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញណាម្នាក់ត្រូវបានបដិសេធមិនទទួលស្គាល់ លោកប្រធានបានស្នើសុំឲ្យភាគីទាំងអស់ដាក់កម្រិតលើការបញ្ចេញមតិរបស់ខ្លួនចំពោះសាក្សីដែលមានចុះនៅក្នុងបញ្ជីតាមតែអាចធ្វើបាន ។ លោកប្រធានក៏បានរំឭកភាគីទាំងអស់ថា បញ្ជីនេះមានចុះឈ្មោះរបស់សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញសម្រាប់ដំណាក់កាលទីមួយនៃអង្គជំនុំជម្រះនេះ ដែលនេះក៏ជាប្រធានបទមួយដែលចៅក្រមបានលើកឡើងកាលពីថ្ងៃច័ន្ទរួចម្តងហើយ ។

បន្ទាប់មកទៀត លោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉្រាយត៍ បានផ្តល់សេចក្តីបង្គាប់បន្ថែមសម្រាប់ការពិភាក្សានៅក្នុងថ្ងៃនេះ ។ ដំបូង លោកស្រីចៅក្រមបានមានប្រសាសន៍ថា អង្គជំនុំជម្រះសាលាដំបូងមិនទាន់បានចេញសេចក្តីសម្រេចចុងក្រោយថាតើអ្នកជំនាញដែលមានចុះនៅក្នុងបញ្ជីគួរតែត្រូវចាត់ទុកជាសាក្សីឬយ៉ាងណានោះទេ ។ លោកស្រីចៅក្រមបានណែនាំភាគីទាំងអស់ថា ចៅក្រមបានដឹងយ៉ាងច្បាស់ពីអំណះអំណាងរបស់ភាគីនីមួយៗមកលើប្រធានបទនេះតាមរយៈការដាក់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់ភាគីទាំងអស់ដែលបានដាក់ជូនចៅក្រម ។ ដូច្នេះ ភាគីទាំងអស់មិនត្រូវលើកឡើងនូវអំណះអំណាងដដែលទាំងអស់នោះនៅក្នុងអង្គសវនាការថ្ងៃនេះទេ ។ ទីពីរ លោកស្រីចៅក្រមក៏បានរំឭកភាគីទាំងអស់ថា ភាគីនីមួយៗត្រូវតែហៅឈ្មោះសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលមាននៅក្នុងបញ្ជីតាមរបស្សនាមដែលតុលាការបានដាក់ឲ្យ ។

បន្ថែមលើនេះ លោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉្រាយត៍ បានពន្យល់បកស្រាយថា អង្គជំនុំជម្រះសាលាដំបូងអាចនឹងបន្តពិនិត្យមើលបញ្ជីសាក្សីដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញទាំងអស់សាឡើងវិញនៅក្នុងអំឡុងដំណើរការនីតិវិធី ហើយអាចនឹងបន្ថែមសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីទៀត ប្រសិនបើចៅក្រមសម្រេចធ្វើដូច្នេះ ។ ក្នុងគោលបំណងឲ្យអង្គជំនុំជម្រះក្តីដំណើរការលឿន លោកស្រីចៅក្រមបានគូសបញ្ជាក់ថា អង្គជំនុំជម្រះសាលាដំបូងនឹងកម្រិតចំនួនសាក្សីបន្ថែមដែលអាចនឹងត្រូវកោះហៅឲ្យចូលរួម ។ លោកស្រីបាននិយាយបន្តទៀតថា ប្រសិនបើភាគីណាមួយជឿជាក់ថាវាមានសារសំខាន់ក្នុងការបន្ថែមបុគ្គលណាមួយចូលទៅក្នុងបញ្ជីរាយនាមសាក្សីមុនពេលអង្គជំនុំជម្រះក្តីចាប់ផ្តើមនោះ សូមភាគីនោះមិនត្រូវប្រកាសសំណូមពររបស់ខ្លួននៅក្នុងអង្គសវនាការជាសាធារណៈទេ ។ ជាងនេះទៅទៀត ភាគីនីមួយៗគួរតែដាក់សេចក្តីស្នើសុំជាលាយលក្ខណ៍អក្សរជូនមកចៅក្រមនៅថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១១ ។ លោកស្រីបានបញ្ជាក់សេចក្តីបង្គាប់នេះសាជាថ្មីម្តងទៀតដល់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីថា ដោយសារតែការបន្ថែមចំនួនដើមបណ្តឹងរដ្ឋប្ប-វេណីដែលទើបតែអនុញ្ញាតដោយអង្គបុរេជំនុំជម្រះនោះ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នឹងទទួលបានឱកាសដាក់បញ្ចូលដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នេះចូលទៅក្នុងបញ្ជីរាយនាមសាក្សីនាពេលក្រោយ ហេតុដូច្នេះមេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់មិនចាំបាច់លើកឡើងពីបញ្ហានេះ ឬបន្ថែមឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីទាំងនោះសម្រាប់ការពិភាក្សានៅក្នុងថ្ងៃនេះទេ ។

លោកប្រធានចៅក្រម និល ណុន បានសន្និដ្ឋានបញ្ចប់នូវសេចក្តីថ្លែងការណ៍បឋមរបស់ចៅក្រមដោយណែនាំឲ្យភាគីទាំងអស់ថា ចៅក្រមនឹងមិនបន្តដំណើរការអង្គសវនាការបឋមនេះនៅថ្ងៃសុក្រទៀតទេ ពីព្រោះថាការសួរដេញដោលដោយផ្ទាល់មាត់ត្រូវបានបញ្ចប់ជាស្ថាពរនៅថ្ងៃពុធរួចហើយ ។

មុននឹងចាប់ផ្តើមការពិភាក្សាពីបញ្ជីរាយនាមសាក្សី សហមេធាវីការពារក្តី ខៀវ សំផន គឺលោក ស សូវ៉ាន បានស្នើសុំការ

អនុញ្ញាតឲ្យកូនក្ដីរបស់លោកមានមតិខ្លីមួយចំពោះមុខចៅក្រម ។ លោកប្រធានចៅក្រម និល ណុន បានស្នើឲ្យ ខៀវ សំផន ជម្រាបអង្គសវនាការពីប្រធានបទដែល ខៀវ សំផន នឹងលើកយកមកនិយាយ ។ ខៀវ សំផន បានឆ្លើយតបវិញថា គាត់សូមនិយាយពីបញ្ហាបញ្ជីរាយនាមសាក្សីដោយខ្លួនឯង ។ ភ្លាមៗនោះ ចៅក្រមបានបដិសេធច្រានចោលការស្នើសុំនេះ ។

ដោយទំនងជាមិនយល់នឹងការឆ្លើយតបភ្លាមៗរបស់ចៅក្រម ខៀវ សំផន នៅឈរស្ងៀមអស់មួយភ្លែតរហូតដល់លោក ស សូវ៉ាន បានណែនាំឲ្យ ខៀវ សំផន អង្គុយចុះ ។ បន្ទាប់មកទៀត លោក ស សូវ៉ាន មានបំណងបកស្រាយបញ្ជាក់ពីគោលបំណងរបស់កូនក្ដីខ្លួន ។ លោកបាននិយាយថា ខៀវ សំផន មានបំណងនិយាយតែពីបញ្ជីរាយនាមសាក្សីតែប៉ុណ្ណោះ ដោយមិនលើកឡើងពីប្រធានបទអ្វីផ្សេងនោះទេ ។

លោកប្រធានចៅក្រម និល ណុន បានឆ្លើយតបថា ចៅក្រមបានសម្រេចមិនអនុញ្ញាតឲ្យជនជាប់ចោទ ខៀវ សំផន និយាយនៅពេលនេះទេ ប៉ុន្តែ ខៀវ សំផន អាចមានមតិបាននៅពេលដែលដំណាក់កាលនៃអង្គសវនាការកំណត់ឲ្យជនជាប់ចោទមានមតិបានមកដល់ ។ លោកប្រធានបាននិយាយថា «នេះគឺជាសិទ្ធិរបស់អ្នក និងកូនក្ដីរបស់អ្នក» ។ ក្រោយពីបានរំឮកដល់ភាគីទាំងអស់ឲ្យប្រើប្រាស់រហស្សនាមជនរងគ្រោះនៅក្នុងអំឡុងពេលផ្ដល់អំណះអំណាងមក លោកប្រធានចៅក្រមបានស្នើសុំឲ្យសហព្រះរាជអាជ្ញាចាប់ផ្ដើមការពិភាក្សាលើបញ្ជីរាយនាមសាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកជំនាញ បម្រុងនេះតែម្ដង ។

## ការអង្កេតរបស់សហព្រះរាជអាជ្ញាលើបញ្ជីរាយនាមសាក្សីដែលត្រូវបានស្នើសុំ

លោកស្រីសហព្រះរាជអាជ្ញាជាតិ ជា លាង បាននិយាយថា ក្រោយពីបានពិនិត្យមើលបញ្ជីរាយនាមសាក្សីបម្រុងនេះមក ការិយាល័យសហព្រះរាជអាជ្ញាសូមបដិសេធមិនទទួលយកសាក្សីតែមួយគត់គឺ សាក្សី TCW៤៨២ ហើយស្នើសុំឲ្យលុបចោលសមាសភាពសាក្សីរូបនេះចោល ។ បន្ទាប់មកទៀត លោកស្រីសហព្រះរាជអាជ្ញាសូមបញ្ចប់ការអង្កេតរបស់ភាគីសហព្រះរាជអាជ្ញាដើម្បីអនុញ្ញាតឲ្យមានការជជែកដេញដោលបន្តទៀតលើការ





ខៀវ សំផន នៅក្នុងបន្ទប់សវនាការ ឆ្នាំ២០១១

បដិសេធច្រានចោលសាក្សីរូបនេះ ។

ក្រោយពីបានពិភាក្សាជាមួយនឹងចៅក្រមផ្សេងៗទៀត លោកប្រធានចៅក្រម និល ណុន បានឆ្លើយតបថា ចៅក្រមបានកត់សម្គាល់ការស្នើសុំនេះ ហើយនិងបញ្ជាក់ពីសេចក្ដីសម្រេចរបស់ចៅក្រមជូនដល់សហព្រះរាជអាជ្ញានាពេលខាងមុខ ពីព្រោះថាភាគីដទៃទៀតមានបំណងចង់បន្តដំណើរការនីតិវិធីនេះដោយលើកឡើងពីអំណះអំណាងរបស់ខ្លួននៅក្នុងកិច្ចដំណើរការនីតិវិធីជាសម្ងាត់វិញ ។

លោក វីលៀម ស្មីត សហព្រះរាជអាជ្ញាអន្តរជាតិបានបន្តការអង្កេតរបស់ការិយាល័យសហព្រះរាជអាជ្ញាដោយរំឮកដល់



ខៀវ សំផន ជាមួយថ្នាក់ដឹកនាំឡាវ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

ចៅក្រមថា ព្រះរាជអាជ្ញាមានកាតព្វកិច្ចដាក់បន្ទុកនៅក្នុងអង្គជំនុំជម្រះក្តីព្រហ្មទណ្ឌ ។ អាស្រ័យហេតុនេះ លោកសហព្រះរាជអាជ្ញាសូមជម្រាបដល់ចៅក្រមថា សហព្រះរាជអាជ្ញាគ្រោងនឹងដាក់ការស្នើសុំជាលាយលក្ខណ៍អក្សរដើម្បីបន្ថែមជនរងគ្រោះចំនួនដប់ប្រាំនាក់ទៀតតាមកាលបរិច្ឆេទកំណត់នៅថ្ងៃទី៩ ខែកក្កដា ។ លោកសហព្រះរាជអាជ្ញាក៏បាននិយាយថាសហព្រះរាជអាជ្ញាបានធ្វើការកត់ចំណាំសេចក្តីប្រកាសរបស់ចៅក្រម ខណៈពេលដែលអង្គជំនុំជម្រះក្តីដំណើរការទៅមុខសម្រាប់ឲ្យភាគីនីមួយៗបន្ថែមចំនួនសាក្សីនៅក្នុងរឿងក្តីនេះ ។ លោកបានបន្តទៀតថា ការដែលភាគីព្រះរាជអាជ្ញាលើកឡើងពីសេចក្តីប្រកាសនេះពីព្រោះថាវាកើតមានជាញឹកញាប់នៅក្នុងអង្គជំនុំជម្រះក្តីមុនៗ និងអង្គសវនាការផ្សេងៗទៀតដែលថាសាក្សីមួយចំនួនមិនអាចមកចូលរួមនៅក្នុងអង្គសវនាការបានស្របពេលដែលសាក្សីមួយចំនួនផ្សេងទៀតមានភាពស្ទាក់ស្ទើរក្នុងការនិយាយ ឬមានភាពភ្លេចភ្លាំង ដែលកត្តាទាំងអស់នេះជំរុញឲ្យមានការទាញយកសាក្សីផ្សេងទៀតមកជំនួសសាក្សីទាំងអស់នេះ ។

## ក្រុមមេធាវីការពារក្តីរបស់ នួន ជា រៀបរាប់ពីភាពចម្រូងចម្រាសនៅក្នុងដំណើរការស៊ើបអង្កេត

ក្រោយពីការបញ្ចប់ការបញ្ចេញមតិយោបល់របស់សហព្រះរាជអាជ្ញា ចៅក្រមបានផ្ទេរវេទិកាទៅឲ្យមេធាវីការពារក្តី ។

ដោយសារការបដិសេធជាបន្តបន្ទាប់ពីសំណាក់មេធាវីការពារក្តី ជាពិសេសក្រុមមេធាវីការពារក្តីរបស់ នួន ជា ទាក់ទិននឹងប្រធានបទនេះតាំងពីដើមសប្តាហ៍មក ការពិភាក្សាពីបញ្ជីរាយនាមសាក្សីនេះបានឈានទៅរកការជជែកដេញដោលនិងភាពមិនចុះសម្រុងគ្នារវាងភាគីសហព្រះរាជអាជ្ញា មេធាវីការពារក្តីដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីការពារក្តីជនជាប់ចោទ និងរវាងភាគីទាំងអស់នេះជាមួយនឹងចៅក្រម ។

លោក វីកទ័រ គូប៉េ សហមេធាវីការពារក្តីអន្តរជាតិរបស់ នួន ជា បានចាប់ផ្តើមពិភាក្សាពីការអង្កេតរបស់ខ្លួនលើបញ្ជីរាយនាមសាក្សីសម្រាប់កូនក្តី នួន ជា ដោយធ្វើការរិះគន់លើដំណើរការស៊ើបអង្កេតតាមផ្លូវច្បាប់របស់តុលាការខ្មែរក្រហមក្នុងគោលបំណងបញ្ចប់ការអះអាងដែលដៃគូសហមេធាវីរបស់គាត់បានលើកឡើងនៅក្នុងអំឡុងអង្គសវនាការកាលពីថ្ងៃច័ន្ទកន្លងទៅនេះ ។ លោក វីកទ័រ គូប៉េ បាន ជម្រាបចៅក្រមថា ភ្លាមៗបន្ទាប់ពីត្រូវបានតែងតាំងជាមេធាវីការពារក្តីឲ្យ នួន ជា ក្រុមមេធាវីការពារក្តីរបស់លោកបានដាក់ការស្នើសុំមួយជូនដល់ចៅក្រមស៊ើបអង្កេតដើម្បីឲ្យភាគីមេធាវីការពារក្តីមានវត្តមាននៅក្នុងការជួបសម្ភាសន៍ជាមួយនឹងសាក្សី ។ បើទោះបីជាវិធានផ្ទៃក្នុងរបស់តុលាការខ្មែរក្រហមមិនតម្រូវឲ្យមេធាវីការពារក្តីមានវត្តមាននៅក្នុងការជួបសម្ភាសន៍សាក្សីក៏ដោយ ក៏លោក វីកទ័រ គូប៉េ និងដៃគូសហមេធាវីរបស់លោកបានធ្វើការស្នើសុំនេះឡើងអាស្រ័យលើមូលហេតុពីរគឺ ៖ ១) ដើម្បីអនុវត្តសិទ្ធិរបស់មេធាវីការពារក្តីក្នុងការពិនិត្យពិច័យសមាសភាពរបស់សាក្សីទាំងអស់ដោយយោងតាមច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ និង ២) ដើម្បីចៀសវាងការសម្ភាសន៍ឬពិនិត្យមើលសមាសភាពរបស់សាក្សីម្តងទៀតក្នុងគោលបំណងធានាឲ្យបាននូវអង្គជំនុំជម្រះក្តីមួយដែលមានល្បឿនទៅមុខនិងប្រកបដោយប្រសិទ្ធភាព និងសម្រេចលទ្ធផលបានល្អ ។ បន្ថែមពីលើនេះ លោកវីកទ័រ គូប៉េ បានរៀបរាប់ថា ចៅក្រមស៊ើបអង្កេតបានបដិសេធច្រានចោលសំណើនេះដោយអះអាងថាការជួបគ្នារវាងមេធាវីការពារក្តីជាមួយនឹងសាក្សីបានផ្តល់ជាលទ្ធផលគ្រប់គ្រាន់ហើយសម្រាប់ការស្នើសុំនេះ ។ លោក វីកទ័រ គូប៉េ បានបន្តទៀតថា ចៅក្រមស៊ើបអង្កេតបានឆ្លើយតបបន្ថែមទៀតថា ការរារាំងមិនឲ្យមេធាវីការពារក្តីជួបនិយាយជាមួយនឹងសាក្សីបានក្រើនរំឭកដល់ក្រុមមេធាវីការពារក្តីថាវាគឺជាសកម្មភាពខុសច្បាប់ក្នុងការដាក់សម្ពាធមកលើសាក្សី ។

ក្រោយពីបានពិភាក្សាជាមួយ នួន ជា លោក វីកទ័រ គូប៉េ បាននិយាយថា សហមេធាវីការពារក្តីបានធ្វើការស្នើសុំឲ្យធ្វើការស៊ើបអង្កេតមួយចំនួន ។ លោកបាននិយាយថា «ប្រសិនបើមិនអនុញ្ញាតឲ្យធ្វើការស៊ើបអង្កេតដោយផ្ទាល់ នោះយើងសូមស្នើសុំឲ្យចៅក្រមស៊ើបអង្កេតធ្វើការស៊ើបអង្កេតជំនួសយើង» វិញ ។ លោក វីកទ័រ គូប៉េ បានរៀបរាប់ថា ការស្នើសុំឲ្យមានការស៊ើបអង្កេតទាំងអស់នេះមានជាប់ពាក់ព័ន្ធនឹងទិដ្ឋភាពជាក់លាក់បួនដែលមេធាវីការពារក្តីរបស់ក្រុមលោកបានជឿថាចៅក្រមស៊ើបអង្កេតមិនបានធ្វើការអង្កេតឲ្យបានពេញលេញ និងគ្រប់ជ្រុងជ្រោយ ។ ទិដ្ឋភាពទាំងបួននោះគឺ ៖

១) តួនាទីប្រទេសវៀតណាមនៅក្នុងអំឡុងឆ្នាំ១៩៧៣ ដល់ឆ្នាំ១៩៧៩ មុន និងក្រោយរបបកម្ពុជាប្រជាធិបតេយ្យ និងផលប៉ះពាល់នៃតួនាទីនេះដែលមានមកលើសេចក្តីសម្រេចរបស់មេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

២) ផលវិបាកនៃការបំផ្លិចបំផ្លាញដោយការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក ថាតើការទម្លាក់គ្រាប់បែកនេះបានបង្កឲ្យមានកង្វះចំណីអាហារមានផលប៉ះពាល់អ្វីខ្លះដែលមានមកលើប្រជាជនកម្ពុជា និងថាតើរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យអាចនឹងធ្វើអ្វីបានខ្លះដើម្បីដោះស្រាយផលប៉ះពាល់ទាំងអស់នេះ ។

៣) មេបញ្ជាការខ្មែរក្រហមដែលពោរពេញដោយល្បិចកល ជាពិសេសនៅភូមិភាគបូព៌ាដែលមេដឹកនាំនៅទីក្រុងភ្នំពេញមិនមានអំណាចមជ្ឈការ ។

៤) សច្ចភាពនៃសក្ខីកម្មរបស់ជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅ ឌុច នៅក្នុងសំណុំរឿង០០១ទាក់ទិននឹងតួនាទីរបស់ នួន ជា នៅមន្ទីរសន្តិសុខស-២១របស់ខ្មែរក្រហម ។

លោក វីកទ័រ គូប៉េ បានអះអាងថា នួន ជា និងក្រុមមេធាវីការពារក្តីបានធ្វើការស្នើសុំឲ្យមានការស៊ើបអង្កេតទាំងអស់នេះឡើងដោយសង្ឃឹមថា បញ្ហាទាំងអស់នេះនឹងមិនចាំបាច់លើកមកពិភាក្សានៅក្នុងអំឡុងអង្គជំនុំជម្រះក្តីនោះទេ ។ លោកបាននិយាយ

ថា កូនក្តីរបស់លោកមានវ័យកាន់តែចាស់ជរា ហើយក៏គ្មានបំណងអូសបន្លាយអង្គជំនុំជម្រះក្តីនេះដែរ ។ បន្ថែមលើនេះ លោក វីកទ័រ គូប៉េ បានបញ្ជាក់ថា នួន ជា ចង់ឲ្យតុលាការលាតត្រដាងពីការពិត «ការពិតជាប្រវត្តិសាស្ត្រ» ដែលមិនត្រឹមតែអាចអានបាននៅក្នុងសៀវភៅនៅតាមបណ្តាប្រទេសសហរដ្ឋអាមេរិក ឬវៀតណាមតែប៉ុណ្ណោះទេ តែការពិតដែលមនុស្សគ្រប់ៗគ្នាអាចដឹងពុបាន ។ ម្យ៉ាងវិញទៀត លោកបានអះអាងថា នួន ជា ចង់បាន «អង្គជំនុំជម្រះក្តីមួយដែលត្រឹមត្រូវ និងយុត្តិធម៌ដែលមិនមែនជាអង្គជំនុំជម្រះក្តីក្លែងក្លាយ» ដូចដែលកើតមានកាលពីឆ្នាំ ១៩៧៩ នោះទេ ។

យ៉ាងណាមិញ លោក វីកទ័រ គូប៉េ បានអះអាងថា ការឆ្លើយតបរបស់សហចៅក្រមស៊ើបអង្កេតចំពោះសំណើទាំងអស់នេះមិនអាចទទួលយកបានទាល់តែសោះ ។ ដូចដែលបានដឹង សក្ខីកម្មរបស់ ឌុច មិនត្រូវបានយកមកពិចារណា មេដឹកនាំនៅភូមិភាគបូព៌ាមិនត្រូវបានសម្ភាសន៍ ហើយបញ្ហារបស់ប្រទេសវៀតណាមក៏មិនត្រូវបានដោះស្រាយ ។ បន្ទាប់មកទៀត លោកក៏បានបន្ត «ពន្យល់បកស្រាយទៅកាន់សាធារណជន» ពីមូលហេតុដែលលោកបានលើកឡើងពីបញ្ហាស៊ើបអង្កេតនៅខណៈពេលនេះ ដោយផ្តល់ជាឧទាហរណ៍ពីសាក្សីដោះបន្ទុកម្នាក់របស់ក្រុមមេធាវីការពារក្តីដែលមិនត្រូវបានបញ្ចូលនៅក្នុងបញ្ជី រាយនាមសាក្សីបម្រុងនេះ ។ មុននឹងពន្យល់បកស្រាយពីសារៈសំខាន់នៃសាក្សីរូបនេះ លោក វីកទ័រ គូប៉េ បានរិះគន់លក្ខខ័ណ្ឌ... 

ភ្លាមៗនោះ លោកសហព្រះរាជអាជ្ញារង វីលៀម ស្មីត បានក្រោមឈរធ្វើការបដិសេធ ។ លោកបាននិយាយថា ស្របពេលដែលលោកដឹងថាលោក វីកទ័រ គូប៉េ មានបំណងធ្វើឲ្យអង្គសវនាការនេះមានលក្ខណៈជាសាធារណៈដោយសារតែការព្រួយបារម្ភពីសុវត្ថិភាពរបស់សាក្សី ចៅក្រមបានបង្គាប់ឲ្យភាគីទាំងអស់ប្រើប្រាស់តែរហស្សនាមសម្រាប់អង្គសវនាការនាថ្ងៃនេះ ។ លោក វីលៀម ស្មីត បានជំទាស់ថានេះគឺជាទង្វើមិនសមរម្យទេដែលមេធាវីការពារក្តីបានហៅសាក្សីថា «លោក» ហើយបែរជាផ្តល់ព័ត៌មានលម្អិតពីសមាសភាពរបស់សាក្សីនោះដែលអាចធ្វើឲ្យសាធារណជនកត់សម្គាល់ពីអត្តសញ្ញាណរបស់សាក្សីនោះបានយ៉ាងងាយទៅវិញ ។ លោកសូមស្នើសុំឲ្យចៅក្រមរំឭកមេធាវីទាំងអស់មិនត្រូវគូសសម្គាល់ពីអត្តសញ្ញាណរបស់សាក្សីដាច់ខាតនៅក្នុងថ្ងៃនេះ ។

លោកប្រធានចៅក្រម និល ណុន បានឆ្លើយតបដោយរំឭកដល់លោក វីកទ័រ គូប៉េ ថាបញ្ជីរាយនាមសាក្សីនេះគឺគ្រាន់តែជាបញ្ជីបណ្តោះអាសន្នតែប៉ុណ្ណោះ ហេតុដូច្នេះប្រសិនបើលោក វីកទ័រ គូប៉េ ត្រូវការសាក្សីផ្សេងទៀតជាចាំបាច់នោះ សូមលោកដាក់ការស្នើសុំនេះជាលាយលក្ខណ៍អក្សរ ។ លោកប្រធានចៅក្រមបានយល់ស្របតាមការអង្កេតរបស់លោក វីលៀម ស្មីត ដោយនិយាយថាការធ្វើការអង្កេតដែលឈានទៅដល់ការកត់សម្គាល់សមាសភាពរបស់សាក្សីបានរំលោភបំពានវិធានការការពារសាក្សីដែលកំណត់ដោយចៅក្រមដែលមានចែងនៅក្រោមបទដ្ឋានច្បាប់អន្តរជាតិ ។ លោកប្រធានចៅក្រមបានបង្គាប់ឲ្យលោក វីកទ័រ គូប៉េ ឈប់ផ្តល់ព័ត៌មានលម្អិតរបស់សាក្សី «ឃ» ហើយបន្តការមានមតិរបស់លោកទៅលើបញ្ជីរាយនាមសាក្សីទៀត ។

លោក វីកទ័រ គូប៉េ បានចាប់ផ្តើមបញ្ចេញមតិរបស់លោកសាជាថ្មីម្តងទៀតដោយនិយាយថាលោកនឹងមិននិយាយអ្វីទាំងអស់ទាក់ទិននឹងសាក្សី «ឃ» ទៀតឡើយ ។ ជាការឆ្លើយតបនឹងការស្នើសុំរបស់ នួន ជា លោកបានរៀបរាប់ថា ចៅក្រមស៊ើបអង្កេតបានបដិសេធមិនសម្ភាសន៍សមាសភាពសាក្សីដែលលោកបានប្រគល់ជូនចៅក្រមស៊ើបអង្កេតនោះទេ ហើយបែរជានិយាយថាការសម្ភាសន៍សាក្សីទាំងអស់នោះមិនមានសារសំខាន់អ្វីទេ ។

លោកបានបន្តនិយាយថា នួន ជា ភ្ញាក់ផ្អើលយ៉ាងខ្លាំងចំពោះការឆ្លើយតបរបស់សហចៅក្រមស៊ើបអង្កេត ហើយជឿថាសហចៅក្រមស៊ើបអង្កេតយកចិត្តទុកដាក់តែលើភ័ស្តុតាងដាក់បន្ទុក ជាងភ័ស្តុតាងដោះបន្ទុករបស់ភាគីមេធាវីការពារក្តី ។

បន្ទាប់មកទៀត លោក វីកទ័រ គូប៉េ បានចាប់ផ្តើមរៀបរាប់ពីព័ត៌មានទាក់ទងនឹងមន្ត្រីប៉ូលិសជនជាតិអូស្ត្រាលីម្នាក់ដែលនេះគឺជារហស្សនាមដែលលោក វីកទ័រ គូប៉េ បានដាក់ឲ្យសាក្សីរូបនោះដែលជាជនមានជាប់ពាក់ព័ន្ធនៅក្នុងដំណើរការស៊ើបអង្កេត ។ ជាថ្មីម្តងទៀត លោកសហព្រះរាជអាជ្ញារងបានបន្ទាក់លោកមេធាវីការពារក្តីដោយជំទាស់ថា បញ្ហាសមភាពនៃដំណើរការស៊ើបអង្កេតមិនមែនជាបញ្ហាដែលត្រូវលើកឡើងមកពិភាក្សាសម្រាប់ដំណើរការអង្គសវនាការថ្ងៃនេះទេ ។ ក្រោយពីបានអះអាងចំពោះមុខមេធាវីការពារក្តីថាភាគីព្រះរាជអាជ្ញាក៏មានបំណងចង់ឲ្យបញ្ហាទាំងអស់នេះត្រូវបានពិភាក្សាជាសាធារណៈមក លោកបាននិយាយបន្តទៀតថា ក្នុងសមាសភាពជាអ្នកគ្រប់គ្រងសំណុំរឿង អង្គជំនុំជម្រះសាលាដំបូងមានសិទ្ធិក្នុងការកំណត់កាលបរិច្ឆេទសម្រាប់ប្រធានបទដែលត្រូវលើកមកពិភាក្សា ។ លោក វីលៀម ស្មីត បានងាកមករកចៅក្រមដោយនិយាយថា «អ្នកនឹងបាត់បង់នូវអំណាចគ្រប់គ្រងអង្គជំនុំជម្រះក្តីនេះ ប្រសិនបើភាគីទាំងអស់ត្រូវបានអនុញ្ញាតឲ្យមានមតិដែលមិនគោរពទៅតាមគោលការណ៍នៃរបៀបវារៈដែលចៅក្រមបានកំណត់ឲ្យនោះ» ។

ក្រោយពីបានពិភាក្សាជាមួយនឹងចៅក្រមផ្សេងៗទៀត លោកប្រធានចៅក្រម និល ណុន បានប្រកាសសេចក្តីសម្រេចរបស់ចៅក្រមដោយបញ្ឈប់ការបញ្ចេញមតិរបស់លោក វីកទ័រ គូប៉េ ដោយសារការមិនគោរពតាមសេចក្តីបង្គាប់របស់ចៅក្រមក្នុងការដាក់កម្រិតលើការបញ្ចេញមតិរបស់ខ្លួនដែលមានទៅលើបញ្ហាបញ្ជីរាយនាមសាក្សីនិងក្នុងការមិនកត់សម្គាល់អត្តសញ្ញាណរបស់សាក្សីបានបង្អាក់រំខានដល់ដំណើរការនីតិវិធីរបស់តុលាការ ។ លោក វីកទ័រ គូប៉េ បានសួរថាតើសេចក្តីសម្រេចរបស់ចៅក្រមនេះមានន័យថាក្រុមមេធាវីការពារក្តីរបស់ នួន ជា មិនត្រូវអនុញ្ញាតឲ្យមានមតិលើបញ្ជីរាយនាមសាក្សីនេះបន្តទៀតឬយ៉ាងណា ហើយលោកបានបញ្ជាក់ទៀតថាកូនក្តីរបស់លោកបានរង់ចាំអស់រយៈពេលបួនថៃហើយដើម្បីធ្វើបទបង្ហាញលើបញ្ហានេះ ។

ទំនងជាមានអារម្មណ៍ថារំខាន លោកប្រធាន និល ណុន បានបង្អាក់លោក វីកទ័រ គូប៉េ ហើយបានជម្រាបលោក វីកទ័រ គូប៉េ ថាលោកប្រធានបានបង្គាប់ឲ្យ នួន ជា ដាក់ការស្នើសុំបញ្ចូលសាក្សីថ្មីទាំងនោះជាលាយលក្ខណ៍អក្សរជូនមកចៅក្រម ។ បន្ទាប់មកទៀត លោកប្រធានចៅក្រមបាននិយាយថា ប្រសិនបើលោក វីកទ័រ គូប៉េ មិនធ្វើការអង្កេតអ្វីតទៅទៀត នោះចៅក្រមនឹងផ្ទេរវេទិកានេះទៅឲ្យភាគីផ្សេងទៀត ។ លោក វីកទ័រ គូប៉េ បានអង្គុយចុះដោយគ្មានធ្វើការឆ្លើយតបអ្វីទាំងអស់ ។ ឃើញដូច្នេះ លោកប្រធានចៅក្រមបានកោះហៅក្រុមមេធាវីការពារក្តីរបស់ អៀង សារី ឲ្យឡើងធ្វើបទបង្ហាញរបស់ខ្លួន ។

## ការអង្កេតរបស់ក្រុមមេធាវីការពារក្តី អៀង សារី លើបញ្ជីរាយនាមសាក្សីដែលត្រូវបានស្នើសុំ

លោក ម៉ៃឃើល ខារណាវ៉ាស សហមេធាវីការពារក្តីអន្តរជាតិរបស់ អៀង សារី បានលើកឡើងការជំទាស់មិនទទួលស្គាល់សាក្សី TCE៤៤ ដោយនិយាយថា មូលហេតុសម្រាប់ការបដិសេធនេះត្រូវបានប្រគល់ជូនចៅក្រមជាលាយលក្ខណ៍អក្សររួចរាល់ហើយ ។ លោកក៏បានស្នើសុំឲ្យចៅក្រមផ្តល់ប្រធានបទបន្ថែមទៀតសម្រាប់អង្គជំនុំជម្រះក្តីឆាប់ៗតាមតែអាចធ្វើបាន ដើម្បីជួយដល់ភាគីទាំងអស់អាចពិនិត្យមើលបញ្ជីរាយនាមសាក្សីនេះឲ្យកាន់តែល្អិតល្អន់ជាងនេះ ។ លោក ម៉ៃឃើល ខារណាវ៉ាស ក៏បានសំណូមពរឲ្យសហព្រះរាជអាជ្ញាយ៉ាងហោចណាស់ផ្តល់នូវ «បញ្ជីស្តីពីអត្តចរិតត្រឹមត្រូវ» របស់សាក្សីចំនួនដប់ប្រាំនាក់ដែលសហព្រះរាជអាជ្ញាបានគ្រោងដាក់បន្ថែមនោះ ។

បន្ទាប់មកទៀត លោក ម៉ៃឃើល ខារណាវ៉ាស បានបញ្ចេញមតិទាក់ទងនឹងសេចក្តីអះអាងរបស់លោក វីលៀម ស្មីត និងលោក វីកទ័រ គូប៉េ ស្តីពីដំណើរការអង្គសវនាការសម្រាប់សាក្សីជាសាធារណៈ ដោយសង្កត់ធ្ងន់ថាវាអាចក្លាយជា «កំហុសឆ្គងមួយដ៏ធ្ងន់ធ្ងរ ប្រសិនបើបញ្ជីរាយនាមសាក្សីត្រូវបានលាតត្រដាងមុនពេលដែលសាក្សីអាចមានវត្តមាននៅក្នុងអង្គសវនាការ» ។ លោកបានជំរុញឲ្យភាគីទាំងពីរមានការប្រុងប្រយ័ត្ន ដោយអះអាង

ថាសាធារណជនអាចនឹងមិនទទួលបានប្រយោជន៍អ្វីទាំងអស់ពីការដឹងពីសមាសភាពសាក្សីទុកជាមុនបែបនេះ ហើយការដឹងពីសមាសភាពសាក្សីនេះទៀតអាចនឹងបង្កជាគ្រោះថ្នាក់ដល់សាក្សី និងបង្កជាបញ្ហាសម្រាប់តុលាការទាំងមូលទៀតផង ។

ទាក់ទិននឹងការបដិសេធរបស់ចៅក្រមក្នុងការមិនអនុញ្ញាតឲ្យ ខៀវ សំផន និយាយ លោក ម៉ៃឃើល ខាណាវ៉ាស បានជំរុញចៅក្រមធ្វើការពិចារណាលើសេចក្តីសម្រេចរបស់ខ្លួនម្តងទៀត ។ លោកបានលើកឡើងពីខ្លឹមសារនៃមាត្រា១៤(ក) របស់កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលស្តីពីសិទ្ធិរបស់ជនជាប់ចោទក្នុងការការពារខ្លួនឯង និងភាគីដទៃ ។

ភ្លាមៗលោកប្រធានចៅក្រម និល ណុន បានពន្យល់បកស្រាយថា អង្គជំនុំជម្រះសាលាដំបូងមិនបាននិយាយថាជនជាប់ចោទ ខៀវ សំផន មិនត្រូវបានអនុញ្ញាតឲ្យនិយាយឡើយ ប៉ុន្តែដោយគោរពទៅតាមគោលការណ៍លំដាប់លំដោយនៃដំណើរការនីតិវិធី ខៀវ សំផន ត្រូវរង់ចាំដល់វេនដែលជនជាប់អាចត្រូវអនុញ្ញាតឲ្យនិយាយតែប៉ុណ្ណោះ ។

### ក្រុមមេធាវីការពារក្តីរបស់ អៀង ធីរិទ្ធ មិនមានមតិយោបល់លើបញ្ជីរាយនាមសាក្សីដែលត្រូវបានស្នើសុំ

ដោយសារតែលោកស្រី ដាយអាណា អេលីស សហមេធាវីការពារក្តីអន្តរជាតិរបស់ អៀង ធីរិទ្ធ ធ្លាប់បានស្នើសុំឲ្យចៅក្រមរៀបចំកាលបរិច្ឆេទនៃអង្គសវនាការសាជាថ្មីម្តងទៀត ដើម្បីធានាថាលោកស្រីអាចមានវត្តមានចូលរួមនៅក្នុងដំណើរការពិភាក្សាពីបញ្ជីរាយនាមសាក្សីនោះ វាដូចជាគួរឲ្យភ្ញាក់ផ្អើលដែលថាដៃគូសហមេធាវីរបស់លោកស្រី គឺលោក ផាត់ ពៅស៊ាង បាននិយាយថា ក្រុមមេធាវីរបស់លោកមិនមានមតិយោបល់អ្វីលើបញ្ជីរាយនាមសាក្សីបម្រុងនេះទេ ដោយលោកបានអង្គុយចុះភ្លាមក្រោយពេលនិយាយចប់ ។ យ៉ាងណាមិញ ចៅក្រមបានបន្តដំណើរការនីតិវិធីភ្លាមៗដោយកោះហៅក្រុមមេធាវីការពារក្តីរបស់ ខៀវ សំផន ដោយអនុញ្ញាតឲ្យជនជាប់ចោទ ខៀវ សំផន ឡើងមានមតិយោបល់លើបញ្ជីរាយនាមសាក្សីនេះដោយខ្លួនឯង ។

### ខៀវ សំផន និយាយ

ខៀវ សំផន បានចាប់ផ្តើមបញ្ចេញមតិដោយធ្វើការគោរពដល់ចៅក្រម មេធាវីទាំងអស់ និងសាធារណជន និងសូម «គោរពថ្វាយបង្គំ» ព្រះសង្ឃដែលគង់នៅក្នុងសាលសាធារណៈ ដែលគាត់បានងាកមើលជាញឹកញាប់ខណៈពេលដែល ខៀវ សំផន កំពុងនិយាយ ។ ក្រោយពីបានអះអាងថា អង្គសវនាការនេះមានសារសំខាន់បំផុតសម្រាប់ខ្លួនឯង និងប្រជាជនខ្មែរទាំងអស់ ខៀវ សំផន បាននិយាយថា គាត់បានរង់ចាំឱកាសនេះជាយូរណាស់មកហើយ ។ ខៀវ សំផន បានបន្តដោយនិយាយថា «ខ្ញុំពិតជាមានសំណាងណាស់ដែលមានសុខភាពល្អនៅខណៈពេលនេះ ។ ឲ្យតែខ្ញុំមានសុខភាពល្អដូចថ្ងៃនេះរហូតទៅ ខ្ញុំនឹងសហការឲ្យអស់ពីសមត្ថភាព និងអស់ពីចិត្តពីថ្លើមដើម្បីជួយសម្រួលដល់កិច្ចការរបស់តុលាការ.... និងព្យាយាមបញ្ជាក់ពីការពិតឲ្យបានច្រើនតាមតែអាចធ្វើបាន» ។

ងាកមកនិយាយពីបញ្ជីរាយនាមសាក្សីវិញ ខៀវ សំផន បាននិយាយថាគាត់ចង់ឲ្យសាធារណជនដឹងថាសាក្សីមួយភាគធំដែលមាននៅក្នុងបញ្ជីរាយនាមសាក្សីបម្រុងនេះគឺជាសាក្សីរបស់ព្រះរាជអាជ្ញា ។ គាត់បានអះអាងថា សូម្បីតែសាក្សីខ្លះដែលដើមឡើយត្រូវបានស្នើសុំដោយក្រុមមេធាវីការពារក្តីរបស់លោកក៏ត្រូវបានក្លាយជាសាក្សីដាក់បន្ទុករបស់ព្រះរាជអាជ្ញាជាជាងសាក្សីដោះបន្ទុកដែរ ។ ក្រោយពីបាននិយាយថា សាក្សីសំខាន់របស់គាត់អាចជួយឲ្យ «ភាពស្អាតស្អំរបស់គាត់ត្រូវបានលាតត្រដាង» មក ខៀវ សំផន បានស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការពិចារណាសាក្សីរបស់គាត់ម្តងទៀត ។ ខៀវ សំផន បានប្រកាសថា «ចៅក្រមត្រូវតែស្តាប់សាក្សីរបស់ខ្ញុំ ហើយខ្ញុំមិនមែនប្រើពាក្យថា "គួរ" ទេ តែខ្ញុំបានប្រើពាក្យថា "ត្រូវតែ" ។ ខៀវ សំផន បាននិយាយថាគាត់សូមធ្វើការស្នើសុំដាក់សាក្សីបន្ថែមជាលាយលក្ខណ៍អក្សរនាពេលខាងមុខនេះ ។ យើងសង្កេតឃើញថាមិនមានប្រតិកម្មប្រឆាំងអ្វីកើតមានឡើងចំពោះការបញ្ចេញមតិរបស់ ខៀវ សំផន ឡើយ ។

### ការអង្កេតរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីទៅលើបញ្ជីរាយនាមសាក្សីដែលត្រូវបានស្នើសុំ

បន្ទាប់មកទៀត ចៅក្រមបានផ្ទេរវេទិកាទៅឲ្យមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ។ លោក ពេជ អង្គ ប្រធានសហមេធាវី

ដើមបណ្តឹងរដ្ឋប្បវេណីបានចាប់ផ្តើមបញ្ចេញមតិយោបល់ដោយគោរពដល់ព្រះសង្ឃនៅសាលសាធារណៈដែលមេធាវីដើមបណ្តឹងរដ្ឋប្បវេណីទើបតែសម្គាល់ឃើញជាលើកដំបូង បើទោះបីជាព្រះសង្ឃដែលឋិតនៅក្នុងស្បង់ជីពរពណ៌ទឹកក្រូចមានវត្តមាននៅជួរខាងមុខនៅក្នុងសាលសាធារណៈជិតមួយសប្តាហ៍ក៏ដោយ ។ លោកប្រធានមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក៏បានផ្ទេរភារកិច្ចទៅឲ្យដៃគូសហមេធាវីរបស់លោកគឺលោកស្រី អេលីហ្សាប៉ែត ស៊ីម៉ូណូហ្វូត ។ លោកស្រីបានមានមតិលើសាក្សីម្នាក់គឺសាក្សី TCW ៦០៨ ដោយនិយាយថា ឋានៈរបស់សាក្សីរូបនេះត្រូវតែផ្លាស់មកជាដើមបណ្តឹងរដ្ឋប្បវេណីដើម្បីគោរពទៅតាមសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ។

បន្ទាប់មកទៀត លោកស្រីមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ម៉ាទីន ហ្សាកាំង បានផ្តើការអង្កេតលើសាក្សីពីររូបគឺសាក្សី TC៣៨៨ ដែលឋានៈរបស់សាក្សីនេះគួរតែក្លាយជាដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី TC៥៣១ ដែលឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីរបស់សាក្សីរូបនេះមិនទាន់ត្រូវបានសម្រេចនៅឡើយទេ ។ លោកស្រីបានជម្រាបចៅក្រមថាសាក្សី TC៥៣១ អាចចូលរួមនៅក្នុងអង្គសវនាការនេះបានលុះត្រាតែសាក្សីរូបនេះត្រូវបានចាត់ទុកជាដើមបណ្តឹងរដ្ឋប្បវេណី ។ លោកស្រី ម៉ាទីន ហ្សាកាំង បានសន្និដ្ឋានបញ្ចប់មតិយោបល់របស់លោកស្រីដោយជំរុញឲ្យចៅក្រមធ្វើយ៉ាងណាទប់ស្កាត់កុំឲ្យអត្តសញ្ញាណរបស់សាក្សីត្រូវបានដឹងឮជាសាធារណៈមុននឹងអង្គជំនុំជម្រះក្តីពិតប្រាកដចាប់ផ្តើម ដើម្បីការពារសិទ្ធិជាបុគ្គល និងសុវត្ថិភាពរបស់សាក្សីផ្ទាល់ ។

ជាចុងក្រោយ លោកស្រីមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ស៊ីលកេ ស្ទួដហ្សិនស្គី បានបញ្ចប់ការបញ្ចេញមតិរបស់ភាគីមេធាវីដើមបណ្តឹងរដ្ឋប្បវេណីដោយនិយាយថា លោកស្រីមានបំណងលើកឡើងពីគោលនយោបាយជាក់លាក់ពីរនៃរបបកម្ពុជាប្រជាធិបតេយ្យដែលជាប់ពាក់ព័ន្ធនឹងបញ្ជីរាយនាមសាក្សីនេះដែលនឹងត្រូវយកមកពិភាក្សានៅក្នុងអង្គជំនុំជម្រះ ។ គោលនយោបាយទាំងពីរនោះគឺគោលនយោបាយស្តីពីបទបញ្ញារៀបអាពាហ៍ពិពាហ៍ និង «គោលនយោបាយខ្មាំង» ។ លោកស្រីបានចាប់ផ្តើមពន្យល់បកស្រាយថាគោលនយោបាយបទបញ្ញារៀបអាពាហ៍ពិពាហ៍គឺខុសគ្នាពីគោលនយោបាយផ្សេងទៀតនៅក្នុងអំឡុងរបបខ្មែរក្រហម ។ ភ្លាមៗនោះ លោក ម៉ៃឃើល ខាណាវ៉ាស មេធាវីការពារក្តីជនជាប់ចោទបានបង្អាក់ការបញ្ចេញមតិរបស់លោកស្រីមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ។ ក្រោយពីក្រោកឈរអស់មួយសន្ទុះដោយមិនត្រូវបានកត់សម្គាល់ពីសំណាក់ចៅក្រម លោក ម៉ៃឃើល ខាណាវ៉ាស បាននិយាយថា «ខ្ញុំសូមមានមតិយោបល់» ។

ចៅក្រមបានកត់សម្គាល់គោលបំណងរបស់លោក ម៉ៃឃើល ខាណាវ៉ាស ហើយបានបង្គាប់ឲ្យលោកស្រី ស៊ីលកេ ស្ទួដហ្សិនស្គី អង្គុយចុះ ។ លោកម៉ៃឃើល ខាណាវ៉ាស សូមជំទាស់នឹងមតិរបស់លោកស្រី មេធាវី ស៊ីលកេ ស្ទួដហ្សិនស្គី ពីព្រោះថាពេលនេះមិនមែនជាពេលដែលត្រូវពិភាក្សាពីបញ្ហាទាំងអស់នេះទេ ។ ទោះបីជាបានទទួលស្គាល់ថាភាគីដើមបណ្តឹងរដ្ឋប្បវេណីមានតួនាទីសំខាន់យ៉ាងណាក្តី ក៏លោកបានអះអាងថា «មេធាវីដើមបណ្តឹងរដ្ឋប្បវេណីត្រូវតែគោរពតាមគោលការណ៍ច្បាប់ដូចភាគីដទៃទៀតដែរ ។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីមិនមានសិទ្ធិលើកលែងនោះទេ» ។

បន្ទាប់មកទៀត លោក ស សូវ៉ាន បានជម្រាបដល់ចៅក្រមថាលោកក៏សូមជំទាស់នឹងការបញ្ចេញយោបល់របស់លោកស្រីមេធាវី ស៊ីលកេ ស្ទួដហ្សិនស្គី ដោយបន្ទំឲ្យលោកស្រីផ្តោតសំខាន់ទៅលើជនជាប់ចោទទាំងបួនរូប «មិនមែនផ្តោតលើរបបគ្រប់គ្រងនោះទេ» ។

ជាការឆ្លើយតបនឹងការជំទាស់របស់មេធាវីការពារក្តីជនជាប់ចោទ លោកប្រធាន និល ណុន បានណែនាំឲ្យលោកស្រីមេធាវី ស៊ីលកេ ស្ទួដហ្សិនស្គី គោរពតាមគោលដៅរបស់អង្គជំនុំជម្រះសាលាដំបូង នៅពេលពិភាក្សាពីសាក្សី និងជម្រាបដល់លោកស្រីថារាល់មតិដែលមិនមានជាប់ពាក់ព័ន្ធនឹងសេចក្តីបង្គាប់ខាងលើនេះមិនត្រូវបានអនុញ្ញាតឲ្យលើកឡើងទេ ។

លោកស្រីមេធាវី ស៊ីលកេ ស្ទួដហ្សិនស្គី បានឆ្លើយតបទៅវិញថាលោកស្រីជឿជាក់ថាលោកស្រីគួរតែត្រូវបានអនុញ្ញាតឲ្យនិយាយពីបរិបទខ្លះដែលជាប់ពាក់ព័ន្ធនឹងយោបល់របស់លោកស្រីដែលមានចំពោះសាក្សីណាម្នាក់ ។ ក្រោយពីបានលើកឡើងពី

សាក្សីបីរូបដែលលោកស្រីមានបំណងចង់និយាយមក លោកស្រី ស៊ីលកេ ស្ទូដហ្វ៊ីនស្គី បាននិយាយថា បើទោះបីជាលោកស្រីមិនបដិសេធលើសាក្សីណាម្នាក់ក៏ដោយ ក៏លោកស្រីចាំបាច់បកស្រាយពីគោលនយោបាយដែលចៅក្រមនិងភាគីទាំងអស់គួរតែដឹងថាហេតុអ្វីបានជាសាក្សីនៅមានចំនួនមិនគ្រប់គ្រាន់ ។ លោកស្រីបានផ្អាកការបញ្ចេញមតិរបស់លោកស្រី ខណៈពេលដែលឃើញថាចៅក្រមកំពុងតែពិភាក្សាគ្នា ។

លោកប្រធានចៅក្រម និល ណុន បាននិយាយខ្លាំងៗទៅកាន់លោកស្រីមេធាវី ស៊ីលកេ ស្ទូដហ្វ៊ីនស្គី ថា «ខ្ញុំបានរំពឹងទុកថាលោកស្រីនឹងយកគំរូតាមប្រធានសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាំងពីរ» ។ ក្រោយពីក្រើនរំឭកលោកស្រីមេធាវីឲ្យគោរពតាមសេចក្តីបង្គាប់របស់ចៅក្រមរួចមក លោកប្រធានចៅក្រម និល ណុន បានផ្តល់ឱកាសឲ្យលោកស្រីមេធាវីមានមតិឲ្យច្បាស់ៗសាជាថ្មីម្តងទៀត ។

បន្ទាប់មកទៀត លោកស្រី ស៊ីលកេ ស្ទូដហ្វ៊ីនស្គី មានមតិបន្តដោយឈរនៅវេទិកាជាមួយទឹកមុខអាក់អន់ចិត្ត ។ លោកស្រីបាននិយាយថាសាក្សីពីររូបគឺសាក្សី TCW១២៦ និងសាក្សី TCW៦០៤ មិនអាចផ្តល់ភ័ស្តុតាងលើគោលនយោបាយបទបញ្ជាររៀបអាពាហ៍ពិពាហ៍នៅក្នុងចន្លោះឆ្នាំ១៩៧៥-១៩៧៩ ទាំងស្រុងតាមគោលការណ៍របស់តុលាការទេ ។ សម្រាប់សាក្សីទីបីគឺសាក្សី TCW៧០៧ លោកស្រីបាននិយាយថា សាក្សីរូបនេះមិនអាចធ្វើជាតំណាងឲ្យសាក្សីទាំងអស់ដែលទទួលរងគ្រោះដោយសារគោលនយោបាយនេះទេ ។ ខណៈពេលដែលលោកស្រី ស៊ីលកេ ស្ទូដហ្វ៊ីនស្គី បានចាប់ផ្តើមស្នើសុំឲ្យចៅក្រមពិចារណាដាក់បញ្ចូលភ័ស្តុតាងមួយចំនួននៅក្នុងអង្គជំនុំជម្រះនេះ លោកមេធាវីការពារក្តី ម៉ៃឃើល ខារណាវ៉ាស បានក្រោកឈរ ហើយជំទាស់ ។

លោកម៉ៃឃើល ខារណាវ៉ាស បាននិយាយថា ទោះបីជាលោកមិនចង់ «ជំទាស់ប្រឆាំង» រហូតយ៉ាងណាក្តី លោកសូមជំទាស់ថា «រាល់ពេល ភាគីនីមួយៗតែងតែមិនគោរពតាមច្បាប់ឡើយ» ។ លោកបានចាត់ទុកការបញ្ចេញមតិយោបល់បែបនេះថាជាការរំលោភលើភាពអនុគ្រោះរបស់ចៅក្រមក្រោយពីបានគូសបញ្ជាក់ពីសេចក្តីបង្គាប់យ៉ាងច្បាស់របស់ចៅក្រមទាក់ទិននឹងភាពចាំបាច់នៃការដាក់ជូនការស្នើសុំបញ្ចូលសាក្សីបន្ថែមជាលាយលក្ខណ៍អក្សរដោយភាគីមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ។

ចៅក្រមបានសម្រេចមិនអនុញ្ញាតឲ្យលោកស្រីមេធាវី ស៊ីលកេ ស្ទូដហ្វ៊ីនស្គី មានមតិបន្តទៀតទេ ។ និយាយដួសមុខឲ្យចៅក្រមទាំងអស់ លោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉្រាយត៍ បាននិយាយថា មេធាវីដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានដឹកនាំដោយប្រធានសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីដែលគ្រប់គ្រងធ្វើជាតំណាងឲ្យក្រុមដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ។ លោកស្រីបានសួរទៅកាន់លោកស្រី ស៊ីលកេ ស្ទូដហ្វ៊ីនស្គី បញ្ជាក់ថាក្នុងតួនាទីជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណីដែលធ្វើការ «គាំទ្រព្រះរាជអាជ្ញានៅក្នុងអំឡុងអង្គជំនុំជម្រះក្តី តើលោកស្រីទទួលស្គាល់ ឬបដិសេធមិនទទួលស្គាល់សាក្សីណាទៀតដែរឬទេ ។ លោកស្រី ស៊ីលកេ ស្ទូដហ្វ៊ីនស្គី បានគូសបញ្ជាក់ថា លោកស្រីសូមធ្វើការទទួលស្គាល់សាក្សីទាំងបីរូបខាងលើនេះ ។ លោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉្រាយត៍ បានឆ្លើយតបថា «ដោយសារសាក្សីទាំងបីត្រូវបានស្នើសុំដោយព្រះរាជអាជ្ញាដែរនោះ ការសម្រេចទទួលយកសាក្សីទាំងបីរូបនេះគឺជាការគូសបញ្ជាក់ដ៏ត្រឹមត្រូវបំផុតមួយ» របស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ។

ក្រោយពីចៅក្រមបានពិភាក្សាគ្នាអស់មួយរយៈពេលក្រោយមក សហមេធាវីការពារក្តីរបស់ អៀង សារី លោក អាង ឧត្តម បានស្នើសុំឲ្យកូនក្តីរបស់លោកវិលត្រឡប់ទៅកាន់មន្ទីរឃុំឃាំងរបស់ខ្លួនវិញ ដើម្បីចូលរួមតាមដានដំណើរការអង្គសវនាការនេះដាច់ដោយឡែកតែឯងដោយសារបញ្ហាឈឺធ្ងន់ធ្ងរ ។ ចៅក្រមបានអនុញ្ញាតតាមការស្នើសុំរបស់លោកមេធាវី ហើយបានស្នើសុំឲ្យមន្ត្រីចាត់ចែងផ្នែកសោតទស្សន៍ធានាថាសម្ភារៈនៅក្នុងមន្ទីរឃុំឃាំងទាំងអស់ដំណើរការតាមធម្មតា ដើម្បីឲ្យជនជាប់ចោទ អៀង សារី នៅតែអាចតាមដានដំណើរការអង្គសវនាការនេះជាបន្តទៀត ។

បន្ទាប់មកទៀត លោកប្រធានចៅក្រម និល ណុន បានប្រកាសថា ដោយសារភាគីមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ចប់ការអង្កេតរបស់ខ្លួនដែលមានទៅលើបញ្ជីរាយនាមសាក្សី

បម្រុង នោះវគ្គសវនាការសាធារណៈនៃអង្គសវនាការបឋមនៅក្នុងអង្គជំនុំជម្រះក្តីលើសំណុំរឿង០០២នេះត្រូវបានចូលមកដល់ទីបញ្ចប់ហើយ ។ បន្ទាប់ពីការផ្អាកដំណើរការសវនាការមួយរយៈពេលខ្លី តុលាការនឹងចាប់ផ្តើមបន្តអង្គសវនាការដោយសម្ងាត់ដូចដែលបានស្នើសុំដោយសហព្រះរាជអាជ្ញា ។

## អង្គសវនាការថ្ងៃនេះត្រូវបានបញ្ចប់ទៅដោយភាពមិនចុះសម្រុងគ្នា និងការជជែកដេញដោល

យ៉ាងណាមិញ មុននឹងចៅក្រមបានបញ្ចប់ដំណើរការអង្គសវនាការនេះ លោកមេធាវីការពារក្តី ម៉ៃឃើល ខារណាវ៉ាស បានក្រោកឈរ ហើយក៏ត្រូវបានកត់សម្គាល់ដោយចៅក្រម ។ លោកបានបកស្រាយថា លោកបានដឹងថាភាគីទាំងអស់អាចប្រើប្រាស់ពេលវេលាដែលនៅចុងបញ្ចប់នៃអង្គសវនាការនេះដើម្បីពិភាក្សាពីបញ្ហាផ្សេងៗបន្ថែមទៀត ។ លោកមេធាវីបានស្នើសុំឲ្យលោកទទួលបានការអនុញ្ញាតដើម្បីមានមតិយ៉ាងខ្លីចុងក្រោយមុននឹងការបញ្ចប់ទៅនៃអង្គសវនាការបឋមនេះ ។ លោកមានបំណងចង់លើកឡើងពីបញ្ហាបីដែលលោកជឿជាក់ថាមានជាប់ពាក់ព័ន្ធនឹងយុត្តាធិការរបស់តុលាការ ហេតុដូច្នេះ ក្រុមមេធាវីការពារក្តីរបស់ជនជាប់ចោទ អៀង សារី គិតថាបញ្ហាទាំងអស់នេះត្រូវតែរៀបចំឲ្យមានការពិភាក្សាផ្ទាល់មាត់មួយទៀត ។

លោកប្រធានចៅក្រម និល ណុន បានស្នើឲ្យលោកមេធាវី ម៉ៃឃើល ខារណាវ៉ាស ធ្វើការគូសបញ្ជាក់បញ្ហាទាំងបីនោះដែលលោកមានបំណងចង់ពិភាក្សា ។ លោកម៉ៃឃើល ខារណាវ៉ាស បានឆ្លើយតបថា បញ្ហាទាំងបីនោះមានដូចជា ៖ ១) ការអនុវត្តច្បាប់អន្តរជាតិ ២) ការអនុវត្តនិងភាពជាប់ពាក់ព័ន្ធនឹងការទទួលខុសត្រូវលើបទបញ្ជា និង ៣) ការជាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ លោកបានអះអាងថា បញ្ហាទាំងបីនេះគឺជាបញ្ហាយុត្តាធិការ បើទោះបីជាបញ្ហាទាំងនេះអាចនឹងចូលក្នុង «សណ្ឋាននៃច្បាប់» ក៏ដោយ ។ អាស្រ័យហេតុនេះ ក្រុមមេធាវីការពារក្តីរបស់លោកស្នើសុំពេលវេលាលើកឡើងបញ្ហាទាំងអស់នេះឲ្យបានលម្អិតនៅក្នុងអំឡុងអង្គសវនាការនេះតែម្តង ឬក៏នៅអង្គសវនាការបឋមខាង មុខទៀត ។

លោក វីកទ័រ គូប៉េ មេធាវីការពារក្តីរបស់ជនជាប់ចោទ នួន ជា បានជម្រាបចៅក្រមថា លោកក៏មានបញ្ហាមួយចំនួនដែលត្រូវពិភាក្សាបន្ថែមដែរមុននឹងអង្គសវនាការបឋមនេះបញ្ចប់ទៅ ។ ដោយដឹងថា ភាគីទាំងអស់មានឱកាសជជែកដេញដោលជាសាធារណៈទាក់ទិននឹងបញ្ហាបញ្ជីរាយនាមសាក្សី លោកបានស្នើសុំឲ្យចៅក្រមគូសបញ្ជាក់លើវិធានផ្ទៃក្នុង៨០ស្ទួនរបស់តុលាការខ្មែរក្រហមដែលតម្រូវឲ្យអង្គជំនុំជម្រះសាលាដំបូង «ធ្វើការពិចារណាលើបញ្ជីរាយនាមសាក្សី និងអ្នកជំនាញសំខាន់ៗដែលត្រូវបានប្រគល់ជូនដោយភាគីជាប់ពាក់ព័ន្ធទាំងអស់បើយោងតាម» វិធានផ្ទៃក្នុងនេះ ។ លោក វីកទ័រ គូប៉េ បានស្នើសុំឲ្យចៅក្រមផ្តល់ជាការណែនាំលើពាក្យ «ពិចារណា» ហើយបញ្ជាក់ថាតើអាចនឹងមានអង្គសវនាការសម្រាប់ការជជែកពិភាក្សាផ្ទាល់មាត់លើការស្នើសុំបញ្ចូលសាក្សីបន្ថែមទៀតរបស់ភាគីទាំងអស់ដែរឬទេ ។

លោកស្រី អេលីហ្សាប៉ែត ស៊ីម៉ូណូ ហ្វុត មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក៏បានជម្រាបចៅក្រមថាក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក៏មានបំណងចង់ឲ្យមានអង្គសវនាការបឋមមួយទៀតដែលអាចឲ្យភាគីទាំងអស់ពិភាក្សាលើបញ្ជីរាយនាមសាក្សី និងបញ្ហាច្បាប់បន្ថែមផ្សេងទៀតដោយស្នើសុំឲ្យចៅក្រមណែនាំឲ្យបានច្បាស់ថាតើអាចនឹងមានអង្គសវនាការមួយទៀតដែរឬទេ ហើយប្រសិនបើមានតើអង្គសវនាការនោះអាចនឹងដំណើរការនៅថ្ងៃណា ។

ជាចុងក្រោយ លោក វីលៀម ស្មីត សហព្រះរាជអាជ្ញារងអន្តរជាតិមានមតិគាំទ្រឲ្យមានអង្គសវនាការបឋមមួយទៀតដោយជំរុញឲ្យអង្គសវនាការនោះប្រព្រឹត្តទៅដោយសាធារណៈ ។ លោក វីលៀម ស្មីត ក៏បានស្នើសុំឲ្យមានការពិភាក្សាលើបញ្ហាជាច្រើនតាមតែអាចធ្វើបានមុននឹងអង្គជំនុំជម្រះក្តីចាប់ផ្តើម ដើម្បីជួយឲ្យដំណើរការអង្គជំនុំជម្រះក្តីសម្រាប់សំណុំរឿងនេះដំណើរការទៅដោយរលូន ។

លោកចៅក្រម ហ្សង់ ម៉ាក ឡាវ៉ែរ៉ញ បានសួរទៅកាន់លោក ម៉ៃឃើល ខារណាវ៉ាស ទាក់ទងនឹងបញ្ហា ដែលលោកមេធាវីបានលើកឡើងមុននេះដោយសួរបញ្ជាក់ថាតើបញ្ហាទាំងអស់នេះគឺជាបញ្ហាដែលត្រូវបានយកមកពិភាក្សាដោយគ្មានការដាក់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ ឬថាតើបញ្ហានេះគឺជាបញ្ហាថ្មី ។

លោកមេធាវី ម៉ៃឃើល ខាណាវ៉ាស បានឆ្លើយតបថា ក្រុមមេធាវីការពារក្ដីរបស់លោកបានដាក់ជាសេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរលើប្រធានបទទាំងអស់នេះហើយ ។ ប៉ុន្តែលោកបានអះអាងថា យោងតាមវិធានផ្ទៃក្នុង៨៩.១(ក)និង(ខ) ប្រធានបទទាំងបីនេះគឺមានជាប់ពាក់ព័ន្ធនឹងប្រភេទបញ្ហាដែលចាំបាច់ត្រូវតែដោះស្រាយមុននឹងអង្គជំនុំជម្រះក្ដីចាប់ផ្ដើម ។

បន្ទាប់មកទៀត លោកម៉ៃឃើល ខាណាវ៉ាស បានងាកមកនិយាយពីប្រធានបទថ្មីមួយដោយលើកឡើងពីបញ្ហាការប្រព្រឹត្តឧក្រិដ្ឋកម្មរួមប្រភេទទីបីដែលជាប្រភេទនៃការទទួលខុសត្រូវដែលជនជាប់ចោទអាចនឹងត្រូវបានកាត់ទោសឲ្យទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តដោយអ្នកចូលរួមនៅក្នុងឧក្រិដ្ឋកម្មនោះ ។ លោកមេធាវីបានបកស្រាយថា អង្គជំនុំជម្រះសាលាដំបូងបានចេញជាសេចក្ដីសម្រេចជាលាយលក្ខណ៍អក្សរចំនួន៦៨ទំព័រដែលសម្រេចថាការប្រព្រឹត្តឧក្រិដ្ឋកម្មរួមប្រភេទទីបីនេះមិនអាចយកមកអនុវត្តសម្រាប់អង្គនីតិវិធីទាំងអស់នេះបានទេ ពីព្រោះការប្រព្រឹត្តឧក្រិដ្ឋកម្មរួមប្រភេទទីបីនេះមិនបង្កើនកម្រិតនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងអំឡុងឆ្នាំ (១៩៧៥-១៩៧៩) ដែលគ្របដណ្ដប់លើយុត្តាធិការពេលវេលារបស់តុលាការឡើយ ។ លោកម៉ៃឃើល ខាណាវ៉ាស ក៏បានអះអាងថា ព្រះរាជអាជ្ញាបាន «ពន្យារពេលដំណើរការនីតិវិធី» ដោយស្នើសុំឲ្យចៅក្រមផ្ដល់សេចក្ដីណែនាំបន្ថែមទៀតពីសាក្សី ឬអ្នកជំនាញ ។ ក្រោយពីបាននិយាយថា ភាគីទាំងអស់ចាំបាច់ត្រូវមានការគូសបញ្ជាក់និងភាពច្បាស់លាស់លើបញ្ហាដែលត្រូវយកមកពិភាក្សានៅក្នុងអង្គជំនុំជម្រះក្ដីនេះមក លោកមេធាវីបានជំរុញឲ្យចៅក្រមចេញសេចក្ដីសម្រេចទាក់ទងនឹងបញ្ហានេះឲ្យបានឆាប់តាមតែអាចធ្វើបាន ។

លោក វីលៀម ស្មីត បានឆ្លើយតបនឹងមតិរបស់លោកម៉ៃឃើល ខាណាវ៉ាស ដោយយល់ស្របថា បញ្ហាទាំងអស់នេះចាំបាច់ត្រូវសម្រេចឲ្យបានឆាប់រហ័សបំផុត ។ នៅក្នុងការឆ្លើយតបទៅនឹងមតិដែលថា ព្រះរាជអាជ្ញាបានពន្យារពេលដំណើរការអង្គសវនាការ លោក វីលៀម ស្មីត បាននិយាយថាសហព្រះរាជអាជ្ញាបានបំពេញដាក់ជូនសេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរនិងផ្ដល់ជាការឆ្លើយតបទាន់ពេលនិងលឿនជាងភាគីទាំងអស់ទៀតផង ។ បន្ទាប់ពីបានចាត់ទុកសេចក្ដីសន្និដ្ឋានរបស់មេធាវីការពារក្ដីជនជាប់ចោទ ជាពិសេសសេចក្ដីសន្និដ្ឋានរបស់ក្រុមមេធាវីការពារក្ដីជនជាប់ចោទ អៀង សារី ថាមាន «ខ្លឹមសារវែងជ្រុលពេក» លោក វីលៀម ស្មីត បាននិយាយថា សហព្រះរាជអាជ្ញាមិនបានធ្វើអ្វីដែលធ្វើពន្យារដល់ដំណើរការអង្គនីតិវិធីនោះទេ ។

លោកម៉ៃឃើល ខាណាវ៉ាស បានការពារអំណះអំណាងរបស់លោកដោយនិយាយថា លោកមានការព្រួយបារម្ភពីការបញ្ចេញមតិយោបល់របស់លោកសហព្រះរាជអាជ្ញា វីលៀម ស្មីត ដែលអាចធ្វើការដាក់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារក្ដីលេចឮដល់សាធារណជន ។ លោកមេធាវីបានអះអាងថា «ខ្ញុំមានតួនាទីធ្វើជាតំណាងឲ្យកូនក្ដីរបស់ខ្ញុំ» ហើយលោកបាននិយាយបន្តទៀតថាលោកមានបំណងបំពេញកិច្ចការរបស់លោកឲ្យអស់ពីសមត្ថភាពនៅក្នុងការគាំទ្រការពារជនជាប់ចោទ អៀង សារី ។ ជាងនេះទៅទៀត លោកបានបញ្ជាក់ថា ព្រះរាជអាជ្ញាមិនបានបំពេញកិច្ចការរបស់ខ្លួនឲ្យអស់ពីសមត្ថភាពទេ ដោយលើកឡើងការប្រព្រឹត្តឧក្រិដ្ឋកម្មរួមប្រភេទទីបី «ដែលជាឧក្រិដ្ឋកម្មពោរពេញដោយភាពលម្អៀង» ។ លោកជឿថា ប្រធានបទនេះគួរតែត្រូវបានច្រានចោលដោយស្នើសុំឲ្យចៅក្រមចេញសេចក្ដីសម្រេចលើបញ្ហាការប្រព្រឹត្តឧក្រិដ្ឋកម្មរួមប្រភេទទីបីនេះឲ្យបានឆាប់តាមតែអាចធ្វើទៅបាន ដើម្បីឲ្យភាគីទាំងអស់ជ្រាបថាតើការប្រព្រឹត្តឧក្រិដ្ឋកម្មរួមប្រភេទទីបីនេះមានជាប់ពាក់ព័ន្ធនឹងសំណុំរឿងនេះដែរឬយ៉ាងណា និងដើម្បីឲ្យលោកមេធាវីខ្លួនឯងផ្ទាល់អាចធ្វើជាតំណាងឲ្យកូនក្ដីរបស់ខ្លួនកាន់តែមានប្រសិទ្ធភាព ។

ក្រោយពីការតតាំងគ្នាដ៏តានតឹងមក ចៅក្រមបានបញ្ឈប់ដំណើរការនីតិវិធីមួយរយៈដោយប្រកាសបញ្ចប់អង្គសវនាការបឋមសម្រាប់សំណុំរឿង០០២នេះ ។ អង្គសវនាការតាមនីតិវិធីនៃច្បាប់រំពឹងនឹងចាប់ផ្ដើមនៅខែសីហា ឬកញ្ញាខាងមុខនេះ ។ យ៉ាងណាមិញ យើងមិនទាន់ដឹងច្បាស់ថាតើតុលាការនឹងកោះហៅឲ្យមានអង្គសវនាការបន្ថែមទៀតមុននឹងអង្គជំនុំជម្រះក្ដីចាប់ផ្ដើមយ៉ាងណានោះទេ ។

**គ្រីស្ទីន អ៊ីវេន**

# អៀង សារី ត្រូវតែមានវត្តមានដើម្បីទទួលនូវការកាត់ទោស

ដំណើរការកាត់សេចក្តីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាកាលពីថ្ងៃទី២៨ ខែមិថុនា កន្លងទៅបានពិភាក្សាអំពីវិសាលភាព និងដែនកំណត់នៃការអភ័យទោសនិងការលើកលែងទោសដែលបានផ្តល់ជូន អៀង សារី កាលពីឆ្នាំ១៩៩៦ ។ ក្នុងចំណោមប្រធានបទជាច្រើនដែលលើកមកនិយាយ ព្រះរាជអាជ្ញាបានអះអាងថា ការអភ័យទោស និងការលើកលែងទោសរបស់ អៀង សារី នៅតែអាចយកមកអនុវត្តន៍បានចំពោះឧក្រិដ្ឋកម្មអន្តរជាតិនៅក្នុងអាជ្ញាយុកាលច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ តាមគំនិតខ្ញុំ បើសិនជា អៀង សារី មិនត្រូវបានកាត់ទោសទេ នោះនឹងមានកំហឹងជាច្រើនពីសំណាក់ប្រជាជនកម្ពុជា ។ ក្នុងនាមជាមេដឹកនាំជាន់ខ្ពស់ម្នាក់នៃរបបកម្ពុជាប្រជាធិបតេយ្យ អៀង សារី ត្រូវតែបានកាត់ទោសដោយអង្គជំនុំជម្រះនេះ ។ លើសពីនោះ តុលាការប្រជាជនបដិវត្តន៍ក្នុងឆ្នាំ១៩៧៩ គឺជាតុលាការវិនិច្ឆ័យទោសមួយ ហើយច្បាប់ដាក់ខ្មែរក្រហមឲ្យនៅក្រៅច្បាប់ឆ្នាំ១៩៩៤គឺមានលក្ខណៈបណ្តោះអាសន្ននិងខុសពីធម្មតា ។ គ្មាននរណាម្នាក់អាចប្រើឧទាហរណ៍ទាំងពីរនេះជាមូលដ្ឋានគ្រឹះក្នុងការដោះលែងឲ្យមានសេរីភាពនូវមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់ម្នាក់ដែលទទួលខុសត្រូវពីបទប្រព្រឹត្តអំពើប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនេះបានទេ ។

ការអះអាងដោយក្រុមការពារក្តីរបស់ អៀង សារី ពិតជាគួរឲ្យចាប់អារម្មណ៍ណាស់ ។ ក្រុមការពារក្តីរបស់ អៀង សារី បាននិយាយថា មនុស្សម្នាក់មិនអាចកាត់ទោសពីរដងបានទេពីបទឧក្រិដ្ឋតែមួយ ហើយបានអះអាងទៀតថា នេះមិនមែនជានីតិរដ្ឋដ៏ត្រឹមត្រូវដែលកម្ពុជាត្រូវតែអនុវត្តន៍តាមនោះទេ ។ ការផ្តាច់ខ្លួនរបស់ អៀង សារី ចេញពីចលនាខ្មែរក្រហមបានធ្វើឲ្យគោលនយោបាយសមាហរណកម្មកាន់តែមានល្បឿនលឿនឡើង ។ អៀង សារី បានផ្តាច់ខ្លួនចូលជាមួយរដ្ឋាភិបាលដោយការដោះដូរជាថ្នូរនឹងការអភ័យទោសនិងការលើកលែងទោសដល់ខ្លួន ។ បើសិនជាគាត់ត្រូវបានកាត់ទោសម្តងទៀត នោះ អៀង សារី នឹងមិនចុះចូលជាមួយរដ្ឋាភិបាលទេ ។ ប៉ុន្តែ បើសិនជាការអភ័យទោសនិងការលើកលែងទោស សម្រាប់ អៀង សារី គឺជាឧបសគ្គក្នុងការការពារមិនឲ្យមានការកាត់ទោស អនាគតនឹងមើលឃើញថា អៀង សារី គឺជាឧក្រិដ្ឋជននៃរបបប្រល័យពូជសាសន៍ដែលគួរតែបន្តធ្វើសង្គ្រាមទៅទៀតឲ្យបានយូរតាមតែអាចធ្វើទៅបាន ហើយបន្ទាប់មកយកលេសនៃសង្គ្រាមនោះដើម្បីទាមទារសេរីភាពផ្ទាល់ខ្លួន ។ ឥឡូវនេះ អៀង សារី កំពុងស្ថិតនៅក្នុងមន្ទីរឃុំឃាំង ហើយ អៀង សារី ត្រូវតែមានអារម្មណ៍បន្ទាក់ទឹកចិត្តនិងក្បត់ខ្លួនឯង ។ ប៉ុន្តែ យើងចង់ឲ្យគាត់មានអារម្មណ៍បែបនេះ ។

ប្រជាជនកម្ពុជាក៏មានអារម្មណ៍ស្រដៀងគ្នានឹង អៀង សារី



អៀង សារី ក្នុងបន្ទប់សវនាការ ឆ្នាំ២០១១



ដែរដោយសារតែសម័យអង្គការបដិវត្តន៍ខ្មែរក្រហមពីឆ្នាំ ១៩៧៥ ដល់១៩៧៩ ។ មនុស្សជាច្រើនម៉ឺននាក់ត្រូវបានបញ្ជូនទៅកាន់មន្ទីរឃុំឃាំងចំនួន១៩៦ ទូទាំងប្រទេសដោយគ្មានជំនុំជម្រះទោសនិងកាត់ក្តីឲ្យបានត្រឹមត្រូវ ។ នៅមន្ទីរស-២១ អ្នកទោសត្រូវបានដកហូតសិទ្ធិទាំងអស់ បង្អត់អាហារ ធ្វើទារុណកម្ម សួរចម្លើយ និងសម្លាប់ដោយកំហុសតូចតាចនៃគោលនយោបាយរបស់អង្គការ ដូចជា លួចអាហារដែលដាំក្បែរផ្ទះ ធ្វើឲ្យបាក់ឧបករណ៍កសិកម្មផ្សេងៗ ការចោទប្រកាន់ដោយការខ្ជិលច្រអូស និងការលួចហូបអាហារម្នាក់ឯង ។ ឧក្រិដ្ឋកម្មធំៗរួមមាន បញ្ជរវន្តមន្ត្រីរបស់ លន់ នល់ អ្នករស់នៅទីក្រុង និងជនជាតិភាគតិច ។ នៅមានឧទាហរណ៍ជាច្រើនទៀតដែលខ្មែរក្រហមយកទៅសម្លាប់ ។ អ្នកដែលត្រូវបានចោទប្រកាន់បានស្លាប់ទាំងភាពអយុត្តិធម៌និងអាណោចអធ័ម ។

ខ្ញុំចាំថា ខ្មែរក្រហមធ្លាប់ប្រើពាក្យស្លោកមួយថា «ស៊ូចាប់ដប់នាក់ប្រឡំ ប្រសើរជាងដោះលែងម្នាក់ខុស» ។ តាមទ្រឹស្តីនេះយើងអាចយល់បានថា សត្រូវខាងក្នុងមានភាពសាហាវឃោរឃៅនិងគ្រោះថ្នាក់ណាស់ចំពោះបដិវត្តន៍ ដែលត្រូវចាប់ខ្លួនជនសង្ស័យគ្រប់ដប់នាក់ដោយលាបឈ្មោះអ្នកទាំងនោះថាជាជនក្បត់ ហើយខ្មែរក្រហមមិនដែលមានអារម្មណ៍ថាខ្លួនឯងបានធ្វើខុសទេ ។ សម្រាប់អ្នកដែលត្រូវបានចាប់ប្រឡំម្នាក់ៗអាចយល់បានថា អ្នកដែលត្រូវចាប់ខ្លួននោះថាមានអារម្មណ៍បែបណាមុននឹងស្លាប់ ។

ថ្ងៃនេះ អៀង សារី ប្រហែលជានិយាយថា ការអភ័យទោសនិងការលើកលែងទោសដែលខ្លួនទទួលបានរួចផុតពីការជំនុំជម្រះទោស ហើយថាការជំនុំជម្រះទោសនេះគឺ «ខុសច្បាប់» សម្រាប់គាត់ដែលយកមកកាត់ទោសម្តងទៀត ។ ខ្ញុំមិនយល់ស្របទេ ។ អៀង សារី ត្រូវតែមានវត្តមានដើម្បីជំនុំជម្រះទោស ហើយ អៀង សារី ត្រូវតែទទួលថា តាមផ្លូវច្បាប់ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវតែសម្រេចថាតើគាត់ត្រូវរស់នៅដោយមានសេរីភាពម្តងទៀតដែរឬយ៉ាងណា ។

**អេង កុកថាយ**



អៀង សារី ជាមួយថ្នាក់ដឹកនាំបរទេសក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

# ខៀវ សំផន មិនដែលទុកចិត្តប្រជាជនរបស់ខ្លួនទេ

ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ខៀវ សំផន ស៊ុះស្វែងរកមើលនរណាដែលខ្លួនមិនចូលចិត្ត ឬនរណាដែលខ្លួនស្អប់ ។ អ្នកទាំងនោះនឹងត្រូវចាត់ទុកជាសត្រូវផ្ទៃក្នុងដែលជាគោលដៅក្នុងការសម្លាប់ចោល ។ ប៉ុន្តែ នៅថ្ងៃនេះ ខៀវ សំផន បានផ្លាស់ប្តូរទស្សនៈយោបល់ និងគំនិតរបស់ខ្លួនទាំងស្រុង ។ ផ្ទុយពីកាលរបបកម្ពុជាប្រជាធិបតេយ្យ ពេលនេះ ខៀវ សំផន ស៊ុះស្វែងរកមើលនរណាដែលគាំទ្រខ្លួន និងនរណាដែលខ្លួនទុកចិត្តជាទីបំផុតដែលអាចផ្តល់សក្ខីកម្មដោះបន្ទុកខ្លួន ។

ការផ្តល់សក្ខីកម្មដែលធ្វើឡើងនៅសាលាក្តីខ្មែរក្រហមគឺជាក្តីបារម្ភដ៏ធំរបស់ ខៀវ សំផន ។ ទើបតែពេលដែល ខៀវ សំផន ឡើងតុលាការខ្មែរក្រហមនេះទើបគាត់ភ្ញាក់រឭកថា អ្នកដែលរស់រានមានជីវិតពីរបបខ្មែរក្រហមភាគច្រើនសុទ្ធតែប្រឆាំងនឹងខ្លួន ។ ត្រង់ចំណុចនេះ ខៀវ សំផន ពិតជាមានសំណួរជាច្រើនដើម្បីចោទសួរមកខ្លួនឯងវិញ ។ ខៀវ សំផន គួរតែសួរខ្លួនឯងថាហេតុអ្វីបានជាអ្នករួចរស់ជីវិតពីរបបរបស់ខ្លួនស្អប់ ហើយប្រឆាំងនឹងខ្លួនខណៈពេលដែលខ្លួនធ្លាប់អះអាងម្តងហើយម្តងទៀតថា របបរបស់ខ្លួនមិនបានធ្វើទុក្ខទោសដល់ប្រជាជន និងមិនបានធ្វើការកាប់សម្លាប់ប្រជាជនទេនោះ ។ បើសិនជារបបរបស់ខ្លួនមិនបានធ្វើអ្វីខុស ខៀវ សំផន មិនត្រូវខ្លាចសាក្សីណាម្នាក់ទេ ។

កាលពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១១ នៅសាលាក្តីខ្មែរក្រហម ខៀវ សំផន បានតវ៉ាថា សាក្សីដែលមាននៅក្នុងបញ្ជីឈ្មោះបណ្តោះអាសន្នដែលផ្តល់ដោយចៅក្រមភាគច្រើនមិនមែនជាអ្នកគាំទ្រខ្លួនទេ ។ ខៀវ សំផន បាននិយាយនៅក្នុងអង្គសវនាការថា «ខ្ញុំកត់សម្គាល់ឃើញថា សាក្សីភាគច្រើនលើសលប់ដែលមាននៅក្នុងបញ្ជីគឺជាសាក្សីរបស់សហព្រះរាជអាជ្ញា ។ សាក្សីដែលខ្ញុំស្នើមិនមានឃើញឈ្មោះនៅក្នុងបញ្ជីទេ» ។

ពេលនេះ ខៀវ សំផន បារម្ភពីភាពអយុត្តិធម៌ ហើយស្រេកឃ្លានចង់បានយុត្តិធម៌ ។ ប៉ុន្តែ កាលពីអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ប្រជាជនកម្ពុជារាប់ម៉ឺននាក់ត្រូវបានដាក់ក្នុងមន្ទីរឃុំឃាំង បង្ខំឲ្យឆ្លើយនូវអ្វីដែលអ្នកទោសមិនដែលធ្លាប់ដឹង ហើយក្រោយមកអ្នកទាំងនោះត្រូវយកទៅសម្លាប់ចោលយ៉ាងអាណោចអធ័ម ដោយគ្មានជំនុំជម្រះទោសអ្វីទាំងអស់ ហើយអ្នកដែលបានស្លាប់នោះ មិនដែលទទួលបានភាពយុត្តិធម៌ទាល់តែសោះមុននឹងស្លាប់ ។ ពេលនោះ ខៀវ សំផន ធ្វើពុតជាមិនដឹងថាជនរងគ្រោះទាំងនោះក៏ចង់បានយុត្តិធម៌ដូចខ្លួននៅពេលនោះដែរ ។



ខៀវ សំផន ក្នុងបន្ទប់សវនាការ ឆ្នាំ២០១១

នៅក្នុងបន្ទប់សវនាការ ខៀវ សំផន បាននិយាយថា យុត្តិធម៌នឹងមិនអាចកើតមានទេ បើសិនជាសាក្សីរបស់ខ្លួនមិន

បានចូលខ្លួនមកធ្វើសក្ខីកម្ម ។ ប៉ុន្តែកាលពីរបបខ្មែរក្រហម ប្រជាជនកម្ពុជាដែលត្រូវបានចាប់ខ្លួនមិនមានសាក្សីមកធ្វើសក្ខីកម្មដើម្បីគាំទ្រទេ ហើយជនរងគ្រោះទាំងនោះក៏មិនអាចនិយាយការពារខ្លួនឯងបានដែរ ។ ខៀវ សំផន បានអះអាងថា «ដើម្បីធ្វើឲ្យដំណើរការសវនាការនេះមានភាពរលូននិងត្រឹមត្រូវ និងដើម្បីទទួលបានការពិត និងដើម្បីឲ្យភាពស្មោះត្រង់និងភាពត្រឹមត្រូវរបស់ខ្ញុំវាលេចឡើងបាន លុះត្រាតែតុលាការយល់ព្រមសុខចិត្តស្តាប់សាក្សីសំខាន់ៗរបស់ខ្ញុំ តុលាការត្រូវតែយកចិត្តទុកដាក់ស្តាប់សាក្សីដែលក្រុមរបស់ខ្ញុំស្នើ» ។

តាមសេចក្តីថ្លែងការណ៍របស់ ខៀវ សំផន យើងអាចយល់បានថា ខៀវ សំផន ក៏ដឹងដែរថាអ្នកដែលត្រូវសម្លាប់កាលពីរបបខ្មែរក្រហមសុទ្ធតែត្រូវការយុត្តិធម៌ ។ សាធារណជនអាចយល់បានថាតើ ខៀវ សំផន ធ្វើពុតជាមិនដឹង ឬក៏គាត់មិនដឹងមែន ហើយទើបតែដឹងពេលនេះដោយសារតែខ្លួនធ្លាក់ចូលក្នុងស្ថានភាពដូចអ្នកទោសកាលពីរបបកម្ពុជាប្រជាធិបតេយ្យដែរ ។

សាក្សីដែលក្រុមរបស់ ខៀវ សំផន ស្នើគឺជាអ្នកដែលធ្លាប់ស្គាល់គាត់យ៉ាងជិតស្និទ្ធ អ្នកដែលធ្លាប់រស់នៅជាមួយគាត់ និងអ្នកដែលដឹងថាគាត់បានធ្វើអ្វីខ្លះកាលពីរបបខ្មែរក្រហម ។ ដូចកាលពីរបបខ្មែរក្រហមដែរ ខៀវ សំផន មិនទុកចិត្តនរណាក្រៅពីគូកន និងមិត្តជិតស្និទ្ធបំផុតរបស់ខ្លួនទេ ។ ខៀវ សំផន មិនទុកចិត្តប្រជាជនកម្ពុជាទេតាំងពីរបបកម្ពុជាប្រជាធិបតេយ្យរហូតដល់ពេលបច្ចុប្បន្ននេះ ។ ម្យ៉ាងវិញទៀត គាត់បែរជាចោទប្រកាន់ប្រជាជនកម្ពុជាជាអ្នក «បំផ្លើស» ទៅវិញ ។ បើសិនជា ខៀវ សំផន អះអាងថារបបរបស់ខ្លួនមិនបានសម្លាប់មនុស្ស គាត់គួរតែទុកចិត្តអ្នកដែលបានរស់ជីវិតពីរបបខ្មែរក្រហមដោយអនុញ្ញាតឲ្យអ្នកទាំងនោះនិយាយពីបទពិសោធន៍ជីវិតកាលពីរបបខ្មែរក្រហមនៅក្នុងបន្ទប់សវនាការ ។

**ញាណ សុជាតិ**

# ប្រកាសរកស្វាមីដែលបានបាត់ខ្លួន

លោកយាយ ប៉ុល កាឡាង សព្វថ្ងៃអាយុ៧០ឆ្នាំរស់នៅផ្ទះលេខ៦B ផ្លូវ២៩៦ សង្កាត់ទួលស្វាយព្រៃ២ ខណ្ឌចំការមន រាជធានីភ្នំពេញ សូមស្វែងរកស្វាមីឈ្មោះ ឌុល គៀ ហៅ នូវ ដែលបានបែកគ្នាតាំងពីដើមឆ្នាំ១៩៧០ ។ ឌុល គៀ គឺជាអតីតគ្រូបង្រៀននៅសាលាអនុវិទ្យាល័យបាផ្លង់នៅឃុំព្រៃឈរស្រុកកំពង់ត្របែក ខេត្តព្រៃវែង ។ នៅដើមឆ្នាំ១៩៧០ ដោយ ឌុល គៀ ជាប់លេខមួយក្នុងការប្រកួតកីឡាបាល់ទះ សម្តេច នរោត្តមសីហនុ បានហៅគាត់មកភ្នំពេញ បន្ទាប់មកក៏បញ្ជូនគាត់ទៅសហរដ្ឋអាមេរិក ។ រយៈពេលប្រហែលមួយខែក្រោយមកក៏មានរដ្ឋប្រហារទម្លាក់ សម្តេច នរោត្តម សីហនុ ហើយ ឌុល គៀ ក៏បាត់ដំណឹងគាត់សូន្យឈឹងរហូតមក ។ បីឆ្នាំមុន ប៉ុល កាឡាង ឮដំណឹងថា ឌុល គៀ បានមកលេងស្រុកខ្មែរហើយបានមករកគាត់នៅឯស្រុកកំណើតនៅខេត្តព្រៃវែង ។ បើបងប្អូនណាដឹងដំណឹងពី ឌុល គៀ ឬដឹងថាគាត់រស់នៅទីណាសូមទំនាក់ទំនងលោកយាយ ប៉ុល កាឡាង តាមអាស័យដ្ឋានខាងលើ ឬតាមទូរស័ព្ទលេខ ០៧៨ ៩០៦ ២៩៦ ឬ ០១៧ ៨៧៦ ៥០៩ ឬតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។ រូបថតដែលភ្ជាប់ជាមួយនេះគឺជារូបរបស់ ឌុល គៀ ដែលថតនៅឆ្នាំ១៩៧០ ពេលគាត់ទៅលេងខេត្តសៀមរាប ។ ***សូមអរគុណ***





# អៀង ធីរិទ្ធ : ស្ត្រីដំបូងរបស់កម្ពុជា

*អៀង ធីរិទ្ធ កើតនៅថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៣២ ក្នុងត្រកូលអ្នកស្តុកស្តម្ភមួយនៅក្នុងទីក្រុងភ្នំពេញ ។ អៀង ធីរិទ្ធ ជាស្ត្រីខ្មែរដំបូងគេដែលបានបញ្ចប់ការសិក្សាពីប្រទេសបារាំងផ្នែកភាសាអង់គ្លេស ។ អៀង ធីរិទ្ធ ក៏អាចជាស្ត្រីដំបូងម្នាក់ដែលបានបង្កើតសាលាភាសាអង់គ្លេសឯកជនមុនគេនៅទីក្រុងភ្នំពេញដែលគាត់ជាគ្រូបង្រៀននៅទីនោះ ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ អៀង ធីរិទ្ធ ក៏ជាស្ត្រីម្នាក់ក្នុងចំណោមស្ត្រីដ៏តិចតួចដែលបានកាន់តំណែងជាន់ខ្ពស់នៅក្នុងជួររដ្ឋាភិបាលដោយមានមុខតំណែងជារដ្ឋមន្ត្រីសង្គមកិច្ច និងសុខាភិបាល ។ តំណែងរបស់ អៀង ធីរិទ្ធ គឺជាកិច្ចការដ៏ពិសេសមួយក្នុងរបបកម្ពុជាប្រជាធិបតេយ្យដោយហេតុថាកិច្ចការសង្គមកិច្ចគឺជាការងារដ៏ថ្លៃថ្នូរបំផុតមួយសម្រាប់បដិវត្តន៍ ។ ឥឡូវនេះ អៀង ធីរិទ្ធ ក៏ជាស្ត្រីកម្ពុជាទីមួយដែលត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដែលបានប្រព្រឹត្តកាលក្នុងអំឡុងពីឆ្នាំ១៩៧៥ រហូតដល់ឆ្នាំ១៩៧៩ ដោយបានរួមចំណែកក្នុងការប្រព្រឹត្តបទឧក្រិដ្ឋក្នុងប្រទេសកម្ពុជា ។*

*តាមប្រពៃណីទំនៀមទំលាប់ពីបុរាណមក ស្ត្រីខ្មែរត្រូវបានចាត់ទុកថាមានអត្តចរិតទន់ភ្លន់ សុភាពរាបសា ស្លូតបូត មានមេត្តាធម៌ និងគុណធម៌ក្នុងខ្លួន ព្រមទាំងចេះអត់ឱនអធ្យាស្រ័យ ។ ប៉ុន្តែ ការដែល អៀង ធីរិទ្ធ ជាប់ពាក់ព័ន្ធនឹងរបបមួយដែលបង្កឲ្យមនុស្សស្លាប់ជិតពីរលាននាក់នោះគឺជារឿងមិនអាចនឹកស្មានដល់ ។ តាមការសម្ភាសន៍កម្មាភិបាលពេទ្យជាច្រើននាក់បានបង្ហាញថាសមាជិកកម្មាភិបាលមកពីក្រសួងសង្គមកិច្ចនិងសុខាភិបាលជាច្រើននាក់ត្រូវបានចាប់ខ្លួននិងសម្លាប់ ។ អៀង ធីរិទ្ធ ពិតជាដឹងរឿងនេះ ហើយគាត់ក៏ធ្លាប់ចោទប្រកាន់ នួន ជា ពីបទអនុវត្តការចាប់ខ្លួននិងសម្លាប់កម្មាភិបាលពេទ្យរបស់ខ្លួនដែរ ។*

*នៅក្នុងសវនាការបឋមកាលពីថ្ងៃទី២៧ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១១ មានមេដឹកនាំបួនរូប នួន ជា, អៀង សារី, អៀង ធីរិទ្ធ និង ខៀវ សំផន ។ រយៈពេលបួនថ្ងៃនៅក្នុងសវនាការបឋមនេះ អៀង ធីរិទ្ធ បែរជាមិនបាននិយាយអ្វីទាំងអស់ ។*

*ប៉ុន្តែ តាមរយៈសវនាការកាលពីលើកមុន អៀង ធីរិទ្ធ បាននិយាយថា «...ខ្ញុំមិនដែលប្រព្រឹត្តខុសទេ ហើយខ្ញុំក៏មិនដែលសម្លាប់មនុស្សដែរ» ដែលពាក្យសម្ដីនេះបញ្ជាក់ថា គាត់មិនបានពាក់ព័ន្ធនឹងបទឧក្រិដ្ឋទេ ហើយការចោទប្រកាន់នេះគឺមិនត្រឹមត្រូវឡើយ ។ ដូច្នេះ ទោះបីជាលើកនេះ អៀង ធីរិទ្ធ មិនបាននិយាយដូចមេដឹកនាំ នួន ជា ដែលថា «ខ្ញុំមិនសប្បាយចិត្តចំពោះសវនាការនេះទេ» ក៏គេអាចសន្និដ្ឋានបានថា អៀង ធីរិទ្ធ នៅតែមានគោល*



គណៈប្រតិភូបរទេសទស្សនកិច្ចរបបកម្ពុជាប្រជាធិបតេយ្យ

ជំហរដូចមុនដដែលគឺគាត់ចាត់ទុកខ្លួនឯងជាជនរងគ្រោះម្នាក់ក្នុងចំណោមជនរងគ្រោះរាប់លាននាក់ផ្សេងទៀតកំពុងស្វែងរកយុត្តិធម៌ និងភាពស្អាតស្អំរបស់ខ្លួន។ បន្ថែមពីលើនេះទៀត មេធាវីរបស់គាត់ លោក ផាត់ ពៅស៊ាង បានឡើងតវ៉ាឲ្យគាត់ដើម្បីឲ្យរួចពីការចោទប្រកាន់ដែរទាក់ទងនឹងអញ្ញត្រកម្មអំពីអាជ្ញាយុកាលនៃបទល្មើសដែលមានចែងក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ដោយនិយាយថា យុត្តិធម៌ត្រូវការទាំងសងខាង ទាំងជនរងគ្រោះនិងជនជាប់ចោទ ហើយការបកស្រាយត្រូវតែយកច្បាប់ជាគោល។ យើងឃើញថា ការបកស្រាយនេះគឺពិតជាត្រឹមត្រូវ ព្រោះថាជនរងគ្រោះត្រូវការស្វែងរកជនល្មើសមកដាក់ទោសទៅតាមផ្លូវច្បាប់ ចំណែកជនជាប់ចោទត្រូវការលើកសម្អាងដើម្បីបង្ហាញថា ខ្លួនមិនបានប្រព្រឹត្តខុសនោះទេ ប៉ុន្តែប្រសិនបើទាំងសងខាងសុទ្ធតែត្រូវការរកយុត្តិធម៌ ចុះហេតុអ្វីបានជាជនដែលត្រូវចោទមិនព្រមលាតត្រដាងការពិតចំពោះអ្វីដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម ដើម្បីស្វែងរកការពិត និងយុត្តិធម៌ទាំងអស់គ្នា ប៉ុន្តែបែរជាធ្វើការបដិសេធមិនដឹងពីការកាប់សម្លាប់នៅក្នុងរបបនោះ។

មនុស្សជាច្រើនស្ទើរតែមិនជឿថា របបខ្មែរក្រហមដែលការសម្លាប់មនុស្សអស់ជិតពីរលាននាក់ដោយគ្មានការវិនិច្ឆ័យទោសក៏មានស្ត្រីចូលរួមពាក់ព័ន្ធនៅក្នុងការសម្លាប់នេះដែរ។ អៀង ធីរិទ្ធ ដែលធ្លាប់តែធ្វើការអះអាងថា គាត់នឹងនិយាយការពិត យើងសង្ឃឹមថា ស្ត្រីទីមួយម្នាក់នេះនឹងធ្វើការសហការជាមួយតុលាការដើម្បីប្រាប់រឿងរ៉ាវពិតដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជានៅពេលនោះនិងដើម្បីបង្ហាញថាស្ត្រីខ្មែរម្នាក់នេះក៏បានរួមចំណែកក្នុងការស្វែងរកយុត្តិធម៌ជូនប្រជាជនកម្ពុជាក៏ដូចជាអ្នកដែលបានបាត់បង់ជីវិតក្នុងរបបខ្មែរក្រហម។

**គាត លក្ខិណា និង ឆាយ ឈុនលី**



អៀង ធីរិទ្ធ ក្នុងបន្ទប់សវនាការ ឆ្នាំ២០១១

# នួន ជា មិនត្រូវដើរចេញពីបន្ទប់សវនាការទេ

ក្នុងអំឡុងវគ្គបណ្តុះបណ្តាលគ្រូប្រវត្តិសាស្ត្រស្តីអំពីវិធីសាស្ត្របង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅខេត្តកំពង់ចាម សិក្ខាកាមម្នាក់ដែលបានតាមដានសវនាការជំនុំជម្រះករណី០០២ បាននិយាយប្រាប់សិក្ខាកាមផ្សេងទៀតថា នួន ជា បានដើរចេញពីបន្ទប់សវនាការកាលពីអង្គបុរេជំនុំជម្រះករណី ០០២ ចាប់ផ្តើមនៅថ្ងៃដំបូងដោយលើកហេតុផលថាគាត់មិនសប្បាយចិត្ត។ ពាក្យនេះបានធ្វើឲ្យសិក្ខាកាមហួសចិត្ត និងរន្ធត់ ព្រោះ នួន ជា បានមាក់ងាយដល់ជនរងគ្រោះ ហើយការធ្វើបែបនេះគឺជារឿង «មិនអាចទទួលយកបាន» ទាល់តែសោះ ។

តុលាការខ្មែរក្រហមបង្កើតឡើងដើម្បីបញ្ជាក់ឲ្យឃើញថាតើជនត្រូវចោទដែលកំពុងឃុំខ្លួនសព្វថ្ងៃនេះគឺជាជនដែលមានកំហុសឬជាជនស្លូតត្រង់ ហើយតុលាការនេះក៏ជាយន្តការមួយដែលអាចរួមចំណែកទប់ស្កាត់អំពើប្រល័យពូជសាសន៍នាពេលអនាគតដែរ ។

នួន ជា ដែលជាអតីតអនុលេខាបក្សកុម្មុយនីស្តកម្ពុជា និងជាប្រធានសភាប្រជាជននៃរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) អាចផ្តល់ព័ត៌មានប្រវត្តិសាស្ត្របានយ៉ាងច្រើនសន្ធឹកសន្ធាប់ ហើយក៏អាចផ្តល់ឲ្យមានការយល់ដឹងច្រើនដែរទាក់ទងនិងរបបកម្ពុជាប្រជាធិបតេយ្យសម្រាប់ក្មេងជំនាន់ក្រោយ បើសិនជាគាត់មានវត្តមាននៅក្នុងបន្ទប់សវនាការរហូតដល់ដំណើរការនេះចប់ចុងចប់ដើម ។

នេះជាឱកាសចុងក្រោយសម្រាប់ នួន ជា និងមេដឹកនាំខ្មែរក្រហមដទៃទៀតដើម្បីធ្វើអ្វីមួយដល់ប្រទេសរបស់ខ្លួន ។

**ឌី ខាំបូលី**




នួន ជា ក្នុងបន្ទប់សវនាការ ឆ្នាំ២០១១

# ប្រតិកម្មរបស់យុវជនចំពោះសំណុំរឿង០០២

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបើកសវនាការបឋមនៃសំណុំរឿង០០២ដែលទាក់ទងនឹងមេដឹកនាំជាន់ខ្ពស់ចំនួនបួនរូបពីថ្ងៃច័ន្ទ ទី២៧ ដល់ថ្ងៃព្រហស្បតិ៍ ទី៣០ ខែមិថុនា ។ តុលាការខ្មែរក្រហមត្រូវបានចាត់ទុកថាជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រមួយដែលមានអ្នករស់រានមានជីវិត មន្ត្រីជាន់ខ្ពស់អ្នកការទូតអន្តរជាតិ ដូចជាឯកអគ្គរដ្ឋទូតអាមេរិក (ខារ៉ូល រ៉ដលី) និងអ្នកចូលរួមជាតិ និងអន្តរជាតិចូលរួមយ៉ាងច្រើនកុះករ ។ បន្ថែមពីលើនេះទៀត ព្រឹត្តិការណ៍ទាំងនេះបានទាក់ទាញការយកចិត្តទុកដាក់យ៉ាងខ្លាំងទាំងក្នុងតំបន់ និងពិភពលោកតាមរយៈទូរទស្សន៍ វិទ្យុ និងសារព័ត៌មានផ្សេងៗ ។ ក្នុងចំណោមអ្នកចូលរួមយ៉ាងច្រើននេះ និស្សិតកម្ពុជាក៏បានខិតខំប្រឹងប្រែងដើម្បីតាមដានតុលាការនេះដែរ ។

ហេតុអ្វីបានជានិស្សិតទាំងនេះចូលរួមក្នុងតុលាការនេះ? និសិ្សតទាំងនេះចូលរួមក្នុងតុលាការពីព្រោះវាជាផ្នែកមួយនៃប្រវត្តិសាស្ត្ររបស់ប្រទេសដែលយុវជនទាំងនោះចាំបាច់ត្រូវតែដឹង ។ យុវជនគឺជាទំពាំងស្នងឫស្សីដែលជាមូលដ្ឋានដ៏សំខាន់ណាស់សម្រាប់ប្រទេសជាតិ ។ ប្រមាណ៦៥ភាគរយនៃប្រជាជនកម្ពុជាសរុបគឺជាយុវជន ។ ដោយសារតែយុវជនតំណាងឲ្យភាគច្រើននៃប្រជាជនកម្ពុជា ទស្សនៈនិងការគិតរបស់យុវជនទាំងនោះនឹងមានផលប៉ះពាល់ និងជះឥទ្ធិពលយ៉ាងធំទៅលើអនាគតរបស់ប្រទេសជាតិ ។ ទស្សនៈរបស់យុវជនមានកម្លាំងដូចខ្យល់ព្យុះស៊ូណាមិ ។ ប៉ុន្តែទស្សនៈរបស់យុវជនក៏អាចបង្កជាផលប៉ះពាល់ដូចកម្លាំង



អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមតម្រង់ជួរចូលក្នុងបន្ទប់សវនាការ

ស៊ូណាមីដែលមិនបានជួយអភិវឌ្ឍប្រទេសដែរ ប៉ុន្តែបែរជាបំផ្លាញនូវសក្តានុពលរបស់អនាគតប្រទេសជាតិទៅវិញ ។

ណៃ ធារី និង នី ធីតា មានអាយុ១៩ឆ្នាំ ជាសិស្សរៀនថ្នាក់ទី១២ នៅវិទ្យាល័យហ៊ុនសែនស្អាង ។ នាពេលព្រឹកខណៈពេលដែលសំណុំរឿង០០២បានចាប់ផ្តើម អ្នកទាំងពីរបានក្រោកពីព្រឹកដើម្បីប្រមែប្រមូលមិត្តរួមថ្នាក់នៅក្នុងភូមិនិងជិះម៉ូតូប្រហែលជាពីរម៉ោងដើម្បីទៅជិះរថយន្តដែលរង់ចាំរួចជាស្រេចនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញដើម្បីធ្វើដំណើរមកកាន់តុលាការខ្មែរក្រហម ។ នៅពេលសួរអំពីការយល់ឃើញទាក់ទងនឹងសម្តីរបស់ នួន ជា ដែលនិយាយថា «ខ្ញុំមិនសប្បាយចិត្តទេនៅថ្ងៃនេះ» ធារី និង ធីតា និយាយថា «ខ្ញុំឆ្ងល់ថាហេតុអ្វីបានជាគាត់មិនសប្បាយចិត្ត ឬក៏មកពីគាត់ត្រូវបានតុលាការកាត់ទោស? តើគាត់និយាយបែបនេះយ៉ាងម៉េចកើត? តើគាត់សប្បាយចិត្តឬនៅពេលគាត់ឃើញខ្មែរក្រហមសម្លាប់មនុស្សច្រើនបែបនេះ? ជាក់ស្តែង គាត់ជាអ្នកចេញបញ្ជាហើយឲ្យអ្នកនៅក្រោមបង្គាប់អនុវត្តតាមគាត់» ។

ឆែម ពៃ ជានិស្សិតមហាវិទ្យាល័យឆ្នាំទីពីរផ្នែកសង្គមវិទ្យានៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញបានចូលរួមក្នុងសវនាការនេះនៅថ្ងៃទីពីរ ។ នៅពេលអង្គសវនាការឈប់សម្រាក ឆែម ពៃ បាននិយាយថា «ខ្ញុំមកចូលរួមសវនាការនេះពីព្រោះខ្ញុំចង់ដឹងថាតើហេតុអ្វីបានជាមនុស្សរាប់លាននាក់ត្រូវបានសម្លាប់? ហើយប្រសិនបើវាជាបញ្ជាពីខាងលើ តើនរណាជាមេដឹកនាំជាន់ខ្ពស់នោះ?» ។

សុភា ជានិស្សិតច្បាប់នៅឆ្នាំទីពីរបាននិយាយថា នាងមានការខកចិត្តបន្តិចបន្តួច ពីព្រោះតែនាងរំពឹងថានឹងឃើញមេដឹកនាំទាំងបួននាក់នេះអង្គុយនៅក្នុងតុលាការពេញម៉ោង ។ សុភា គិតថាមេដឹកនាំទាំងនេះគួរតែមានវត្តមាននៅក្នុងអំឡុងពេលអង្គសវនាការនេះ ។ សុភា និយាយថា «នៅពេលដែលមេដឹកនាំទាំងនេះស្នើសុំចាកចេញពីសវនាការពីព្រោះតែគាត់ឈឺខ្នងនិងចង្កេះ តើមេដឹកនាំទាំងនេះមិនគិតពីមនុស្សចាស់ដែលគាត់បានបង្ខំឲ្យធ្វើការដោយគ្មានការយកចិត្តទុកដាក់ថាមនុស្សចាស់នេះឈឺ ឬចាស់ជរាដែរឬទេ?»

ចេង វឌ្ឍនា ជានិស្សិតឆ្នាំទីពីរផ្នែកសង្គមវិទ្យាចង់ឃើញការពិភាក្សាដេញដោលគ្នារវាងជនជាប់ចោទនិងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងការប្រជុំរបស់តុលាការ ។ វឌ្ឍនា និយាយថា «សវនាការថ្ងៃនេះភាគច្រើនអានតែអង្គនីតិវិធីច្បាប់ប៉ុណ្ណោះ ខ្ញុំនឹងអង្កេតមើលបន្តទៀត ពីព្រោះខ្ញុំចង់ឃើញសេចក្តីសម្រេចចុងក្រោយ... ។ មិនថាតុលាការកាត់ទោសមេដឹកនាំទាំងនេះត្រឹមតែ៣០ឆ្នាំ ឬ៥ឆ្នាំ ក៏ដោយ ក៏មេដឹកនាំទាំងនេះនឹងស្លាប់ឆាប់ៗនេះដោយសារតែមេដឹកនាំទាំងអស់នេះមានវ័យចាស់ហើយ ប៉ុន្តែខ្ញុំសង្ឃឹម និងចង់ឃើញតុលាការនេះកាត់ក្តីដោយត្រឹមត្រូវ និងនាំយុត្តិធម៌ជូនជនរងគ្រោះ» ។

នៅពេលខ្ញុំសួរយុវជនទាំងនេះថាអ្វីដែលពួកគេជឿថាជាយុត្តិធម៌ត្រឹមត្រូវ ហើយថាតើយុត្តិធម៌នេះអាចសម្រេចបានដោយរបៀបណានោះ? យុវជនភាគច្រើនឆ្លើយថា វាគឺជាសវនាការត្រឹមត្រូវមួយនៅពេលដែលប្រជាជនភាគច្រើនអាចទទួលយកបាន និងសមរម្យ ។

តុលាការខ្មែរក្រហមបានដើរតួនាទីមួយយ៉ាងសំខាន់នៅក្នុងការផ្តល់យុត្តិធម៌ ហើយជាតុលាការដែលមានបទដ្ឋាន និងជាគំរូល្អមួយ ។ ដូច្នេះ នេះជាការទទួលខុសត្រូវរបស់តុលាការក្នុងការពន្យល់និងធ្វើឲ្យប្រជាជនយល់នូវតួនាទីរបស់ប្រជាជន នីតិវិធីច្បាប់ និងដំណើរការអង្គសវនាការនេះ ពីព្រោះថាអ្នកដែលទទួលផលប្រយោជន៍សំខាន់ពីតុលាការគឺអ្នករស់រានមានជីវិតនៃរបបខ្មែរក្រហម និងប្រជាជនកម្ពុជាទូទៅ ។ នេះជាតួនាទីមួយយ៉ាងសំខាន់របស់តុលាការ ដើម្បីបង្កើននូវការយល់ដឹងអប់រំនៅក្នុងចំណោមយុវជន ។

សវនាការត្រឹមត្រូវ និងយុត្តិធម៌ផ្អែកយ៉ាងសំខាន់ទៅលើអ្នករស់រានមានជីវិត ពីព្រោះតុលាការនេះគឺជាកម្មសិទ្ធិអ្នកទាំងអស់នោះដោយអាទិភាព ។ ប្រសិនបើអ្នករស់រានមានជីវិតភាគច្រើនយល់ស្របនិងសប្បាយចិត្តចំពោះសេចក្តីសម្រេចដាក់ទណ្ឌកម្មរបស់តុលាការ នោះតុលាការនឹងទទួលជោគជ័យ ហើយតុលាការខ្លួនឯងនឹងទទួលបាននូវភាពត្រឹមត្រូវយុត្តិធម៌ដែរ ។ ផ្ទុយទៅវិញ ប្រសិនបើគ្មានការទទួលស្គាល់ពីប្រជាជនទេ នោះយុត្តិធម៌ និងតុលាការខ្លួនឯងប្រៀបបីដូចជាត្រីដែលគ្មានទឹក ស្ងួតហើយអត់ស្រកាដូច្នេះឯង ។ **សេរី សាយ្យាណា**

# ស្វែងរកស្វាមីឈ្មោះ មូល វង្សបណ្ឌិត ហៅ ណេង



មាន គុណា

នាងខ្ញុំឈ្មោះ មាន គុណា សព្វថ្ងៃរស់នៅភូមិព្រៃកទំលាប់ ឃុំព្រៃកទំលាប់ ស្រុកលើកដែក ខេត្តកណ្តាល ។ នៅឆ្នាំ១៩៧៨ យើងរស់នៅខេត្តពោធិ៍សាត់ ហើយពេលនោះក្រុម ប៉ុល ពត តម្រូវឲ្យយើងបែកគ្នាដោយបញ្ជូនខ្ញុំនិងកូនស្រីខ្ញុំឈ្មោះ ណេង ក្រវ៉ាន់ ទៅភ្នំក្តោក ចំណែកឯប្តីខ្ញុំនៅភូមិព្រៃផ្តៅប ។ តាំងពីពេលនោះមក នាងខ្ញុំមិនដែលបានជួបគាត់សោះ មិនដឹងថាគាត់នៅរស់ឬក៏ក្រុម ប៉ុល ពត យកគាត់ទៅឯណាទេ ។ ប្រសិនបើប្អូនឃើញឬស្គាល់ប្តីនាងខ្ញុំឈ្មោះ មូល វង្សបណ្ឌិត ហៅ ណេង សូមទំនាក់ទំនងមកនាងខ្ញុំតាមទូរស័ព្ទលេខ ០១១ ៦២០ ៧៩៩ ឬផ្ទះលេខ១ ផ្លូវ៥៨២ សង្កាត់ទួលគោក១ ខ័ណ្ឌទួលគោក ក្រុងភ្នំពេញ ។

# ដំណឹងស្វែងរកគ្រួសារដែលបាត់ខ្លួននៅសម័យខ្មែរក្រហម

ខ្ញុំបាទឈ្មោះ អួន ផល្លី ហៅ វ៉ា ឬប្រុស សព្វថ្ងៃរស់នៅក្នុងភូមិប្រក់ស្តារ ឃុំវិហារលួង ស្រុកពញាឮ ខេត្តកណ្តាល ។ ខ្ញុំបាទសូមប្រកាសសួររកក្រុមគ្រួសារដែលបានបាត់ខ្លួននៅក្នុងរបបខ្មែរក្រហម រួមមាន ១) ឪពុកឈ្មោះ អួន ២) ម្តាយឈ្មោះ ហន (ពៅ) ៣) បងស្រីទីមួយ អួន មុំ ៤) បងស្រីទីពីរ អួន ម៉ាច ៥) ប្អូនស្រីទី៤ អួន ស្រី និង ៦) ប្អូនស្រីពៅឈ្មោះ អួន ស្រស់ ។ ភ្លាមៗបន្ទាប់ពីខ្មែរក្រហមវាយចូលទីក្រុងភ្នំពេញនៅឆ្នាំ១៩៧៥ គ្រួសាររបស់ខ្ញុំដែលមានសមាជិកប្រាំពីរនាក់ រួមទាំងខ្ញុំដែរត្រូវបានខ្មែរក្រហមជម្លៀសទៅនៅឃុំព្រៃកភ្នៅ ស្រុកពារាំង ខេត្តព្រៃវែង ។ ពេលទៅដល់នោះបានមួយរយៈខ្លី សមាជិកគ្រួសាររបស់ខ្ញុំក៏បានបាត់ខ្លួនជា បន្តបន្ទាប់ដោយមិនដឹងពីមូលហេតុ ។ កាលនោះខ្ញុំក៏មិនបានដឹងពីការបាត់ខ្លួនរបស់គាត់ដែរ ពីព្រោះថាខ្ញុំត្រូវបានចាត់ឲ្យទៅធ្វើការនៅកងកុមារឆ្ងាយពីភូមិ ។ បើសិនជាក្រុមគ្រួសាររបស់ខ្ញុំបានឮដំណឹងនេះ ឬបងប្អូនណាបានស្គាល់គាត់ សូមមេត្តាទំនាក់ទំនងមកខ្ញុំបាទតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជា ឬខ្ញុំបាទផ្ទាល់តាមរយៈទូរស័ព្ទលេខ ០១២ ៦១២ ១០៦ ឬ ០៩៧ ៩២៥ ១៩៦៩ ។ ***សូមអរគុណ***

# ដំណឹងស្វែងរកក្រុមគ្រួសារ

ខ្ញុំបាទឈ្មោះ សួន វណ្ណថន សព្វថ្ងៃរស់នៅក្នុងភូមិជ័យក្រោម ឃុំរាធរ ស្រុកព្រះស្តេច ខេត្តព្រៃវែង ។ ខ្ញុំបាទសូមប្រកាសសួររកក្រុមគ្រួសារដែលបានបាត់ខ្លួននៅខេត្តពោធិ៍សាត់ ចុងឆ្នាំ១៩៧៨ ។ នៅចុងឆ្នាំ១៩៧៨ ប្អូនស្រីរបស់ខ្ញុំឈ្មោះ សួន ស្រីពៅ (ហៅ ជិន ស្រីពៅ) បានបាត់ខ្លួននៅកងកុមាររបស់សហករណ៍វត្តលួង ដែលស្ថិតនៅក្បែរភូមិទួលព្រះថ្ម ស្រុកបាកាន ខេត្តពោធិ៍សាត់ ។ កាលនោះស្រីពៅ មានអាយុប្រហែល៧ឆ្នាំប៉ុណ្ណោះ ។ ក្រោយពេលបែកគ្នា ខ្ញុំបានឮដំណឹងថា យាយអ៊ឹម និងតាថេម ដែលជាអ្នកស្រុកពោធិ៍សាត់ បានរើសប្អូនស្រីខ្ញុំ (ស្រីពៅ) មកចិញ្ចឹម ។ តែក្រោយមកមិនដែលបានឮដំណឹងអ្វីទាល់តែសោះ ។ ក្រៅពីប្អូនស្រីពៅ បានបាត់ខ្លួនម្តាយខ្ញុំឈ្មោះ សារឿង ឪពុកឈ្មោះ ជិន ប្អូនប្រុស២នាក់ឈ្មោះ ថា និង ព្រីង ក៏បាត់ខ្លួននៅខេត្តពោធិ៍សាត់ដែរ ។

ប្រសិនបើបងប្អូនណាបានស្គាល់ឬបានឃើញ ឬក្រុមគ្រួសារបានឮដំណឹងនេះហើយ សូមមេត្តាទំនាក់ទំនងមករូបខ្ញុំផ្ទាល់តាមរយៈអាសយដ្ឋានខាងលើ ឬតាមទូរស័ព្ទលេខ ០៩៧ ៦៨៨ ១៣២៩ ។ ***សូមអរគុណ***

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហម

មជ្ឈមណ្ឌលឯកសារកម្ពុជាគ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមកមជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាងមួយលាននាក់រួចមក ហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ អេង កុកថាយ ទូរស័ព្ទលេខ ០១២ ៩៥៥ ៨៥៨ ឬអ៊ីម៉ែល : truthkokthay@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។

***សូមផ្តល់ព័ត៌មានដូចខាងក្រោមៈ***

១) ឈ្មោះអ្នកប្រកាសប្រាប់ ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់ ៤) ភេទអ្នកស្លាប់ ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន) ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍ : ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី) ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ : ស្លាប់នៅទីណា? មូលហេតុអ្វី?) ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍ : រូបថត ឯកសារ ឬវត្ថុ ផ្សេងៗ) ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍ : លេខទូរស័ព្ទ អាសយដ្ឋាន) ។

***ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោមៈ***

១) ឈ្មោះអ្នកបាត់ខ្លួន ២) ភេទ ៣) អាយុ ៤) ត្រូវជាអ្វី ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍ : រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។




ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវ៉េ ស៊ុីតដេន និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា : ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 139, July 2011 ◆ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.